# សំណួរល្អ ចម្លើយល្អ

## GOOD QUESTION, GOOD ANSWER



- តើអ្វីគឺព្រះពុទ្ធសាសនា?
- គោលគំនិតជាមូលដ្ឋានរបស់ព្រះពុទ្ធសាសនា
- ព្រះពុទ្ធសាសនាជាមួយនឹងគំនិតបូជាអាទិទេព
- និច្ចសីល ឬ សីល៥
- ការកើតម្តងទៀត
- សមាធិ
- បញ្ញា និង មេត្តា
- មំសវិរត្តិឬការមិនហូបសាច់
- សំណាងល្អនិងសំណាងអាក្រក់
- ការក្លាយជាពុទ្ធសាសនិកជន


និពន្ធដោយ ព្រះមហាថេរៈ ស.ធម្មិកៈ

បកប្រែដោយ ព្រះភិក្ខុវោធានោ ស.សុត័ណ



ចែកដោយឥតគិតថ្លៃ *For Free Distribution*

*and Sponsored by Bandar Utama Buddhist Society and Malaysian Buddhist Friends*

# សំណួរល្អ ចម្លើយល្អ

## GOOD QUESTION, GOOD ANSWER


សរសេរដោយ ព្រះមហាថេរៈ ស.ធម្មិកៈ

បកប្រែដោយ ព្រះភិក្ខុវោទានោ ស.សុផាន់

**Writer: Bhikkhu S. Dhammika**

**Translator: Bhikkhu s. Vodano Sophan Seng**

**B.A.(Philosophy)**



បោះពុម្ព និងចែកចាយជាធម្មទាន លើកទីពីរដោយ

**សមាគម អភិវឌ្ឍន៍ព្រះពុទ្ធសាសនា និងសង្គម**

វត្តនគរបាជ័យ ខេត្តកំពង់ចាម

**(FOR FREE DISTRIBUTION)**

**Buddhism and Society Development Association (BSDA)**

**Wat Nokor Bachey Temple, Kampong Cham**

www.bsda-cambodia.org

bsdaoffice@gmail.com

*Sponsored by Bandar Utama Buddhist Society*

*and Malaysian Buddhist Freands*



( Rights Reserved)

(រក្សាសិទ្ធិ)



០៣ កើត ខែ ស្រាពណ៍ ឆ្នាំ ជូត សម្រឹទ្ធិស័ក ព.ស ២៥៥២

០៤ សីហា គ.ស ២០០៨

# ចាចារម្ភកបកប្រែ

សៀវភៅ*សំណួរល្អ ចំឡើយល្អ*នេះសរសេរដោយព្រះភិក្ខុធម្មិកៈ ដែលជាព្រះភិក្ខុសង្ឃសញ្ជាតិអូស្ត្រាលី ជាអ្នកបង្រៀនសមាធិកម្មដ្ឋាន និងទេសនាធម៌ដ៏ល្បីល្បាញ ។ ការសរសេរសៀវភៅនេះកើតឡើងពីការរើសសំរាំងមកឆ្លើយនូវសំណួរល្អៗដែលគេនិយមសួរច្រើន ព្រមទាំងមានអត្ថន័យសំខាន់ផ្តោតទៅលើពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធបរមគ្រូ ។

សំរាប់អ្នកដែលចង់សិក្សាឱ្យស៊ីជំរៅនិងចង់ស្រាវជ្រាវអំពីខ្លឹមធម៌ពិតរបស់ព្រះពុទ្ធសាសនាគួរតែរកឱកាសអានសៀវភៅនេះឱ្យបាន ។

ខ្ញុំព្រះករុណាអាត្មាភាព ឃើញសារៈសំខាន់ដ៏ធំធេងនៃសៀវភៅដ៏តូចនេះ ទើបព្យាយាមប្រែពីភាសាអង់គ្លេសជាភាសាខ្មែរដើម្បីឱ្យពុទ្ធបរិស័ទខ្មែរយើងបានអាននិងសិក្សាឱ្យបានស៊ីជំរៅទៅក្នុងពុទ្ធធម៌ ។

សេចក្តីខុសឆ្គងដែលមិនអាចជៀសវាងបានក្នុងការប្រែសៀវភៅនេះ សូមញាតិញោមពុទ្ធបរិស័ទ កល្យាណមិត្តអ្នកអានទាំងអស់ជួយតិទៀននិងកែតំរូវទៅតាមការគួរ ។

*សូមឧទ្ទិសមគ្គផលដែលកើតអំពីសៀវភៅធម៌ដ៏តូចនេះជូនដល់មាតាបិតា ដែលជាកំពូលអ្នកមានគុណទាំងឡាយ !*

ចំរើនពរដោយសារាណីយធម៌ **ព្រះភិក្ខុសោភណោ ស.សុគំណា**

*១៥ កើត ខែកត្តិក ឆ្នាំច អដ្ឋស័ក ព.ស.២៥៥០*

Email: sophan@hawaii.edu, www.cambodianview.com

# ការប្រកាសរបស់អ្នកនិពន្ធ

សៀវភៅនេះសរសេរដំបូងក្នុងឆ្នាំ១៩៨៧ តំរូវទៅតាមចំណាប់អារម្មណ៍កាន់តែខ្លាំងឡើងក្នុងព្រះពុទ្ធសាសនាក្នុងចំណោមប្រជាជនសាំងកាពួរ។ ចំពោះការពេញចិត្តនិងភ្ញាក់ផ្អើលនោះគឺការដែលសៀវភៅនេះបានទទួលជោគជ័យយ៉ាងសម្បើម។ គ្រាន់តែBDMSបានបោះពុម្ពចំនួន៣០០០០ច្បាប់ ហើយបានប្រែជាភាសាផ្សេងៗជាច្រើនដូចជាភាសាតាមិល ចិន និងនេប៉ាល់។ មានសំណើរសុំឱ្យមានការបោះពុម្ពរាប់ចាប់ពីទីឆ្ងាយៗដូចជាអូស្ត្រាលី អាសង់ទីន និងកោះសីឈីល។ ក្នុងខែមិថុនាឆ្នាំនេះ ខ្ញុំបានទៅទស្សនាខ្មោចនៅដាច់ស្រយាលមួយលើកំពូលភ្នំខ្ពស់ហិមាល័យក្នុងក្រុងឡាដាក់តែមួយកន្លែង ជួបប្រទះឃើញព្រះចៅអធិការវត្តមិនមែនគ្រាន់តែបានអានសៀវភៅ*សំណួរល្អ ចំឡើយល្អ* ប៉ុណ្ណោះទេប៉ុន្តែពេញចិត្តវាយ៉ាងខ្លាំង។ ទាំងអស់នេះបានធ្វើឱ្យខ្ញុំជឿជាក់ថាទំរង់សៀវភៅដ៏តូចនិងសេចក្តីដ៏តិចនេះបានបំពេញតំរូវការដ៏សំខាន់ ហើយការបោះពុម្ពសាឡើងវិញនិងការបន្ថែមកាន់តែច្រើនឡើងនឹងធ្វើឱ្យសៀវភៅនេះមានតំលៃកាន់តែខ្លាំងឡើងដូចជាការបោះពុម្ពនៅពេលនេះ។ អ្នកណាដែលចង់បោះពុម្ពសៀវភៅ*សំណួរល្អ ចំឡើយល្អ* នេះឬបកប្រែវា មិនចាំបាច់សរសេរលិខិតសុំអនុញ្ញាតទេ។ តែយ៉ាងណាក៏ដោយយើងនឹងស្វាគមន៍យ៉ាងខ្លាំងប្រសិនបើអ្នកអាចផ្ញើរសំណៅបោះពុម្ពចំនួនពីរច្បាប់ ហើយប្រាប់ឱ្យយើងដឹងអំពីចំនួនដែលបានបោះពុម្ពនោះ។

**ព្រះតេជគុណ ស.ធម្មិកៈ**

សាំងកាពួរ ១៩៩១

# មាតិកា

*ចំណងជើងរឿង* *ទំព័រ*

## ភាគ ១

## តើអ្វីគឺជាព្រះពុទ្ធសាសនា


តើព្រះពុទ្ធសាសនាជាអ្វី? ១

ដូច្នេះ តើព្រះពុទ្ធសាសនាគ្រាន់តែជាទស្សនវិជ្ជាឬ? ១

តើព្រះពុទ្ធជានរណា? ២

តើព្រះពុទ្ធជាអាទិទេពឬ? ៣

បើព្រះពុទ្ធមិនមែនជាអាទិទេពទេ ចុះហេតុអ្វីប្រជាជនគោរពបូជា
ព្រះអង្គ? ៣

តែខ្ញុំបានឮគេនិយាយថាពុទ្ធសាសនិកជនគោរពបូជារូបសំណាក។ ៤

បើព្រះពុទ្ធសាសនាល្អ ចុះហេតុអ្វីប្រទេសកាន់ព្រះពុទ្ធសាសនាខ្លះ
ក្រីក្រម្លេះ? ៥

បើដូច្នោះ ចុះហេតុអ្វីយើងមិនដែលឮជាញឹកញាប់សោះអំពីការធ្វើសង្គមសង្គ្រោះពី
ពុទ្ធសាសនិកជនទាំងឡាយ? ៦

ហេតុអ្វីបានជាមានព្រះពុទ្ធសាសនាច្រើននិកាយប្លែកៗគ្នាច្រើនម្លេះ? ៧

តើព្រះពុទ្ធសាសនាមានលក្ខណៈជាវិទ្យាសាស្ត្រទេ? ៧

## ភាគ ២

## គោលគំនិតជាមូលដ្ឋានរបស់ព្រះពុទ្ធសាសនា

តើខ្លឹមសារសំខាន់នៃពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគឺអ្វី? ១០

តើអរិយសច្ចទី១គឺអ្វី? ១០

តើនេះមិនមែនជាលក្ខណៈទុទិដ្ឋិនិយមឬ? ១០

តើអរិយសច្ចទី២គឺអ្វី? ១១

តែ តើសេចក្ដីត្រូវការនិងតណ្ហានាំយើងទៅរកសេចក្ដីទុក្ខខាងផ្លូវ
កាយយ៉ាងណា? ១២

តែបើយើងបញ្ឈប់ចំណង់គ្រប់យ៉ាងទាំងអស់ យើងនឹងមិនបានសំរេចអ្វីសោះ។ ១២

តើអរិយសច្ចទី៣គឺអ្វី? ១៣

ព្រះនិព្វានគឺអ្វីហើយនៅទីណា? ១៣

តើគេមានភស្តុតាងបញ្ជាក់ពីការមានឋានសួគ៌ឋានស្ថានពិតប្រាកដឬទេ? ១៤

តើអរិយសច្ចទី៤គឺអ្វី? ១៥

## ភាគ ៣

## ព្រះពុទ្ធសាសនាជាមួយនឹងគំនិតបូជាអាទិទេព

តើពុទ្ធសាសនិកជនជឿលើអាទិទេពទេ? ១៦

តែបើគ្មានអាទិទេពទេ តើចក្រវាឡកើតឡើងនៅទីនេះបានយ៉ាងណា? ១៩

តើព្រះពុទ្ធត្រាស់ថាដូចម្ដេចអំពីកំណើតរបស់ចក្រវាឡ? ១៩

អ្នកនិយាយថាគ្មានភស្តុតាងការមានអាទិទេពពិតប្រាកដ។ ចុះអំពី អព្ភូតហេតុទាំងឡាយ? ១៩

តែមនុស្សជាច្រើនជឿលើតួអង្គអាទិទេពរូបរាងផ្សេងៗ នោះវាពិតជាមានពិត។ ២០

ដូច្នេះបើពុទ្ធសាសនិកជនមិនជឿលើអាទិទេពទាំងឡាយ តើពុទ្ធសាសនិកជន ជឿទៅលើអ្វី? ២១

## ភាគ ៤

## និច្ចសីល ឬ សីល៥

សាសនាផ្សេងៗចាប់យកគំនិតត្រូវឬខុសពីបញ្ញត្តិទាំងឡាយរបស់អាទិទេពមួយ អង្គឬច្រើនអង្គ។ អ្នកជាពុទ្ធសាសនិកជនបែរជាមិនជឿលើអាទិទេព ដូច្នេះតើអ្នកដឹងសេចក្តីត្រូវពីសេចក្តីខុសបានយ៉ាងណា? ២២

ដូច្នេះ តើព្រះពុទ្ធសាសនាមានក្រមសីលធម៌ទេ? ២៣

តែតាមពិតវាជាការល្អដែលត្រូវសំឡាប់នៅពេលខ្លះ។ ឧទាហរណ៍ ដូចជាសំឡាប់សត្វល្អិតដែលចំឡងមេរោគ ឬក៏អ្នកខ្លះនឹងមកសំឡាប់យើង? ២៣

អ្នកជាពុទ្ធសាសនិកជនដែលអោយតំលៃខ្លាំងទៅលើស្រមោច និងសង្កើច ។ ២៤

សិក្ខាបទទី៣បញ្ជាក់ថាយើងគួរចៀសវាងការប្រព្រឹត្តខុសផ្លូវភេទ តើអ្វីគឺការ ប្រព្រឹត្តខុសផ្លូវភេទ? ២៤

ការរួមភេទមុនពេលរៀបអាពាហ៍ពិពាហ៍ជាប្រភេទការប្រព្រឹត្តខុសផ្លូវភេទទេ? ២៥

ចុះអំពីការនិយាយកុហក់? តើយើងអាចរស់នៅបានទេបើយើងគ្មានការកុហក់? ២៥

ប្រពៃណាស់! ចុះអំពីការផឹកទឹកស្រវឹង? តាមពិតផឹកបន្តិចបន្តួចមិនខុសអ្វីមែនទេ? ២៥

ផឹកតិចតួចអាចនឹងមិនខុសសីលមែនទេ? ព្រោះវាបន្តិចបន្តួចប៉ុណ្ណោះ។ ២៦
សីល៥គឺអវិជ្ជមាន។ សិក្ខាបទទាំងឡាយប្រាប់អ្នកមិនអោយធ្វើអ្វីឡើយ
គេហាមមិនអោយធ្វើអ្វីសោះឡើយ។ ២៦

## ភាគ ៥

## ការកើតម្តងទៀត

តើពួកសត្វលោកទាំងអស់កើតមកពីណា ហើយពេលពួកគេស្លាប់ទៅកើតនៅទីណា? ២៨
តើចិត្តចេញពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបានយ៉ាងណា? ២៩
តើមនុស្សម្នាក់ៗសុទ្ធតែកើតកំណើតជាមនុស្សទាំងអស់ឬ? ២៩
តើអ្វីដែលកំណត់នូវទីកន្លែងដែលយើងទៅកើត? ៣១
ដូច្នេះបើជីវិតរបស់យើងត្រូវកំណត់ដោយកម្មរបស់យើង តើអាចប្តូរវាបានទេ? ៣១
អ្នកបានពន្យល់ច្រើនអំពីការកើតម្តងទៀត តើមានភស្តុតាងណាមួយ
ទេដែលបញ្ជាក់ថាយើងកើតម្តងទៀតក្រោយពីការស្លាប់? ៣៣
អ្នកនិយាយថា ការនិយាយអំពីបិសាចគឺជារឿងអរូបិយ៍។ តើការនិយាយ
អំពីការកើតម្តងទៀតមិនមែនជារឿងអរូបិយជំនឿនោះដែរឬ? ៣៥
មែនហើយ តើមានអ្នកវិទ្យាសាស្ត្រណាមួយដែលជឿទៅលើការកើតថ្មីម្តងទៀត? ៣៥

## ភាគ ៦

### សមាធិ


តើអ្វីគឺសមាធិ? ៤០

តើសមាធិមានសារៈប្រយោជន៍ទេ? ៤០

ខ្ញុំឮគេថាសមាធិអាចគ្រោះថ្នាក់។ តើនេះជារឿងពិតមែនឬ? ៤០

តើមានវិធីបដិបត្តិសមាធិប៉ុន្មានយ៉ាង? ៤២

តើអ្នកបដិបត្តិការចំរើនសតិដោយផ្ដើមខ្យល់ចេញចូលនេះដោយរបៀបណា? ៤២

តើខ្ញុំអាចធ្វើសមាធិយូរយ៉ាងណា? ៤៣

ចុះអំពីការចំរើនមេត្តាសមាធិជាអ្វី? តើសមាធិនេះគេបដិបត្តិដូចម្ដេច? ៤៣

តើការបដិបត្តិបែបនេះបានប្រយោជន៍យ៉ាងណា? ៤៤

តើសមាធិអាចនឹងបានផលយ៉ាងណា? ៤៤

តើខ្ញុំចាំបាច់ត្រូវមានគ្រូបង្រៀនសមាធិខ្ញុំទេ? ៤៥

ខ្ញុំបានដឹងថាសមាធិកម្មដ្ឋានត្រូវបានគេប្រើយ៉ាងទូលំទូលាយដោយពួក
អ្នកចិត្តវិទ្យានិងប្រាសាទវិទ្យា។ តើនេះជារឿងពិតឬទេ? ៤៥


## ភាគ ៧

### បញ្ញា និង មេត្តា


តើពាក្យថាបញ្ញា និងមេត្តា មានអត្ថន័យដូចម្ដេចក្នុងព្រះពុទ្ធសាសនា? ៤៦

ដូច្នេះ អាស្រ័យតាមព្រះពុទ្ធសាសនា តើអ្វីគឺជាបញ្ញា? ៤៧
តើគោលនៃព្រះពុទ្ធសាសនាគឺអ្វីបើមានតែពីរបីនាក់អាចបដិបត្តិបាន ៤៨
អាស្រ័យតាមព្រះពុទ្ធសាសនា តើអ្វីគឺជាមេត្តាធម៌? ៤៨
តើវាមិនមែនជាបុគ្គលនិយមឬទេ ដែលនិយាយថាយើងគឺចំណុច
ខ្លាំងបំផុតដែលអាចជួយអ្នកដទៃបន្ទាប់ពីយើងបានជួយខ្លួនយើង។ ៤៩

## ភាគ ៨

## មំសវិរត្តិ ឬ ការហូបបន្លែ

ពុទ្ធសាសនិកជនគួរតែមិនបរិភោគសាច់មែនទេ? ៥០
បើអ្នកបរិភោគសាច់ គឺអ្នកត្រូវទទួលខុសត្រូវដោយត្រង់នូវការសំឡាប់សត្វទាំងឡាយ។
តើនោះមិនមែនជាការប្រព្រឹត្តខុសសីលទីមួយឬ? ៥០
ពុទ្ធសាសនិកជននិកាយមហាយានមិនបរិភោគសាច់ទេ? ៥១
តែខ្ញុំនៅតែគិតថាពុទ្ធសាសនិកជនគួរតែមំសវិរត្តិ។ ៥១
មនុស្សដែលជាអ្នកមានសេចក្ដីស្មោះត្រង់និងសន្ដានចិត្តល្អ។ ៥១
ពីព្រោះមនុស្សប្រភេទនោះមានសន្ដានចិត្តល្អជាក់ស្ដែង ។ ៥១

## ភាគ ៩

## សំណាងល្អ និង សំណាងអាក្រក់

តើព្រះពុទ្ធជាម្ចាស់បង្រៀនអ្វីខ្លះអំពីមហិទ្ធិឫទ្ធិនិងការទោះទាយ? ៥៣

បើដូច្នេះ ហេតុអ្វីពេលខ្លះមនុស្សបដិបត្តិដូចនោះ ហើយជឿនូវវិជ្ជាសិល្បៈទាំងនោះ? ៥៣
តែវេទមន្តភ័ព្វសំណាងខ្លះជួយបានពិតប្រាកដ មែនទេ? ៥៤
ដូច្នោះ តើមានវត្ថុដូចនេះអាចជាភ័ព្វសំណាងទេ? ៥៤

## ភាគ ១០

## ការក្លាយជាពុទ្ធសាសនិកជន

អ្វីដែលបាននិយាយមកទាំងអម្បាលមាណ ធ្វើឱ្យខ្ញុំចាប់អារម្មណ៍ណាស់
តើខ្ញុំអាចក្លាយជាពុទ្ធសាសនិកជនបានយ៉ាងណា? ៥៦
បើខ្ញុំបានធ្វើដូច្នេះហើយអាចយល់ដឹងនូវពាក្យប្រៀនប្រដៅរបស់ព្រះ
ពុទ្ធអង្គដែលអាចទទួលយកបាន បន្ទាប់មកតើខ្ញុំគួរធ្វើដូចម្តេចបើខ្ញុំ
ចង់ក្លាយជាពុទ្ធសាសនិកជន? ៥៧
តើអ្វីជាការយកព្រះរតនត្រ័យជាទីពឹងទីរលឹក? ៥៧
តើមានអ្វីផ្លាស់ប្តូរកើតឡើងក្នុងជីវិតរបស់អ្នកចាប់តាំងពីពេលអ្នកយក
ព្រះរតនត្រ័យជាទីពឹងទីរលឹកជាលើកដំបូង? ៥៩
ខ្ញុំមានមិត្តម្នាក់ដែលជាញឹកញយព្យាយាមទាក់ទាញខ្ញុំឱ្យចូលសាសនារបស់គេ។
ខ្ញុំពិតជាមិនបានចាប់អារម្មណ៍ទៅលើសាសនារបស់គាត់ ហើយខ្ញុំក៏បានប្រាប់ទៅគាត់ដូច្នេះ
តែគាត់នៅតែមិនចាកចេញពីខ្ញុំ។ តើខ្ញុំអាចធ្វើយ៉ាងណា? ៥៩
តែគាត់និយាយថាគាត់ចូលរួមចំណែកសាសនារបស់គាត់ជាមួយខ្ញុំ។ ៦០
ដូច្នេះតើខ្ញុំអាចបញ្ឈប់គាត់បានយ៉ាងណា? ៦០
តើពុទ្ធសាសនិកជនអាចព្យាយាមរួមចំណែកធម៌ជាមួយអ្នកដទៃបានទេ? ៦១

# ភាគ ១

# តើអ្វីគឺជាព្រះពុទ្ធសាសនា?

**ឞុ.** *តើព្រះពុទ្ធសាសនាជាអ្វី?*

**ទិ.** ឈ្មោះថាព្រះពុទ្ធសាសនាមានប្រភពពីពាក្យថា *ពោធិ* ដែលមានន័យថា *ត្រាស់ដឹង* ហើយព្រះពុទ្ធសាសនាជាទស្សនវិជ្ជានៃការត្រាស់ដឹង។ ទស្សនវិជ្ជា នេះមានប្រភពមកពីបទពិសោធន៍ពិតរបស់សិទ្ធត្ថគោតមដែលគេស្គាល់ថាជាព្រះពុទ្ធពេលព្រះអង្គត្រាស់ដឹងក្នុងព្រះជន្មាយុ ៣៥ព្រះវស្សា។ ព្រះពុទ្ធសាសនាឥឡូវនេះមានអាយុ២៥០០ឆ្នាំ[1] ហើយមានសាសនិកជនជាង ៣០០លាននាក់ទូទាំងពិភពលោក។ ១០០ឆ្នាំកន្លងផុតទៅព្រះពុទ្ធសាសនាបានក្លាយជាទស្សនាវិជ្ជាសំខាន់របស់អាស៊ី ប៉ុន្តែបានកំពុងបង្កើនសាសនិកយ៉ាង ច្រើននៅអឺរ៉ុប អូស្ត្រាលី និងអាមេរិក។

**ឞុ.** *ដូច្នេះ តើព្រះពុទ្ធសាសនាគ្រាន់តែជាទស្សនវិជ្ជាឬ?*

**ទិ.** ពាក្យទស្សនវិជ្ជាមកពីពាក្យពីរម៉ាត់គឺហ្វីឡូមានន័យថាស្រឡាញ់ និងសូហ្វៀមានន័យថាបញ្ញា។ ដូច្នេះទស្សនវិជ្ជាគឺស្រឡាញ់បញ្ញាឬ ស្រឡាញ់និងបញ្ញា អត្ថន័យទាំងពីរបញ្ជាក់នូវភាពសុក្រឹតរបស់ព្រះពុទ្ធសាសនា។ ព្រះពុទ្ធសាសនាបង្រៀនយើងថាចូរព្យាយាមអភិវឌ្ឍន៍គំនិតបញ្ញាអោយខ្ពស់បំផុតដើម្បីស្វែងយល់អោយច្បាស់លាស់។ ហើយបង្រៀនផងដែរអោយយើងអភិវឌ្ឍន៍ មេត្តាធម៌និងករុណាធម៌ ដូច្នេះយើងអាចជាមិត្តពិតប្រាកដរវាងសត្វ

[1] នេះជាអាយុឆ្នាំពេលដែលអ្នកនិពន្ធសរសេរសៀវភៅនេះ សព្វថ្ងៃគឺ ព.ស.២៥៥០

លោកទាំងអស់។ ដូច្នេះព្រះពុទ្ធសាសនាអាចជាទស្សនវិជ្ជាតែជាឧត្តមទស្សនវិជ្ជា។

## ២. *តើនរណាជាព្រះពុទ្ធ?*

**១.** ក្នុងឆ្នាំ៦២៣មុនគ្រឹស្តសករាជ ព្រះរាជបុត្រមួយព្រះអង្គបានប្រសូត្រឡើងក្នុងរាជត្រកូលភាគខាងជើងប្រទេសឥណ្ឌា។ ព្រះអង្គធំធាត់នៅលើគំនរទ្រព្យនិងលោកីយសុខ តែជាចុងក្រោយព្រះអង្គយល់ថាសុវត្ថិភាពនិងសេចក្តីសុខផ្លូវលោកមិនអាចធានាដល់សេចក្តីសុខពិតប្រាកដឡើយ។ ព្រះអង្គត្រូវបានជំរុញអោយគិតយ៉ាងខ្លាំងនូវសេចក្តីទុក្ខដែលប្រទះជុំវិញខ្លួន ហើយគិតនឹងត្រូសត្រាយផ្លូវទៅរកសេចក្តីសុខពិតប្រាកដរបស់មនុស្សជាតិ។លុះព្រះជន្ម២៩ព្រះវស្សាព្រះអង្គបានចេញចាកព្រះរាជមហេសីនិងបុត្រហើយតាំងទីសេនាសនៈចំពោះបាទាគ្រូបង្រៀនសាសនាល្បីៗនៅសម័យនោះដើម្បីរៀនសូត្រពីពួកគេ។ គ្រូទាំងអស់នោះបង្រៀនស្ទើរតែអស់នូវចំណេះវិជ្ជា ប៉ុន្តែព្រះអង្គមិនចេះវិជ្ជាណាមួយដែលជាហេតុនៃសេចក្តីទុក្ខហើយនិងវិធីដើម្បីយកជំនះលើសេចក្តីទុក្ខនោះឡើយ។ ជាចុងក្រោយបន្ទាប់ពីចំណាយពេលរៀនសូត្រ៦ព្រះវស្សា មានតែសមាធិទេដែលព្រះអង្គបានពិសោធន៍និងជាមាគ៌ាទំលាយនូវអវិជ្ជាហើយព្រះអង្គបានយល់ពីហេតុនៃសេចក្តីទុក្ខភ្លាមៗ។

ពីពេលនោះរហូតមក គេហៅព្រះអង្គថាព្រះពុទ្ធមានន័យថាអ្នកត្រាស់ដឹង។ ព្រះអង្គចំណាយពេល៤៥ឆ្នាំទៀតដោយព្រះអង្គបានត្រាច់ចរជុំវិញឥណ្ឌាខាងជើងដើម្បីបង្រៀនអ្នកដទៃនូវអ្វីដែលបានរកឃើញ។ ខន្តិធម៌និងករុណាធម៌របស់ព្រះអង្គមានលក្ខណៈជាប្រវត្តិសាស្ត្រហើយព្រះអង្គមានសាវ័ករាប់ពាន់សែននាក់។ ក្នុងព្រះព្រះជន្មាយុ៨០ព្រះវស្សាទោះបីជរានិងព្យាធិក៏ដោយ ក៏ព្រះអង្គមានសេចក្តីសុខនិងសេចក្តីស្ងប់ឈានទៅរកបរិនិព្វានទៅទីបំផុត។

**ប្ុ.** *តើព្រះពុទ្ធជាអាទិទេព(god) ឬ?*

**ឆ្ល.** ទេ, ព្រះពុទ្ធមិនមែនជាអាទិទេពទេ។ ព្រះអង្គមិនដែលអះអាងថាព្រះអង្គជាអាទិទេព ជាបុត្ររបស់អាទិទេព ឬជាអ្នកនាំសាររបស់អាទិទេព។ ព្រះអង្គជាបុរសដែលបានធ្វើអោយបរិបូរដោយព្រះអង្គឯងហើយបង្រៀនថាបើយើងដើរតាមគំរូព្រះអង្គ យើងអាចនឹងបរិបូរដោយខ្លួនយើងផ្ទាល់ផងដែរ ។

**ប្ុ.** *បើព្រះពុទ្ធមិនមែនជាអាទិទេពទេ ចុះហេតុអ្វីប្រជាជនគោរពបូជាព្រះអង្គ?*

**ឆ្ល.** មានវិធីបូជាខុសគ្នាច្រើនយ៉ាង។ ពេលនរណាម្នាក់បូជាអាទិទេពពួកគេកោតសរសើរទេវបុត្រនិងទេវតា សែនសំណែននិងប្រាថ្នាបួងសួង ជឿជាក់ថាអាទិទេពនឹងឮពាក្យសរសើរ ទទួលនូវសំណែននិងតបស្នងនូវពាក្យបួងសួងរបស់គេ។ ពុទ្ធសាសនិកជននឹងមិនទំលើឬផ្តេកផ្តួលទៅតាមការបូជាបែបនេះទេ។ ការបូជាម្យ៉ាងទៀតគឺពេលយើងសំដែងសេចក្តីគោរពចំពោះនរណាម្នាក់ឬវត្ថុអ្វីម្យ៉ាងដែលយើងលើកសរសើរ។ ពេលគ្រូដើរចូលថ្នាក់រៀនយើងក្រោកឈរឡើង ពេលយើងជួបឥស្សរជនណាម្នាក់យើងជំរាបសួរ ពេលភ្លេងជាតិកំពុងបន្លឺងយើងគំនាប់គោរព។ ទាំងអស់នេះគឺកិរិយាបទនៃការគោរពនិងបូជានិងចង្អុលប្រាប់នូវការកោតសរសើររបស់យើងសំរាប់មនុស្សនិងវត្ថុទាំងឡាយ។ នេះជាប្រភេទនៃការបូជាដែលពុទ្ធសាសនិកជនបដិបត្តិ។ ព្រះពុទ្ធបដិមាដែលមានព្រះហស្តដាក់យ៉ាងស្រាលនៅលើភ្លៅនិងស្នាមញញឹមប្រកបដោយករុណាធម៌រំលឹកយើងអោយព្យាយាមអភិវឌ្ឍន៍សុខសន្តិភាពនិងសេចក្តីស្រឡាញ់នៅក្នុងខ្លួនយើង។ ក្លិនក្រអូបរបស់ធូបរំលឹកយើងឱ្យជ្រួតជ្រាបនូវកំឡាំងនៃគុណធម៌,

ភ្លើងទៀនរំលឹកយើងដល់ពន្លឺនៃចំណេះដឹង និងផ្កាដែលស្រស់មួយរំពេចក៏ស្វិតស្រពោនទៅរំលឹកយើងនូវធម៌អនិច្ចំគឺមិនទៀង។ ពេលយើងសំពះ យើងសំដែងនូវការដឹងគុណចំពោះព្រះពុទ្ធសំរាប់អ្វីដែលព្រះអង្គបានបង្រៀននូវសច្ចធម៌ពិតរបស់ព្រះអង្គ។ នេះគឺជាធម្មជាតិធម្មតានៃការគោរពបូជារបស់ពុទ្ធបរិស័ទ។

## ៤. ខ្ញុំបានឮគេនិយាយថាពុទ្ធសាសនិកជនគោរពបូជារូបសំណាក ។

[illegible]. [illegible]ការ[illegible]ប្រៀបនូវការយល់ខុសរបស់មនុស្សដែលធ្វើដូច្នោះ។ វចនា[illegible] *រូបតំណាងរូបបដិមាដែលគេគោរពបូជាដូចជា*[illegible] [illegible]ព្រោះយ៉ាងច្បាស់ថាពុទ្ធសាសនិកជនមិនជឿថាព្រះពុទ្ធជា[illegible] [illegible]ណាត់ឈើឬក៏ដុំដែកជាអាទិទេពឬ?។ សាសនាទាំង[illegible] [illegible]ពាក់និតផ្សេងៗគ្នា។ សាសនាតៅ យិង-យ៉ាំងប្រើ[illegible] [illegible]ជួយគ្នា។ ក្នុងសាសនាសិក ដាវប្រើតំណាងអោយ[illegible]។ ក្នុងសាសនាគ្រីស្ទគ្រីគឺប្រើតំណាងអោយការលះ បង់របស់យេស៊ូ។ ហើយក្នុងព្រះពុទ្ធសាសនាពុទ្ធបដិមាជាការរំលឹកផងដែរ ដល់អាណាចក្ររបស់មនុស្សក្នុងព្រះពុទ្ធវចនៈ នូវសច្ចភាពពិតដែលថាព្រះពុទ្ធសាសនាគឺយកមនុស្សជាធំ មិនមែនយកអាទិទេពជាធំទេនូវអ្វីដែលយើងត្រូវតែសំឡឹងមើលខ្លួនឯងមិនមែនត្រឹមតែស្វែងរកសុក្រឹតភាពនិងការយល់ដឹង។ដូច្នេះ ការនិយាយថាពុទ្ធសាសនិកជនគោរពបូជារូបសំណាកជារឿងមិនត្រឹមត្រូវ។

**ម.** *តើព្រះពុទ្ធសាសនាល្អចុះហេតុអ្វីប្រទេសកាន់ព្រះពុទ្ធសាសនាខ្លះក្រីក្រម្លេះ?*

**ឆ.** ប្រសិនបើភាពក្រីក្រដែលអ្នកនិយាយជាផ្នែកសេដ្ឋកិច្ច វាជារឿងពិតដែលថាប្រទេសកាន់ព្រះពុទ្ធសាសនាខ្លះក្រីក្រមែន។ តែបើភាពក្រីក្រដែលអ្នកនិយាយជាផ្នែកគុណភាពជីវិតពេលនោះប្រហែលជាប្រទេសកាន់ព្រះពុទ្ធសា សនាខ្លះពិតជាមាន។ឧទាហរណ៍ សហរដ្ឋអាមេរិកជាប្រទេសដែលមានខ្លាំងផ្នែកសេដ្ឋកិច្ចហើយមានអំណាចតែកំរិតការប្រព្រឹត្តអាជ្ញាកម្មជាប្រទេសមួយដែលខ្ពស់ជាងគេបង្អស់ក្នុងពិភពលោក មនុស្សចាស់ជរារាប់លាននាក់ត្រូវបានកូនទាំងឡាយបំបរបង់ចោល ហើយស្លាប់យ៉ាងអណោចអធម្មឯកោម្នាក់ឯងក្នុង ផ្ទះជនជរា ចំណែកអំពើហឹង្សានិងការប្រព្រឹត្តបំពានលើក្មេងជាបញ្ហាធំបំផុត។ ចុងក្រោយនៃជីវិតអាពាហ៍ពិពាហ៍មួយក្នុងចំណោមបីគឺការលែងលះគ្នា ហើយមានបង្ហាញរូបអាសគ្រាមពេញពាស។ មានក្នុងលក្ខ័ណ្ឌលុយកាក់ តែប្រហែលជាក្រក្នុងលក្ខ័ណ្ឌនៃគុណភាពជីវិត។

ឥឡូវនេះបើអ្នកក្រឡេកមើលប្រទេសដែលប្រកាន់ខ្ជាប់នឹងព្រះពុទ្ធសាសនាខ្លះ អ្នកនឹងជួបប្រទះនូវទិដ្ឋភាពខុសគ្នាយ៉ាងខ្លាំង។ ឪពុកម្តាយជាទេវបុគ្គលដែលបុត្រធីតាត្រូវគោរពកោតខ្លាច អាត្រារអាជ្ញាកម្មមានកំរិតទាបបំផុតការលែងលះប្តីប្រពន្ធនិងអត្តឃាតកម្រនឹងមានហើយតំលៃខាងប្រពៃណីទំនៀមទំលាប់ដូចជាភាពទន់ភ្លន់ សន្តានចិត្តល្អ ការទទួលរាក់ទាក់ចំពោះអ្នកខាងក្រៅ ការអត់ធន់ និងគារវកិច្ចចំពោះអ្នកដទៃ នៅតែបដិបត្តិយ៉ាងម៉ឺងម៉ាត់។ និយាយតាមសេដ្ឋកិច្ចអាចមានការថយក្រោយ តែគុណភាពជីវិតប្រហែលជាខ្ពង់ខ្ពស់ជាងបើប្រៀបធៀបជាមួយសហរដ្ឋអាមេរិកជាដើម។

តែទោះបីជាយ៉ាងណាក៏ដោយបើយើងកាត់សេចក្តីអោយបានច្បាស់ចំពោះប្រទេសដែលកាន់ព្រះពុទ្ធសាសនាក្នុងរឿងសេដ្ឋកិច្ចតែម្យ៉ាង ប្រទេសមួយដែលមានអត្រាការធំធាត់

ខាងសេដ្ឋកិច្ចនិងមានជាងគេបង្អស់ក្នុងពិភពលោកបច្ចុប្បន្នគឺប្រទេសជប៉ុនដែលប្រជាជន៩៧ភាគរយហៅខ្លួនឯងថាជាពុទ្ធបរិស័ទ ។

ឬ. *បើដូច្នោះចុះហេតុអ្វីយើងមិនដែលឮជាញឹកញាប់ទេអំពីកម្មវិធីសង្គ្រោះសង្គមពីក្រុមសាសនិកជនទាំងឡាយ?*

ទ. ប្រហែលព្រោះថាពុទ្ធសាសនិកជនហាក់បីដូចមិនចង់លើកតំកើងអំពើល្អដែលគេធ្វើ។ ច្រើនឆ្នាំកន្លងទៅហើយ មេដឹកនាំព្រះពុទ្ធសាសនាជនជាតិ ជប៉ុនឈ្មោះនិកក្យូ ណីវ៉ាណូ បានទទួលរង្វាន់ទីមផ្លេតុនសំរាប់កិច្ចការលើកកំ ពស់សាមគ្គីធម៌ផ្ទៃក្នុងសាសនា។ ដូចគ្នាដែរ ព្រះភិក្ខុសង្ឃថៃពេលថ្មីៗនេះបានទទួលរង្វាន់ម៉ែកសៃសៃដែលគួរអោយកោតសរសើរសំរាប់សេចក្តីសំរេចដ៏ខ្ពង់ខ្ពស់ទូវរឿងកំណាត់ថ្នាំញៀនរបស់ព្រះអង្គ។

ក្នុងឆ្នាំ១៩៨៧ ភិក្ខុសង្ឃថៃមួយអង្គទៀតឈ្មោះព្រះតេជគុណខន្តិយពិ វ៉ាត់ បានទទួលរង្វាន់សន្តិភាពក្មេងរបស់ណ័រវេ សំរាប់ការងារច្រើនឆ្នាំរបស់ព្រះអង្គក្នុងការជួយក្មេងអនាថាក្នុងតំបន់ដាច់ស្រយាល។ ហើយចុះអំពីគំរោងកិច្ចការសង្គមដ៏ធំសំរាប់បំរើជនក្រីក្រឥណ្ឌាដែលដំណើរការដោយក្រុមព្រះភិក្ខុសង្ឃមកពីប្រទេសអ៊ឺរ៉ុប?។ ពួកគេបានកសាងសាលារៀនមជ្ឈមណ្ឌលលើកកំពស់ស្មារតីក្មេង អគារឱសថាល័យនិងរោងចក្រឧស្សាហកម្មខ្នាតតូចសំរាប់លើកស្ទួយគុណភាពជីវិតពួកគេ។ ពុទ្ធសាសនិកជនមើលឃើញការធ្វើទានដល់អ្នកដទៃជាការសំដែងការបដិបត្តិខាងផ្លូវសាសនារបស់ខ្លួនដូចគ្នានឹងការបដិបត្តិរបស់សាសនាដទៃ តែពួកគេគិតថាវាត្រូវតែធ្វើដោយសទ្ធាហើយ មិនលើកតំកើងខ្លួនឯង។ ដូច្នេះអ្នកនឹងមិនឮច្រើនអំពីកិច្ចការធ្វើបុណ្យទានរបស់ពួកគេ។

**សុ.** *ហេតុអ្វីបានជាមានព្រះពុទ្ធសាសនានិកាយផ្សេងៗគ្នាច្រើនម្លេះ?*

**ទិ.** មានស្ករប្រភេទផ្សេងៗជាច្រើន ដូចជាស្ករក្រហម ស្ករស ស្ករដុំ ស្ករទឹកស៊ីរ៉ូ និងស្ករលាបកាហ្វេ តែទាំងអស់នោះគឺជាស្ករហើយវាមានរស់ជាតិផ្អែមដូចគ្នា។ វាត្រូវបានផលិតចេញពីទំរង់ផ្សេងៗគ្នា ដូច្នេះវាក៏អាចប្រើបានច្រើនយ៉ាងផ្សេងពីគ្នាដែរ។ព្រះពុទ្ធសាសនាក៏ដូចគ្នាដែរគឺមាននិកាយ<u>ថេរវាទ</u> និកាយ<u>ហ្សេន</u> និកាយ<u>សុខាវតី</u> និកាយ<u>យោគៈ</u> និងនិកាយ<u>វជិរញ្ញាណ</u> តែនិកាយទាំងអស់នេះគឺព្រះពុទ្ធសាសនា ហើយមានរសជាតិតែមួយដូចគ្នាគឺ រសជាតិនៃការអស់ទៅនូវសេចក្តីទុក្ខទាំងពួង។

ព្រះពុទ្ធសាសនាបានវិវត្តន៍ជាទំរង់ផ្សេងៗគ្នា ដូច្នេះព្រះពុទ្ធសាសនាអាចសំរបជាមួយវប្បធម៌ផ្សេងៗគ្នាដែលមានរួចមកហើយ។ ព្រះពុទ្ធសាសនាបានសំរបសំរួលសាចុះសាឡើងច្រើនសតវត្សន៍ដែលអាចស្ថិតស្ថេរសំរបជាមួយនឹងអនុជនជំនាន់ថ្មីជាបន្តបន្ទាប់។ បើមើលពីខាងក្រៅឃើញថាព្រះពុទ្ធសាសនាមាននិកាយច្រើនដែលហាក់ដូចជាខុសគ្នាតែមជ្ឈិត្តិកនៃនិកាយទាំងអស់នោះគឺ អរិយសច្ច៤និងអរិយមគ្គប្រកបដោយអង្គ៨។ សាសនាធំៗរួមទាំងព្រះពុទ្ធសាសនាបានបែកខ្ញែកជាក្រុមនិងនិកាយ។ តែនិកាយផ្សេងៗគ្នារបស់ព្រះពុទ្ធសាសនាមិនដែលបង្កអោយមានសង្គ្រាមរវាងគ្នាឡើយហើយរហូតមកដល់បច្ចុប្បន្ននិកាយសាសនាទាំងអស់នោះនៅតែទៅមករកគ្នារវាងវត្តនិងវត្តនិងមានការបដិបត្តិសាសនពិធីរួមគ្នា។ ខន្តិធម៌និងការយោគយល់គ្នាដូច្នេះគឺកម្រនឹងរកបានណាស់ ។

**សុ.** *តើព្រះពុទ្ធសាសនាមានលក្ខណៈជាវិទ្យាសាស្ត្រទេ?*

**ទិ.** មុននឹងឆ្លើយនូវសំណួរនេះវាជាការប្រសើរណាស់ដើម្បីកំណត់និយមន័យពាក្យវិទ្យាសាស្ត្រ។ តាមវចនានុក្រមវិទ្យាសាស្ត្រមានន័យថា *ចំណេះ*

*នឹងដែលអាចបង្កើតជាប្រព័ន្ធដែលអាស្រ័យកត្តាពិតដែលអាចពិសោធន៍ និង ឃើញច្បាស់បាន ហើយថ្លែងទៅតាមច្បាប់ធម្មជាតិទូទៅ ជាសាខាចំណេះដឹងម្យ៉ាងដែលអាចសិក្សានូវសភាវៈពិតបាន។* មានទ្រឹស្តីខ្លះរបស់ព្រះពុទ្ធសាសនា ដែលមិនសមស្របទៅតាមនិយមន័យនេះ តែពាក្យប្រៀនប្រដៅដែលសំខាន់ បំផុតរបស់ព្រះពុទ្ធសាសនាគឺអរិយសច្ច៤ដែលមានលក្ខណៈជាវិទ្យាសាស្ត្រខ្លាំងបំផុត។

**អរិយសច្ចៈទី១**សេចក្តីទុក្ខគឺការពិសោធន៍ដែលយើងអាចកំណត់និយមន័យ ធ្វើការពិសោធន៍និងវាស់វែងបាន។ **អរិយសច្ចៈទី២**បង្ហាញថាសេចក្តីទុក្ខមានសាហេតុតាមធម្មជាតិ គឺសេចក្តីចង់បានដែលជាហេតុអាចកំណត់និយមន័យធ្វើការពិសោធន៍និងវាស់ទំហំបាន។ គេមិនអាចបង្កើនការព្យាយាមពន្យល់សេចក្តីទុក្ខទៅនឹងគំនិតខាងបរមត្ថទស្សនវិជ្ជាឬទេវកថាទេ។ យោងតាម**អរិយសច្ចៈទី៣**សេចក្តីទុក្ខនឹងអាចបំបាត់បានដោយមិនអាស្រ័យទៅលើសភាវៈអស្ចារ្យណាមួយ ដោយជំនឿ ឬដោយការអធិស្ឋានបួងសួង តែសាមញ្ញបំផុតដោយការកំចាត់នូវសាហេតុរបស់វាចោល។ នេះគឺឃើញជាក់ច្បាស់ដោយខ្លួនឯង **អរិយសច្ចៈទី៤**គឺមាគ៌ាទៅរកការរំលត់នូវទុក្ខ ជាថ្មីម្តងទៀតជាគោលការណ៍ ដែលមិនអាស្រ័យបរមត្ថទស្សនវិជ្ជាទាល់តែសោះ តែអាស្រ័យលើការបដិបត្តិត្រូវ ហើយបើកទូលាយសំរាប់អ្នកបដិបត្តិពិសោធន៍មើលម្តងហើយម្តងទៀត។ ព្រះពុទ្ធសាសនាមិនទទួលស្គាល់នូវគំនិតជឿលើសភាវៈអស្ចារ្យដូចគ្នានឹងវិទ្យាសាស្ត្រដែរ ហើយពន្យល់នូវសាហេតុនិងបាតុភូតរបស់ចក្រវាឡ ដោយសំអាងលើច្បាប់ធម្មជាតិ។ទាំងអស់នេះឈរនៅលើការបង្ហាញនូវចិត្តវិញ្ញាណនៃវិទ្យាសាស្ត្រ។ បន្ថែមលើនេះទៀតពាក្យទូន្មានជាញឹកញាប់របស់ព្រះពុទ្ធដែលមិនអោយយើងជឿទាំងងងឹតងងល់ តែគួរចោទសួរខ្លះ ត្រួតពិនិត្យ ស៊ើបអង្កេត និងសំអាងលើការពិសោធន៍ដោយខ្លួនឯង ដោយមានបន្ទីរោទិ៍ទ្រឹស្តីវិទ្យាសាស្ត្រនិយាយថា *'ចូរកុំបណ្តោយខ្លួនជឿទៅតាមការ*

*ប្រកាសដំណឹងល្អឬទំនៀមទំលាប់,ចូរកុំបណ្តោយខ្លួនជឿទៅតាមពាក្យចចាមអារាម ឬតម្រិះ សក្តិសិទ្ធ កុំបណ្តោយខ្លួនជឿទៅតាមពាក្យបំផ្លើសឬគ្រាន់តែតក្កៈ កុំបណ្តោយខ្លួនជឿទៅតាមភាពអគតិតាមការសង្កេតឬដោយសមត្ថភាពដែលសំដែងចេញរបស់មនុស្ស និងកុំបណ្តោយខ្លួនជឿទៅតាមគំនិតថាគាត់ជាគ្រូរបស់យើង។ តែបើនៅពេលខ្លួនអ្នកផ្ទាល់ដឹងថាវត្ថុនេះល្អដែលមិនអាចបំភាន់បាន ដែលលើកសរសើរដោយបណ្ឌិត ហើយពេលបានបដិបត្តិនឹងសង្កេតឃើញថាវានាំទៅរកសេចក្តីសុខ ដូច្នេះចូរបណ្តោយខ្លួនជឿតាមវត្ថុនោះចុះ។* ដូច្នេះយើងអាចនិយាយថា ថ្វីបើព្រះពុទ្ធសាសនាមិនមែនជាវិទ្យាសាស្ត្រទាំងស្រុង តែតាមសេចក្តីពិតគឺមានសំលេងជាវិទ្យាសាស្ត្រខ្លាំងហើយមានលក្ខណៈជាវិទ្យាសាស្ត្រជាងសាសនាដទៃ។ វាជាការឆ្លុះបញ្ចាំងយ៉ាងច្បាស់ថាលោកអាល់បើតអែស្តាញជាអ្នកវិទ្យាសាស្ត្រដ៏ល្បីល្បាញម្នាក់ក្នុងសតវត្សន៏ទី២០និយាយអំពីព្រះពុទ្ធសាសនាថា *"សាសនានៃអានាគតគឺជាសាសនាសាកល។ អាចពុះពារជំនះលើវត្ថុមានអាទិទេព្យនិងជៀសផុតពីគំនិតទិដ្ឋិនិយមនិងទេវវិទ្យា។ គ្របដណ្តប់ទាំងសភាវៈធម្មជាតិ និងចិត្តវិញ្ញាណវាអាចមានគោលជំហរលើវិញ្ញាណខាងសាសនា ដែលផុសឡើងពីបទពិសោធន៏លើវត្ថុទាំងអស់ទាំងធម្មជាតិនិងចិត្តវិញ្ញាណនិងកត្តារួមដ៏ជាក់លាក់។ បើមានសាសនាណាមួយអាចគ្រប់គ្រងលើតំរូវការរបស់វិទ្យាសាស្ត្រសម័យទំនើបថ្មីនោះបាន គឺព្រះពុទ្ធសាសនា។*

# ភាគ ២

# គោលគំនិតជាមូលដ្ឋានរបស់ព្រះពុទ្ធសាសនា

**ប្ុ.** *តើខ្លឹមសារសំខាន់នៃពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធគឺអ្វី?*

**ទ.** ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ទាំងអស់មានអរិយសច្ច៤ជាស្នូល ដូចគ្នានឹងខ្នងកង់និងកាំកង់មានដុំកង់ជាស្នូល។ គេហៅថាបួនពីព្រោះមានបួនក្នុងចំណោមស្នូលទាំងនោះ។ គេហៅថាអរិយៈពីព្រោះគេចង់លើកកំពស់បុគ្គលណាយល់នូវធម៌ទាំងបួននោះ ហើយគេហៅថាសច្ចៈពីព្រោះជាសេចក្ដីពិតនិងអោបក្រសោបជាមួយសេចក្ដីពិតជានិច្ច។

**ប្ុ.** *តើអរិយសច្ចទី១គឺអ្វី?*

**ទ.** អរិយសច្ចទី១គឺជីវិតដែលប្រទះតែសេចក្ដីទុក្ខ។ ដើម្បីមានជីវិតអ្នកច្បាស់ជាមានទុក្ខ។ វាមិនអាចប្រព្រឹត្តទៅបានដែលថាជីវិតរស់នៅមិនដែលប្រឈមមុខនឹងសេចក្ដីទុក្ខនោះ។ យើងត្រូវតែឆ្លងកាត់សេចក្ដីទុក្ខខាងផ្លូវកាយដូចជាឈឺ របួស ការនឿយហត់ ចាស់ជរានិងសេចក្ដីស្លាប់នៅទីបញ្ចប់ ហើយយើងត្រូវតែឆ្លងកាត់សេចក្ដីទុក្ខខាងផ្លូវចិត្តដូចជាភាពឯកោឯកាការព្រួយកង្វល់ ការភិតភ័យ ការខ្ជាញខ្ពើរ ការអស់សង្ឃឹម និងសេចក្ដីខឹងជាដើម។

**ប្ុ.** *តើនេះមិនមែនជាលក្ខណៈទុទិដ្ឋិនិយមឬ?*

**ទ.** វចនានុក្រមអោយនិយមន័យទុទិដ្ឋិនិយមថា *ការចំលាប់គិតដែលទោរទន់ទៅលើអ្វីដែលអាក្រក់នឹងកើតឡើងឬ ជំនឿដែលថាអំពើអាក្រក់មានឥទ្ធិពលជាងអំពើល្អ។* ព្រះ

ពុទ្ធសាសនាមិនបានបង្រៀនគំនិតទាំងអស់នោះទេ។ តែក៏មិនបដិសេធថាសេចក្ដីសុខមិនមាន នោះដែរ។ ព្រះពុទ្ធសាសនានិយាយយ៉ាងសាមញ្ញថាដើម្បីមានជីវិតគឺដើម្បីពិសោធន៍នូវសេចក្ដីទុក្ខទាំងផ្លូវកាយនិងផ្លូវចិត្តដែល គេមិនអាចបដិសេធដោយការអធិប្បាយអោយងាយយល់នោះ។ គោលគំនិតសំខាន់នៃសាសនាភាគច្រើនគឺទេវកថា រឿងព្រេង ឬជំនឿដែលពិបាក ឬក៏មិនអាចពន្យល់បញ្ជាក់បាន។ ព្រះពុទ្ធសាសនាចាប់ផ្ដើមពីការធ្វើបទពិសោធន៍មួយជាហេតុការណ៍ពិតដែលមិនអាចថ្កោងបន្ដិចបានជាវត្ថុមួយដែលអ្នកទាំងអស់គ្នាស្គាល់មកពីការបានធ្វើការពិសោធន៍និងកំពុងព្យាយាមវាយទំលុះអោយបាន។ ដូច្នេះព្រះពុទ្ធសាសនាជាសាសនាសាកលដ៏ពិតពីព្រោះបានជ្រៀតចូលទៅក្នុងភាពត្រឹមត្រូវនៃសារត្ថៈរបស់បច្ចេកបុគ្គលម្នាក់ៗគ្រប់ទាំងអស់ជាមួយនឹងសេចក្ដីទុក្ខនិងវិធីដើម្បីពន្លត់ទុក្ខបាន។

**ម.** *តើអរិយសច្ចទី២គឺអ្វី?*

**ត.** អរិយសច្ចទី២គឺសេចក្ដីទុក្ខទាំងអស់មានសាហេតុមកពីតណ្ហា។ ពេលយើងសំឡឹងមើលសេចក្ដីទុក្ខខាងផ្លូវចិត្តយើងឃើញយ៉ាងងាយនូវតណ្ហាដែលជាសាហេតុនៃសេចក្ដីទុក្ខ។ពេលយើងត្រូវការវត្ថុខ្លះតែមិនបានដូចបំណង យើងនឹងព្រួយកង្វល់។ ពេលយើងសង្ឃឹមថាមាននរណាម្នាក់មករកយើងតែគេមិនបានមក យើងហាក់ដូចជាអស់កំឡាំងកំហែងនិងអស់សង្ឃឹម។ ពេលយើងចង់អោយអ្នកដទៃដូចយើងតែវាមិនដូច យើងនឹងឈឺចុកចាប់។ទោះបីពេលយើងចង់បានអ្វីមួយហើយយើងអាចបានរបស់នោះ ក៏មិនបាននាំសេចក្ដីសុខមកអោយយើងគ្រប់ពេលផងដែរពីព្រោះមិនយូរប៉ុន្មានយើងហាក់ដូចជាធុញទ្រាន់ជាមួយវត្ថុនោះ បាត់ចំណូលចិត្តចំពោះវត្ថុនោះហើយចាប់ផ្ដើមប្រាថ្នាចង់បានវត្ថុដទៃផ្សេងៗទៀត។ និយាយអោយសាមញ្ញ គឺថាអរិយសច្ចទី២និយាយថាបានអ្វីក៏ដោយដែលអ្នកត្រូវការក៏មិនធានាដល់សេចក្ដីសុខឡើយ។ ទោះ

បីការតស៊ូជាបន្តបន្ទាប់ដើម្បីទទួលបាននូវអ្វីដែលអ្នកចង់បាន   ព្យាយាមធ្វើអោយបាននូវចំណង់របស់អ្នក។  តណ្ហាដកហូតពីយើងនូវភាពស្ងប់ចិត្ត  និងសេចក្តីសុខ។

**ឋ.** *តែ  តើសេចក្តីត្រូវការនិងតណ្ហានាំយើងទៅរកសេចក្តីទុក្ខខាងផ្លូវកាយយ៉ាងណា?*

**ទិ.** សេចក្តីត្រូវការនិងតណ្ហាសំរាប់វត្ថុនេះវត្ថុនោះមានមិនចេះចប់  ហើយជាពិសេសតណ្ហាស្ថិតនៅជាបន្តបង្កើតជាកំឡាំងដ៏ខ្លាំងក្លាដែលបណ្តាលអោយបុគ្គលម្នាក់ៗកើតហើយកើតទៀត។  ពេលយើងកើតម្តងទៀត  យើងមានខ្លួនប្រាណ  ដូចដែលយើងបាននិយាយរួចមកហើយ  ខ្លួនប្រាណយើងបណ្តាលអោយយើងចុកចាប់និងឈឺគឺវាអាចឡើយហត់ដោយការងារវាចាស់ទៅៗរហូតដល់ទីបំផុតស្លាប់។  ដូច្នេះតណ្ហានាំអោយទុក្ខខាងផ្លូវកាយពីព្រោះវាបណ្តាលអោយយើងចាប់កំណើតម្តងទៀត  ។

**ឋ.** *តែបើយើងបញ្ឈប់ចំណង់គ្រប់បែបយ៉ាងទាំងអស់  យើងនឹងមិនបានសំរេចអ្វីសោះ។*

**ទិ.** ជារឿងពិត។  តែអ្វីដែលព្រះពុទ្ធត្រាស់គឺថាពេលសេចក្តីប្រាថ្នា  សេចក្តីចង់បានការមិនចេះឆ្អែតឆ្អល់ជាបន្តបន្ទាប់របស់យើងជាមួយអ្វីដែលយើងមានហើយនិងការប្រាថ្នាច្រើនហើយច្រើនទៀតមិនចេះចប់ជាហេតុធ្វើអោយមានសេចក្តីទុក្ខ  ពេលនោះយើងគួរតែបញ្ឈប់ធ្វើដូច្នោះ។  វាជាសំណើរដល់យើងថាតើយើងអាចបង្កើតភាពខុសគ្នានូវអ្វីគឺសេចក្តីត្រូវការនិងអ្វីគឺសេចក្តីចង់បាន  ហើយព្យាយាមធ្វើអោយបាននូវតំរូវការរបស់យើងនិងធ្វើអោយស្កប់ស្កល់នូវចំណង់របស់យើង។  ព្រះពុទ្ធអង្គប្រាប់យើងថាសេចក្តីត្រូវការរបស់យើងអាចមានទីបញ្ចប់  តែចំណង់របស់យើងគ្មានព្រំដែនទេ  វាជាប្រហោងដ៏ជ្រៅបំផុត។  មានសេចក្តីត្រូវការជាវត្ថុសំខាន់ជាមូលដ្ឋាននិងគួររក្សាទុក  ហើយយើងគួរបំពេញវាអោយសំរេច។សេចក្តីលោភឬចំណង់

ដែលខ្លាំងហួសហេតុពេកគួរតែកាត់បន្ថយបន្តិចម្តងៗ។ បន្ទាប់ពីនោះ តើអ្វីដែលជាវត្ថុបំណង របស់ជីវិត?។ គិតតែពីប្រមូលផលប្រយោជន៍ឬគ្រាន់តែជាការពេញចិត្តនិងសេចក្តីស្ងប់សុខ!

**ប្**. *តើអរិយសច្ចទី៣គឺអ្វី?*

**ទិ**. អរិយសច្ចទី៣គឺយើងអាចយកជំនះលើសេចក្តីទុក្ខបានហើយសេចក្តីសុខអាចធ្វើបានសំរេច។ នេះអាចពិតជាសារៈសំខាន់បំផុតរបស់អរិយសច្ចទី៤ពីព្រោះចំពោះអរិយសច្ចនេះព្រះពុទ្ធជាម្ចាស់បញ្ជាក់ប្រាប់យើងថាសេចក្តីសុខពិតនិងភាពពេញបរិបូរអាចសំរេចយកបាន។ ពេលយើងបោះបង់ចោលចំណង់ឥតប្រយោជន៍ចេញហើយរៀនស្ងូត្រក្នុងការរស់នៅពីមួយថ្ងៃទៅមួយថ្ងៃ រីករាយចិត្តដោយមិនចាំបាច់មានចំណង់គ្មានឈប់ឈរដែលជាបទពិសោធន៍ពិតរបស់ជីវិតបន្តការងារដោយការអត់ធន់នូវបញ្ហាដែលទាក់ទងជីវិត ដោយគ្មានសេចក្តីភ័យខ្លាច សេចក្តីខឹងនិងក្រេវក្រោធ ពេលនោះយើងនឹងបានជាអ្នកមានសេចក្តីសុខនិងរំដោះរួចពីទុក្ខទាំងពួង។ ពេលនោះហើយជាពេលតែមួយដែលយើងចាប់ផ្តើមមានជីវិតយ៉ាងពេញបរិបូរ។ ពីព្រោះយើងមិនចុញចប់អ្វីទៀតឡើយជាមួយនឹងការធ្វើអោយស្កប់ស្កល់នូវចំណង់អត្តភាពផ្ទាល់ខ្លួនរបស់យើង ហើយយើងបានមានពេលច្រើនជាងមុនដើម្បីជួយអ្នកដទៃបំពេញតំរូវការរបស់គេ។ អាណាចក្រនេះគេហៅថាព្រះនិព្វាន។ យើងរំដោះខ្លួនរួចផុតពីសេចក្តីទុក្ខខាងផ្លូវចិត្តបានយ៉ាងពិតប្រាកដ។ នេះគេហៅថាព្រះនិព្វាននៅទីបំផុត។

**ប្**. *ព្រះនិព្វានគឺអ្វី ហើយនៅទីណា?*

**ទិ**. ព្រះនិព្វានជាឋានមួយដែលហួសពីវិស័យនៃពេលវេលា បរិយាកាស និងមិនអាច

អធិប្បាយបានដោយពាក្យសំដីឬដោយគិតរែកញែកវិនិច្ឆ័យបាន។ ពាក្យសំដីនិងគំនិតទាំងឡាយ សមរម្យចំពោះការអធិប្បាយឋានស្រទាប់បរិយាកាសនិងពេលវេលាតែប៉ុណ្ណោះ។តែពីព្រោះព្រះនិព្វានឆ្ងាយផុតពីពេលវេលា ទើបគ្មានចលនា ហើយនឹងគ្មានការចាស់ការស្លាប់ផងដែរ។ ដូច្នេះ និព្វានគឺអមតៈពីព្រោះនិព្វានឆ្ងាយផុតពីស្រទាប់បរិយាកាស គ្មានហេតុបច្ច័យ គ្មានព្រំដែន គ្មានការគិតរឿងតួខ្លួននិងគ្មានខ្លួន ហើយនិព្វាននោះគឺអចិន្ត្រៃយ៍។ ព្រះពុទ្ធជាម្ចាស់បញ្ជាក់ដល់យើងផងដែរថាព្រះនិព្វានគឺការជួបប្រទះនូវសេចក្ដីសុខដ៏ជ្រាលជ្រៅ។ ព្រះអង្គត្រាស់ថា និព្វានគឺជាសេចក្ដីសុខដ៏ឧត្ដម *ធម្មបទ២០៤* ។

ឬ. *តែតើមានភស្តុតាងបញ្ជាក់ពីការមានឋានដូច្នោះពិតប្រាកដមែនឬទេ?*

ច. ទេ មិនមានទេ។ តែសភាវៈពិតរបស់ព្រះនិព្វានគេអាចសន្និដ្ឋានបាន។ បើមានឋានណាមួយដែលពេលវេលានិងបរិយាកាសធ្វើចលនាហើយមានឋាននោះពិតប្រាកដ ឋាននោះគឺពិភពលោកដែលយើងរស់នៅ ពេលនោះយើងក៏អាចសន្និដ្ឋានបានផងដែរថាមានឋានដែលពេលវេលានិងបរិយាកាសមិនធ្វើចលនា ឋាននោះគឺព្រះនិព្វាន។ ដូចគ្នាដែរ ទោះបីយើងមិនអាចបង្ហាញភស្តុតាងថានិព្វានមានពិតមែនតែយើងមានព្រះពុទ្ធវចនៈដែលមាននៅក្នុងគម្ពីរពិតប្រាកដ។ ព្រះអង្គត្រាស់ប្រាប់យើងថា *មិនមានការកើត មិនមានទីជាទីតាំង មិនមានការច្យុតិ មិនមានបច្ច័យតាក់តែង។ បើគ្មានការកើត គ្មានការច្យុតិ គ្មានបច្ច័យតាក់តែង នោះនឹងគ្មានអ្វីបង្កើត ដោយសំអាងលើអ្វីមួយដែលធ្វើអោយកើត មានទីជាទីតាំង មានការច្យុតិ មានបច្ច័យតាក់តែង។ ដូច្នេះតើមានអ្នកណាដឹងអំពីការចេញផុតពីអ្វីដែលជាការកើត ការច្យុតិ ការមានបច្ច័យតាក់តែង?* ឧទាន ៨០ ។

យើងនឹងស្គាល់នូវព្រះនិព្វាននៅពេលណាយើងបានសំរេចនូវធម៌។ នៅពេលណាក៏ដោយ ក៏យើងអាចបដិបត្តិធម៌បានដែរ។

ម្ស. *តើអរិយសច្ចទី៤គឺអ្វី?*

ទិ. អរិយសច្ចទី៤គឺផ្លូវនាំទៅរកការឈ្នះនូវទុក្ខទាំងពួង។ ផ្លូវនេះគេហៅថាអរិយមគ្គប្រកបដោយអង្គ៨ ហើយមានអង្គប្រកបដូចតទៅនេះ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ និងសម្មាសមាធិ។ ការបដិបត្តិរបស់ពុទ្ធបរិស័ទមានគ្រប់អង្គទាំង៨នេះ រហូតដល់ពួកគេអាចសំរេចធម៌តាមលំដាប់បាន។ អ្នកអាចសង្កេតឃើញថាជាន់ថ្នាក់នៃអរិយមគ្គប្រកបដោយអង្គ៨គ្របដណ្តប់ទៅលើបញ្ហាគ្រប់បែបយ៉ាងរបស់ជីវិត ដូចជាបញ្ហាសតិបញ្ញា បញ្ហាចរិយធម៌ បញ្ហាសេដ្ឋកិច្ច បញ្ហាផ្លូវចិត្ត និងមិនតែប៉ុណ្ណោះនៅមានវត្ថុគ្រប់យ៉ាងដែលមនុស្សត្រូវការដើម្បីធ្វើអោយជីវិតបានល្អប្រសើរ និងអភិវឌ្ឍន៍ចិត្តវិញ្ញាណបាន ។

# ភាគ ៣

# ព្រះពុទ្ធសាសនាជាមួយនឹងគំនិតបូជាអាទិទេព

**បុ.** *តើពុទ្ធសាសនិកជនជឿលើអាទិទេពទេ?*

**ទំ.** ទេ!យើងមិនជឿទេ។មានហេតុផលច្រើនយ៉ាងអំពីរឿងនេះ។ ព្រះពុទ្ធជាម្ចាស់ប្រដូចជាអ្នកសង្គមវិទ្យានិងចិត្តវិទ្យាសម័យថ្មី ដែលជឿថាគំនិតខាងសាសនាហើយជាពិសេសជំនឿលើអាទិទេពមានប្រភពរបស់វាមកពីសេចក្ដីភ័យខ្លាច។ ព្រះពុទ្ធជាម្ចាស់ត្រាស់ថា *ភ័យមកដល់ មនុស្សទាំងឡាយយកភ្នំជាទីពឹងខ្លះ យកដំបូកជាទីពឹងខ្លះ យកដើមឈើ និងយកចេតិយ៍ជាទីពឹងខ្លះ។* ទីឃនិកាយ ១៨៨

មនុស្សជំនាន់ដើមកសាងខ្លួនឯងក្រោមពិភពលោកនៃគ្រោះថ្នាក់ និងការខ្លាចរអាភ័យខ្លាចសត្វព្រៃកំណាច មិនអាចរកអាហារហូបចុកគ្រប់គ្រាន់ ការឈឺចាប់ឬជំងឺផ្សេងៗហើយនឹងអព្ភូតហេតុខាងធម្មជាតិដូចជាផ្គរលាន់ រន្ទះបាញ់និងភ្នំភ្លើងផ្ទុះ ជានិច្ចជាកាលកើតឡើងដល់ពួកគេ។ ដោយពុំអាចរកសុវត្ថិភាពអ្វីផ្សេងបាន ពួកគេក៏បានបង្កើតគំនិតជឿលើអាទិទេពឡើងក្នុងគោលបំណងអោយគេបានសុខសប្បាយនៅពេលណាល្អ បន់ស្រន់អាទិទេពពេលជួបគ្រោះថ្នាក់និងការបំពេរអារម្មណ៍ពួកគេពេលអ្វីគ្រប់យ៉ាងខុសពីប្រក្រតី។ សព្វថ្ងៃនេះអ្នកអាចសង្កេតឃើញថាមនុស្សនឹងជឿលើអាទិទេពកាន់តែខ្លាំងនៅពេលណាជួបវិបត្តិ អ្នកនឹងឮពួកគេនិយាយថាគេជឿទៅលើឯកាទិទេពឬពហុអាទិទេពដែលជួយពង្រឹងតំរូវការពួកគេដើម្បីដោះស្រាយបញ្ហាជីវិត។ អ្នកនឹងឮពួកគេនិយាយពន្យល់យើងថា ពួកគេជឿលើអាទិទេពតែមួយអង្គគត់ព្រោះពួកគេបួងសួងពេលណាគេធ្លាក់ខ្លួនលំបាកហើយការបួងសួងរបស់គេត្រូវបានសំរេច។ ទាំងអស់នេះហាក់ដូចជាគាំទ្រពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែលត្រាស់ថាមនុស្សនះជឿ

អាទិទេពគឺមកពីសេចក្តីខ្លាចនិងសេចក្តីមិនទុកចិត្តខ្លួនឯង។ ព្រះពុទ្ធជាម្ចាស់បង្រៀនយើងអោយព្យាយាមសិក្សាអោយយល់អំពីសេចក្តីភ័យខ្លាចរបស់ខ្លួនឯង កាត់បន្ថយសេចក្តីលោភលន់និងទទួលយកនូវវត្ថុទាំងឡាយដែលយើងមិនអាចផ្លាស់ប្តូរបានដោយភាពស្ងប់ស្ងៀមនិងក្លាហាន។ ព្រះអង្គបំបាត់សេចក្តីខ្លាចមិនមែនដោយជំនឿគ្មានហេតុផលទេ តែដោយសេចក្តីយល់ដឹងដែលប្រកបដោយហេតុផល។

<u>ហេតុផលទី២</u>ដែលព្រះពុទ្ធអង្គមិនសង្ស័យលើអាទិទេពពីព្រោះហាក់ដូចជាគ្មានអ្វីដែលជាភស្តុតាងគាំទ្រនូវគំនិតនេះ។ មានសាសនាជាច្រើន ដែលអះអាងថាសាសនារបស់ពួកគេតែមួយគត់ដែលពាក្យពិតរបស់ព្រះជាម្ចាស់រក្សាបានល្អក្នុងគម្ពីរសក្តិសិទ្ធិរបស់គេមានតែគេម្នាក់គត់យល់នូវធម្មជាតិរបស់អាទិទេព ដែលព្រះរបស់គេមានពិតតែព្រះរបស់សាសនាអ្នកដទៃមានមិនពិតទេ។ អ្នកខ្លះពោលថាអាទិទេពគឺជាភេទប្រុស អ្នកខ្លះថាអាទិទេពជាភេទស្រី និងអ្នកខ្លះទៀតពោលថាអាទិទេពជាអភេទ។ ពួកគេពេញចិត្តថានេះគឺជាភស្តុតាងគ្រប់គ្រាន់ដើម្បីបញ្ជាក់នូវការមានពិតនៃអាទិទេពរបស់ពួកគេ តែពួកគេសើចចំអកនូវការជឿខុសចំពោះភស្តុតាងរបស់សាសនាដទៃ ដែលអធិប្បាយបញ្ជាក់នូវភាពមានពិតនៃអាទិទេពអង្គផ្សេងទៀត។ វាមិនគួរអោយភ្ញាក់ផ្អើល ជាមួយនឹងសាសនាផ្សេងៗគ្នាជាច្រើនចំណាយពេលមកច្រើនសតវត្សន៍ក្នុងការព្យាយាមបង្ហាញភស្តុតាងវត្តមានពិតនៃអាទិទេពទាំងឡាយរបស់ពួកគេដែលនៅតែមិនពិត មិនឃើញជារូបធម៌ រកមិនឃើញនូវភស្តុតាងដែលគួរអោយជឿទុកចិត្តនិងជាវិជ្ជមាន។ ពុទ្ធបរិស័ទនៅមន្ទិលសង្ស័យការសំរេចចិត្តដូច្នេះ ទាល់តែភស្តុតាងពិតប្រាកដត្រូវបានគេយកមកបង្ហាញបញ្ជាក់ ។

<u>ហេតុផលទី៣</u> ព្រះពុទ្ធជាម្ចាស់មិនជឿលើអាទិទេពព្រោះថាជំនឿនោះគឺមិនចាំបាច់

អ្នកខ្លះពន្យល់ថាជំនឿលើអាទិទេពគឺចាំបាច់ក្នុងគោលបំណងដើម្បីពន្យល់ប្រភពដើមនៃចក្រវាឡ តែបញ្ហានេះវាមិនពិតដូច្នោះទេ។វិទ្យាសាស្ត្របានពន្យល់យ៉ាងច្បាស់នូវវិធីដែលចក្រវាឡបានកើតជាសភាវៈដោយមិនចាំបាច់មានការទទួលស្គាល់ពីទ្រឹស្តីអាទិទេព។ អ្នកខ្លះអះអាងថាជំនឿលើអាទិទេពគឺចាំបាច់ធ្វើអោយជីវិតសុខសប្បាយនិងមានន័យ។ ដូចគ្នាដែរយើងអាចឃើញថាមិនមែនដូច្នេះឡើយ។ មានអ្នកមិនជឿអាទិទេពនិងអ្នកគិតឥស្សរៈរាប់លាននាក់ដោយមិននិយាយដល់ពុទ្ធសាសនិកជនផង ដែលរស់នៅយ៉ាងមានប្រយោជន៍ មានសេចក្តីសុខ និងមានន័យដោយគ្មានជំនឿទៅលើអាទិទេពទាល់តែសោះ។

អ្នកខ្លះអះអាងថាជំនឿលើអំណាចអាទិទេពគឺចាំបាច់ពីព្រោះមនុស្សលោក ជាអ្នកទន់ខ្សោយមិនមានកំឡាំងគ្រប់គ្រាន់ដើម្បីជួយខ្លួនឯង។ ដូចគ្នាដែរ ភស្តុតាងបានចង្អុលប្រាប់ផ្ទុយគ្នាស្រឡះ។ ជាញឹកញាប់យើងឃើញមនុស្សដែលបានជំនះលើអសមត្ថភាពនិងវិកលវិការការទាស់ទែងនិងផលវិបាកធំៗបាន តាមរយៈធនធានផ្ទៃក្នុងផ្ទាល់របស់ពួកគេ តាមរយៈសេចក្តីព្យាយាមផ្ទាល់របស់ពួកគេនិងដោយគ្មានជំនឿលើអាទិទេពសោះ។ អ្នកខ្លះអះអាងថាព្រះអាទិទេពគឺចាំបាច់ដើម្បីនាំមនុស្សទៅរកឥស្សរភាព។ តែការជជែកគ្នាដូច្នេះចាត់ថាល្អបានប្រសិនបើអ្នកទទួលស្គាល់យកទ្រឹស្តីឥស្សរភាពបែបទេវវិទ្យា ហើយពុទ្ធសាសនាមិនទទួលយកនូវទ្រឹស្តីដូច្នោះទេ។ សំអាងលើបទពិសោធន៍របស់ព្រះអង្គផ្ទាល់ព្រះពុទ្ធជាម្ចាស់បានមើលឃើញថាមនុស្សលោកម្នាក់ៗមានសមត្ថភាពដើម្បីសំអាតចិត្ត អភិវឌ្ឍន៍ករុណាធម៌និងមេត្តាធម៌ឥតព្រំដែនព្រមទាំងការត្រាស់ដឹងយ៉ាងបរិបូរ។ ព្រះអង្គពង្រីកការយកចិត្តទុកដាក់ចាប់ពីឋានសួគ៌ាវហូតដល់បេះដូង ហើយលើកទឹកចិត្តយើងអោយស្វែងរកដំណោះស្រាយទាំងឡាយដើម្បីប្រឈមមុខនឹងបញ្ហាទាំងឡាយតាមរយៈការត្រាស់ដឹងដោយខ្លួនឯង។

**ឬ.** *តែបើគ្មានអាទិទេពទេ តើចក្រវាឡកើតឡើងនៅទីនេះបានយ៉ាងណា?*

**ទិ.** សាសនាទាំងអស់ មានរឿងនិទាននិងរឿងរ៉ាវដែលព្យាយាមឆ្លើយនូវសំណួរនេះ។ ក្នុងសម័យបុរាណពេលគេមិនដឹងរឿងដែលសាមញ្ញៗគេក៏លើកតំកើងរឿងព្រេងនេះឡើង តែក្នុងសតវត្សន៍ទី២០ ជាយុគសម័យនៃរូបវិទ្យា តារាសាស្ត្រនិងធរណីវិទ្យា រឿងព្រេងទាំងនោះត្រូវបានជំនួសដោយរឿងពិតនៃវិទ្យាសាស្ត្រ។ វិទ្យាសាស្ត្របានពន្យល់កំណើតនៃចក្រវាឡ ដោយមិនសំអាងទៅលើប្រភពដើមនៃទស្សនះជឿលើអាទិទេពឡើយ ។

**ឬ.** *តើព្រះពុទ្ធត្រាស់ថាដូចម្តេចអំពីកំណើតរបស់ចក្រវាឡ?*

**ទិ.** វាជារឿងគួរអោយចាប់អារម្មណ៍ដែលពាក្យពន្យល់ណែនាំរបស់ព្រះពុទ្ធអំពីកំណើតនៃចក្រវាឡទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងទស្សនះវិទ្យាសាស្ត្រ។ ក្នុងគម្ពីរអគ្គញ្ញសូត្រ ព្រះពុទ្ធជាម្ចាស់អធិប្បាយថាលោករបស់យើងត្រូវបានបំផ្លាញ ហើយវិវត្តន៍កើតឡើងវិញក្នុងទំរង់បច្ចុប្បន្ននេះ ឆ្លងកាត់ថេរៈវេលារាប់លានលានឆ្នាំ។ ជីវិតដំបូងក៏បានករកើតឡើងនៅលើទឹក ហើយវិលទៅអស់វេលារាប់លានលានឆ្នាំទៀតក៏បានវិវត្តពីទំរង់ជីវិតដែលសាមញ្ញទៅជាអវយវះដែលស្មុគស្មាញ។ ការវិវត្តន៍ទាំងនេះគឺមិនមានចំណុចចាប់ផ្តើមនិងចំណុចទីបញ្ចប់ឡើយ ហើយផ្លាស់ប្តូរទៅតាមទំរង់ហេតុបច្ច័យរបស់ធម្មជាតិ ។

**ឬ.** *អ្នកនិយាយថាគ្មានភស្តុតាងការមានអាទិទេពពិតប្រាកដ។ ចុះអំពីអព្ភូតហេតុទាំងឡាយ?*

**ទិ.** មានមនុស្សជាច្រើនជឿថាអព្ភូតហេតុទាំងឡាយជាភស្តុតាងនៃវត្តមានអាទិទេព។ យើងឮការអះអាងដែលគួរអោយអស្ចារ្យថាគេបានព្យាបាលមនុស្សអោយជាពីឈឺ តែយើងមិនដែលបានទទួលការពិសោធន៍យ៉ាងសេរីពីក្រុមមន្ត្រីពេទ្យឬសល្យពេទ្យ (ពេទ្យវះកាត់)សោះ។

ហើយឮសេចក្តីរាយការណ៍ចាស់ៗថា មានអ្នកខ្លះត្រូវបានជួយជីវិតដោយភាពអស្ចារ្យពីគ្រោះមហន្តរាយ តែយើងមិនដែលឃើញផ្ទាល់នឹងភ្នែកនូវហេតុការណ៍អ្វីដែលគេឧបមាថាបានកើតឡើង។ យើងឮពាក្យចចាមអារាមថាការបួងសួងបានពុះច្រែកទៅរកខ្លួនមនុស្សឈឺ ឬជួយតន្ទឹងដែលពុកផុយ តែយើងមិនដែលឃើញគេឆ្លុះដោយពន្លឺអ៊ុលត្រាសោវ ឬបានទទួលការពន្យល់បញ្ជាក់ពីវេជ្ជបណ្ឌិតឬគ្រូពេទ្យណាមួយសោះ។ ការអះអាងដ៏មោះមុតនេះ ជាពាក្យចចាមអារាមនិងដំណឹងពីបុរាណនាយ មិនមានដាក់បង្ហាញភស្តុតាងច្បាស់លាស់ណាមួយ ហើយភស្តុតាងច្បាស់លាស់ខាងបរិហារពិតជាកំរមានណាស់។ ទោះជាយ៉ាងណា ពេលខ្លះវត្ថុដែលមិនអាចពន្យល់បានក៏អាចកើតឡើង ហេតុការណ៍ដែលគេមិនបានគិតទុកជាមុនក៏អាចលេចធ្លោរឡើងបាន។តែជាអសមត្ថភាពរបស់យើងទៅដើម្បីពន្យល់ហេតុការណ៍ដូច្នេះមិនមែនចង្អុលបញ្ជាក់ពីការមានតួអាទិទេពពិតនោះទេ។ វាចង្អុលបញ្ជាក់ប្រាប់យើងច្បាស់ថាចំណេះដឹងរបស់យើងគឺមានមិនគ្រប់គ្រាន់។ មុនពេលពេទ្យសម័យថ្មីមានការអភិវឌ្ឍន៍ ពេលមនុស្សមិនដឹងអំពីអ្វីជាសាហេតុនៃជំងឺ មនុស្សក៏នាំគ្នាជឿថាអាទិទេពអង្គតែមួយឬអាទិទេពច្រើនអង្គបញ្ជូនមេរោគជំងឺមកដើម្បីដាក់ទោសទណ្ឌកម្ម។ ឥឡូវនេះយើងដឹងថាតើអ្វីជាសាហេតុនៃជំងឺទាំងនោះ ហើយពេលយើងឈឺយើងនឹងលេបថ្នាំ។ ក្នុងពេលដែលចំណេះដឹងរបស់យើងអំពីលោកមានការអភិវឌ្ឍន៍ច្រើនឡើងយើងអាចនឹងយល់នូវអ្វីដែលជាសាហេតុនូវអព្ភូតហេតុដែលមិនអាចយល់បានដូចដែលឥឡូវនេះយើងអាចយល់នូវអ្វីដែលជាសាហេតុនៃជំងឺនោះ ។

**ម.** *តែមនុស្សជាច្រើនជឿលើតួអង្គអាទិទេពច្រើនរាងផ្សេងៗ នោះវាពិតជាមានពិត។*

**ឌ.** មិនពិតទេ។ មានពេលមួយជាពេលដែលមនុស្សជឿថាពិភពលោកមានរាងសំប៉ែតតែពួកគេទាំងអស់នោះជឿខុស។ ចំនួនមនុស្សដែលជឿលើការគិតណាមួយគឺគ្មានរង្វាស់វាស់

សេចក្តីពិតឬសេចក្តីមិនពិតនៃគំនិតនោះទេ។ វិធីតែម្យ៉ាងយើងអាចប្រាប់ថាតើការគិតនោះពិតឬមិនពិតដោយការសំឡឹងមើលហេតុការណ៍ពិតទាំងឡាយ ហើយត្រួតពិនិត្យនូវភស្តុតាងនោះ។

*ឬ. ដូច្នេះបើពុទ្ធសាសនិកជនមិនជឿលើអាទិទេពទាំងឡាយតើពុទ្ធសាសនិកជនជឿទៅលើអ្វី?*

**ទ.** យើងមិនជឿលើអាទិទេពពីព្រោះយើងជឿលើមនុស្ស។ យើងជឿថាមនុស្សម្នាក់ៗគឺមានតំលៃនិងមានសារះប្រយោជន៍ ដែលមនុស្សទាំងអស់នោះមានសក្តានុពលដើម្បីអភិវឌ្ឍន៍ខ្លួនឯងអោយក្លាយជាព្រះសម្មាសម្ពុទ្ធជាម្ចាស់បាន ដែលព្រះអង្គជាមនុស្សដែលបានបំពេញខ្លួនឯងអោយមានលក្ខណៈគ្រប់បរិបូរទាំងអស់។ យើងជឿថាមនុស្សលោកអាចជុះនូវអវិជ្ជានិងភាពគ្មានហេតុផលបានដាច់របស់ ហើយឃើញវត្ថុគ្រប់យ៉ាងដូចដែលពួកគេឃើញថាពិតដូច្នោះ។ យើងជឿថាការប្រកាន់ខ្លួន សេចក្តីខឹង ការឈ្នានីស និងការច្រណែនពិន្ទាអាចផ្លាស់ប្តូរបានដោយករុណាធម៌ ការអត់ធន់ ការទំនុកបំរុងគ្នា និងការមានសន្តានចិត្តល្អ។ យើងជឿថាទាំងអស់នេះគឺស្ថិតលើស្មារតីរបស់មនុស្សម្នាក់ៗប្រសិនបើគេមិនប្រមាទ ទាំងបានដឹកនាំនិងគាំទ្រដោយពុទ្ធបរិស័ទល្អៗទាំងឡាយ ហើយញ៉ាំងស្មារតីអោយយល់បានតាមពុទ្ធភាសិតដូចដែលព្រះពុទ្ធអង្គត្រាស់ថា *មានតែខ្លួនជាទីពឹងនៃខ្លួន អ្នកដទៃមិនអាចជាទីពឹងដល់យើងបានឡើយ។ អ្នកត្រូវតែដើរទៅលើមាគ៌ាដោយខ្លួនឯង តថាគតគ្រាន់តែជាអ្នកចង្អុលបង្ហាញផ្លូវអោយដើរតែប៉ុណ្ណោះ* ទីឃនិកាយ ១៦៥

# ភាគ ៤

# និច្ចសីល ឬ សីល៥

**ស.** *សាសនាផ្សេងៗចាប់យកគំនិតត្រូវឬខុសពីបញ្ញត្តិទាំងឡាយរបស់អាទិទេពមួយអង្គឬច្រើនអង្គ។ អ្នកជាពុទ្ធសាសនិកជនដែលមិនជឿលើអាទិទេព ដូច្នេះតើអ្នកដឹងសេចក្តីត្រូវពីសេចក្តីខុសបានយ៉ាងណា?*

**ទ.** សេចក្តីត្រិះរិះទាំងឡាយណា បើនិយាយឬប្រព្រឹត្តដែលមានឫសគល់ពីលោភៈ ទោសៈ និងមោហៈ ហើយវានាំអោយឆ្ងាយចាកពីព្រះនិព្វានគឺជាអំពើអាក្រក់ ហើយការត្រិះរិះណាមួយទោះនិយាយឬប្រព្រឹត្តដែលមានឫសគល់ចេញមកពីការធ្វើទាន មេត្តាករុណាធម៌ និងបញ្ញា ហើយអំពើនោះជួយសំអាតផ្លូវទៅរកព្រះនិព្វាន នោះហៅថាអំពើល្អ ។ ដើម្បីដឹងនូវអ្វីត្រូវឬខុស សំរាប់សាសនាដែលយកព្រះអាទិទេពជាធំ អំពើល្អនិងអាក្រក់អ្នកដទៃជាអ្នកកំណត់អោយអ្នក។ តែសំរាប់សាសនាដែលយកមនុស្សជាធំ ដូចជាព្រះពុទ្ធសាសនាស្គាល់នូវអ្វីខុស អ្វីត្រូវ គឺអ្នកត្រូវតែអភិវឌ្ឍន៍ការភ្ញាក់រលឹកនិងការយល់ដោយខ្លួនឯងអោយបានស៊ីជំរៅ។ ហើយចរិយធម៌ដែលស្ថិតលើការយល់ដឹងជានិច្ចជាកាលរឹងមាំជាងចរិយធម៌ដែលស្ថិតលើការបញ្ញាពីអ្នកដទៃ ។

ដូច្នេះ ដើម្បីដឹងនូវអ្វីដែលត្រូវនិងអ្វីដែលខុស ពុទ្ធសាសនិកជនសំឡឹងមើលទៅលើបញ្ញាបីយ៉ាងគឺចេតនា ផលដែលកើតលើបុគ្គលនោះផ្ទាល់និងផលដែលកើតលើអ្នកដទៃ។ ប្រសិនបើចេតនាល្អ (ដែលមានឫសគល់មកពីការសង្គ្រោះ ការស្រឡាញ់អាណិត និងបញ្ញា) តែបើវាជាការជួយខ្លួនឯង (ជួយខ្ញុំឱ្យចេះបរិច្ចាគកាន់តែច្រើន អោយចេះអាណិតស្រឡាញ់កាន់តែច្រើន និងអោយមានបញ្ញាកាន់តែច្រើន) ពេលនោះកម្មនិងការប្រព្រឹត្តរបស់ខ្ញុំ

គឺត្រឹមត្រូវ ល្អនិងមានសីលធម៌។ តាមពិតមានរឿងប្លែកៗគ្នាច្រើនណាស់ចំពោះរឿងនេះ។ ជួនកាលខ្ញុំប្រព្រឹត្តដោយចេតនាល្អបំផុតតែវាមិនបានប្រយោជន៍ទាំងខ្លួនខ្ញុំនិងអ្នកដទៃ។ ជួនកាលចេតនារបស់ខ្ញុំគឺឆ្ងាយពីសេចក្តីល្អ តែអំពើរបស់ខ្ញុំជួយអ្នកដទៃរហូត។ ជួនកាលខ្ញុំធ្វើដោយប្រាសចាកបំណងល្អហើយការធ្វើរបស់ខ្ញុំបានជួយខ្ញុំ តែអាចនឹងធ្វើអោយប៉ះទង្គិចអាក្រក់ដល់អ្នកដទៃខ្លះ។ ក្នុងករណីនេះ អំពើរបស់ខ្ញុំគឺច្របូកច្របល់គ្នាគឺការផ្សំគ្នានូវអំពើល្អនិងអំពើដែលមិនសូវល្អ។ ពេលចេតនាអាក្រក់ហើយអំពើនោះមិនជួយទាំងខ្លួនឯងផងនិងអ្នកដទៃផង អំពើបែបនោះគឺអាក្រក់។ តែពេលចេតនារបស់យើងល្អហើយអំពើរបស់យើងធ្វើប្រយោជន៍ឱ្យខ្លួនឯងផងនិងអ្នកដទៃផង អំពើនោះគឺពិតជាអំពើល្អទាំងស្រុង។

**ស.** *ដូច្នេះ តើព្រះពុទ្ធសាសនាមានក្រមសីលធម៌ទេ?*

**ឆ.** បាទមាន! សីល៥គឺជាសីលធម៌មូលដ្ឋានរបស់ពុទ្ធបរិស័ទ។ សីលទី១គឺជៀសវាងពីការសំឡាប់ឬធ្វើទុក្ខបុកម្នេញសត្វទាំងឡាយ។ សីលទី២គឺវៀរចាកការលួចទ្រព្យគេ សីលទី៣គឺវៀរចាកការប្រព្រឹត្តខុសផ្លូវកាម សីលទី៤គឺវៀរចាកការនិយាយកុហក់ និងសីលទី៥គឺវៀរចាកការផឹកទឹកស្រវឹង និងសេពថ្នាំញៀន។

**ស.** *តែតាមពិតវាជាការល្អដែលត្រូវសំឡាប់នៅពេលខ្លះ។ ឧទាហរណ៍ដូចជាសំឡាប់សត្វល្អិតដែលចំឡងមេរោគ ឬក៏អ្នកខ្លះនឹងមកសំឡាប់យើង?*

**ឆ.** វាជាការល្អសំរាប់អ្នក។ តែតើវត្ថុឬក៏មនុស្សនោះជាអ្វី?។ ពួកគេប្រាថ្នាចង់មានជីវិតដូចអ្នកដែរ។ ពេលអ្នកសំរេចចិត្តសំឡាប់សត្វដែលចំឡងមេរោគ ចេតនារបស់អ្នកគង់នឹងរួមផ្សំជាមួយការជួយខ្លួនឯង (ល្អ) ហើយនឹងជាប្រតិកម្មអាក្រក់ (អាក្រក់)។ អំពើនេះនឹង

ផ្តល់ប្រយោជន៍សំរាប់ខ្លួនអ្នក (ល្អ) តែជាក់ស្តែងវាមិនផ្តល់ប្រយោជន៍ដល់សត្វល្អិតនោះ (អាក្រក់)។ ដូច្នេះពេលនោះជាពេលចាំបាច់របស់អ្នកដែលត្រូវតែសំឡាប់ តែវាក៏មិនអាចធានាថាត្រូវទាំងស្រុងដែរ។

**ប្ញ.** *អ្នកជាពុទ្ធសាសនិកជនដែលអោយតំលៃខ្លាំងណាស់ទៅលើស្រមោចនិងសត្វល្អិត។*

**ទ.** ពុទ្ធសាសនិកជនព្យាយាមអភិវឌ្ឍន៍មេត្តាធម៌ដែលនឹងមិនមានការរើសអើង និងរាប់អានស្មើភាពគ្នា។គេមើលឃើញពិភពលោកប្រមូលផ្តុំជាចង្កោមមួលមួយដែលម្នាក់ៗនិងសត្វលោកទាំងអស់មានទីកន្លែងនិងមុខនាទីរៀងៗខ្លួន។ ពួកគេជឿថាគួរប្រយ័ត្នប្រយែងអោយខ្លាំងឡើងមុននឹងតុល្យភាពស្រស់បំព្រងនៃធម្មជាតិត្រូវគេបំផ្លាញឬធ្វើអោយចលាចល។ គ្រាន់តែក្រលេកមើលវប្បធម៌ទាំងអស់នោះដែលសង្កត់ធ្ងន់ទៅលើការបំផ្លាញធម្មជាតិដើម្បីបំពេញចំណង់ ប្រៀបយកគ្រប់អំណក់ពីធម្មជាតិដោយឥតមានដាក់បំពេញវិញឡើយ មានតែយកឈ្នះនិងកាត់បន្ថយវា។ គេបានជាន់ឈ្លីដល់ធម្មជាតិ។ អាកាសគ្រប់កន្លែងបានកំពុងក្លាយជាពិស ទឹកស្ទឹងត្រូវល្អក់កខ្វក់ឬក៏រីងស្ងួត ពូជសត្វល្អៗជាច្រើនកំពុងបាត់ពូជ ជួរភ្នំទាំងឡាយត្រងោលហើយច្រោះដាច់ពីគ្នា។ សូម្បីអាកាសធាតុក៏ផ្លាស់ប្តូរ។ ប្រសិនបើមនុស្សយកចិត្តទុកដាក់បន្តិចក្នុងការកាប់គាស់ បំផ្លាញនិងសំឡាប់ ស្ថានការណ៍ដែលគួរអោយភ័យខ្លាចនេះនឹងមិនកើតមានឡើយ។ យើងទាំងអស់គ្នាគួរព្យាយាមបន្ទុះការគោរពន្ធវជីវិតសត្វឱ្យខ្លាំងជាងនេះបន្តិច។ នេះគឺជាអ្វីដែលសិក្ខាបទទី១បញ្ជាក់ដល់យើង។

**ប្ញ.** *សិក្ខាបទទីពបញ្ជាក់ថាយើងគួរចៀសវាងការប្រព្រឹត្តខុសផ្លូវភេទតើអ្វីគឺការប្រព្រឹត្តខុសផ្លូវភេទ?*

**ទ.** បើយើងប្រើកលវិធី គំរាមខាងសតិអារម្មណ៍ឬបង្ខិតបង្ខំនរណាម្នាក់អោយរួមភេទ

ជាមួយយើង នេះគឺការប្រព្រឹត្តខុសផ្លូវភេទ។ មនុស្សចិត្តសាវាក៏ជាលក្ខណៈការប្រព្រឹត្តខុសផ្លូវភេទព្រោះពេលយើងរៀបការយើងសន្យាភរិយាយើងថា យើងនឹងភក្តីភាពជាមួយគេ។ ពេលយើងប្រព្រឹត្តក្បត់ចិត្តគឺយើងមិនគោរពកិច្ចសន្យាយើងហើយក្បត់នូវពាក្យសច្ចះ។ រួមភេទអាចជាការបញ្ចេញនូវសេចក្តីស្នេហា និងនៅរួមគ្នារវាងមនុស្សពីរនាក់ ហើយជាពេលដែលវាផ្តល់អោយយើងនូវសុខមាលភាពផ្លូវអារម្មណ៍និងផ្លូវចិត្ត។

**បុ.** *ការរួមភេទមុនពេលរៀបអាពាហ៍ពិពាហ៍ជាប្រភេទការប្រព្រឹត្តខុសផ្លូវភេទទេ?*

**ទ.** ទេ ប្រសិនបើជាការយល់ព្រមរវាងគួរទាំងពីរ។ យ៉ាងណាក៏ដោយយើងមិនគួរបំភ្លេចផងដែរនូវតួនាទីរបស់សរីរវិទ្យានៃការរួមភេទជាការផលិត ហើយប្រសិនបើស្ត្រីដែលមិនទាន់បានរៀបការមានផ្ទៃពោះ វាអាចបង្កជាបញ្ហាធំដើម្បីដោះស្រាយ។ មនុស្សដែលមានគំនិតនិងយល់ការងារជាច្រើនគិតថាវាគួរតែចៀសវាងការរួមភេទរហូតដល់ក្រោយថ្ងៃរៀបការ។

**បុ.** *ចុះអំពីការនិយាយកុហក់? តើយើងអាចរស់នៅបានទេបើយើងគ្មានការកុហក់?*

**ទ.** បើវាពិតជាមិនអាចគេចវេះនិយាយកុហក់បាននៅក្នុងសង្គម ឬធ្វើជំនួញ មូលគំនិតដ៏រលួយស្អុយនិងគួរអោយខ្លាចដូច្នោះគួរនឹងផ្លាស់ប្តូរចេញ។ ពុទ្ធបរិស័ទគឺជាបុគ្គលដែលដោះស្រាយនូវការប្រព្រឹត្តផ្សេងៗប្រកបដោយការយកចិត្តទុកដាក់អំពីបញ្ហាទាំងឡាយ ដោយព្យាយាមធ្វើខ្លួនជាមនុស្សមានភាពស្មោះត្រង់និងគួរអោយជឿទុកចិត្តបាន។

**បុ.** *ប្រពៃណាស់! ចុះអំពីការផឹកទឹកស្រវឹង? តាមពិតផឹកបន្តិចបន្តួចមិនខុសអ្វីមែនទេ?*

**ទ.** មនុស្សមិនមែនផឹកដើម្បីភ្លក់រស់ជាតិនោះទេ។ ពេលអង្គុយផឹកតែម្នាក់ឯងជាការផឹក

ឃើញើបម្លែរភាពតានតឹងហើយពេលពួកគេផឹកស្រាមច្បាស់ច្រើនជានិច្ចជាកាលជាការផឹកដើម្បីសង្គម ទោះបីផឹកតិចក៏ធ្វើអោយបាត់សតិនិងបំផ្លាញភាពចងចាំក្នុងខ្លួនដែរ។ ការផឹកច្រើននឹងនាំឱ្យប៉ះទង្គិចការវិនាសអន្តរាយធំៗ។

**ឬ.** *ផឹកតិចតួចអាចនឹងមិនខុសសីលមែនទេ? ព្រោះវាបន្តិចបន្តួចប៉ុណ្ណោះ។*

**ទិ.** មែនហើយ យើងផឹកបន្តិចបន្តួចហើយបើអ្នកមិនអាចបដិបត្តិសូម្បីបន្តិចបន្តួចបានផង ការប្រព្រឹត្តនិងវិធីដោះស្រាយរបស់អ្នកគឺមិនរឹងប៉ឹងគ្រប់គ្រាន់ទាល់តែសោះមែនទេ?។

**ឬ.** *សីល៥គឺអវិជ្ជមាន។ សិក្ខាបទទាំងឡាយហាមប្រាមអ្នកមិនអោយធ្វើអ្វីសោះគេហាមអ្នកមិនអោយធ្វើអ្វីសោះឡើយ។*

**ទិ.** សីល៥ជាសីលធម៌របស់ពុទ្ធបរិស័ទថ្នាក់មូលដ្ឋាន។វាមិនមែនហាមប្រាមគ្រប់យ៉ាងនោះទេ។ យើងចាប់ផ្តើមដោយការទទួលស្គាល់នូវការប្រព្រឹត្តអាក្រក់របស់ខ្លួនឯងហើយព្យាយាមបំបាត់វាចេញ។ នោះគឺអ្វីដែលសីល៥មាន។ បន្ទាប់ពីយើងឈប់ធ្វើអាក្រក់ពេលនោះយើងចាប់ផ្តើមធ្វើល្អ។ ជាឧទាហរណ៍ដូចជាពាក្យសំដីជាដើម។ ព្រះពុទ្ធជាម្ចាស់ត្រាស់ថាយើងអាចចាប់ផ្តើមពីវៀរចាកការនិយាយកុហក់។ បន្ទាប់មកយើងគួរនិយាយតែពាក្យពិតនិយាយពីរោះនិងសមរម្យ ហើយនិយាយត្រូវតាមកាល។ ព្រះពុទ្ធអង្គត្រាស់ថា

*លោះបង់ការនិយាយកុហក់ចោល អ្នកនឹងក្លាយជាអ្នកនិយាយពាក្យពិត គួរអោយជឿមានសច្ចៈភាព យកជាការបាន គេមិនបានបោកប្រាស់មនុស្សលោក។ លោះបង់ការនិយាយពាក្យញុះញង់ គេនឹងមិនយករឿងអ្នកនោះមកនិយាយទីនេះ និងមិនយករឿងរបស់អ្នកនេះ*

ទៅនិយាយទីនោះព្រោះជាហេតុធ្វើអោយគេបែកបាក់គ្នាបាន។ គេនិយាយផ្សះផ្សាពួកទាំងនោះដែលបែកបាក់គ្នា ហើយជួយគ្រេកអរនៅពេលឃើញអ្នកនោះត្រូវគ្នាល្អ។ អ្នកដទៃត្រូវរូវគ្នាជាសេចក្តីរីករាយរបស់អ្នក គេសាមគ្គីគ្នាជាការពេញចិត្តរបស់អ្នក គេស្រុះស្រួលគ្នាជាករុណាធម៌របស់អ្នក នេះជាប្រសិទ្ធិភាពសំដីត្រូវរបស់អ្នក។ លោះបង់ចោលពាក្យអាសអាភាស ពាក្យសំដីគាត់មិនគ្រោកគ្រាត ពីរោះស្តាប់ ទទួលយកបាន ត្រជាក់ដល់បេះដូងជ្រាលជ្រៅ អ្នកទាំងឡាយនឹងចូលចិត្តអ្នក។ លោះបង់ពាក្យនិយាយ រោយរាយឥតប្រយោជន៍ ទោះត្រូវពេល ត្រូវចំណុច ត្រូវតាមធម៌និងវិន័យ។ គេគួរនិយាយពាក្យមានតំលៃ ត្រូវតាមកាល មានហេតុផល ជាពាក្យសុភាសិត និងត្រូវតាមសេចក្តី ។

# ភាគ ៥
# ការកើតម្ដងទៀត

**ម.** *តើពួកសត្វលោកទាំងអស់កើតមកពីណា ហើយពេលពួកគេស្លាប់ទៅកើតនៅទីណា?*

**ចិ.** មានចំឡើយបីដែលអាចឆ្លើយបានចំពោះសំណួរនេះ។ អ្នកទាំងនោះដែលជឿលើឯកាទិទេពឬពហុអាទិទេពជាធម្មតាអះអាងថាមុនពេលកើតមានបុគ្គលម្នាក់ប្រុសឬស្រីមិនទាន់មានដូចសព្វថ្ងៃទេ ក្រោយមកប្រុសឬក៏ស្រីមានជីវិតឡើងបានដោយសារបំណងព្រះអាទិទេព។ ខ្លួនគាត់ឬខ្លួននាងរស់រានមានជីវិតមកដល់ពេលនេះ អាស្រ័យធ្វើតាមនូវអ្វីដែលគេជឿហើយបដិបត្តិសំរាប់ជីវិតរបស់គេ ពួកគេក៏កើតផងដែរក្នុងឋានសួគ៌ាឬឋាននរក។ មានអ្នកផ្សេងៗទៀតដូចជាអ្នកមនុស្សវិទ្យា អ្នកវិទ្យាសាស្ត្រ ដែលអះអាងថាបុគ្គលម្នាក់ៗកើតមានជីវិតអាស្រ័យទៅលើសាហេតុធម្មជាតិ មានជីវិតហើយបន្ទាប់មកក៏ស្លាប់ មិនមានអ្វីសេសសល់ទៀត ព្រះពុទ្ធសាសនាមិនទទួលស្គាល់ផងដែរនូវការពន្យល់ទាំងនេះ។ បញ្ហាទី១បង្កើតជាបញ្ហាចរិយធម៌ច្រើន។ បើអាទិទេពល្អៗពិតជាបានបង្កើតពួកយើងម្នាក់ៗ វាពិបាកនឹងពន្យល់ថាហេតុអ្វីបានជាមនុស្សភាគច្រើនវិកលវិការគួរអោយខ្លាច ឬហេតុអ្វីក្មេងចំនួនជាច្រើនខុសគេតាំងពីកំណើត ហើយនៅតែមានដូច្នេះ។ បញ្ហាមួយទៀតជាមួយនឹងការពន្យល់ដោយពួកជឿលើអាទិទេព គឺថាវាហាក់បីដូចជាអយុត្តិធម៌ដែលមនុស្សទទួលរងទុក្ខវេទនាក្នុងខ្លួន ក្នុងឋាននរកអស់ពេល៦០,៧០ឆ្នាំពីព្រោះតែការមិនជឿឬអសីលធម៌។ ដូចគ្នាដែរ អ្នករស់នៅប្រកបដោយសីលធម៌៦០,៧០ឆ្នាំ ហាក់ដូចជាទទួលសិទ្ធិទៅកើតទៅសោយសុខនៅឋានសួគ៌ាបានតិចតួចណាស់ សំរាប់អ្វីដែលបុគ្គលប្រុសស្រីនោះបានធ្វើក្នុងកំឡុងរស់នៅក្នុងឋានមនុស្ស។

ការពន្យល់ទីពីរគឺអាចល្អជាងទីមួយនិងមានភស្តុតាងជាវិទ្យាសាស្ត្រជាងមុនដើម្បីគាំទ្រ តែនៅសល់សំណួរសំខាន់ៗជាច្រើនដែលនៅមិនទាន់ឆ្លើយ។ តើអព្ភូតហេតុអ្វីដែលស្មុគស្មាញយ៉ាងខ្លាំងដូចជាវិញ្ញាណអាចវិវត្តពីការជួបកោសិការពីរដ៏សាមញ្ញ ទឹកកាមហើយនឹងពងញាស់។ហើយឥឡូវនេះការសិក្សាខាងចិត្តវិស័យជាសាខាដែលទទួលស្គាល់ដោយវិទ្យាសាស្ត្រ អព្ភូតហេតុនៃទូរលេទន៍គឺលំបាកខ្លាំងឡើងដើម្បីតំរូវទៅនឹងរូបបែបខាងវត្ថុវិស័យនៃសភាវៈចិត្ត។

**ប្ុ.** *តើចិត្តចេញពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបានយ៉ាងណា?*

**ទិ.** គិតអំពីអ្វីមួយប្រដូចទៅនឹងរលកវិទ្យុ។ រលកវិទ្យុដែលមិនកើតឡើងពីពាក្យសំដីឬតន្ត្រី តែជាកំឡាំងក្នុងរលកប្រេដេញចង្វាក់ខុសគ្នា ដែលជំរុញតពីមួយទៅមួយ ហោះហើរឆ្លងកាត់ស្រទាប់បរិយាកាស ហើយដាច់ចេញ និងជ្រៀតចូលដោយគ្រឿងទទួលពីកន្លែងដែលជាកន្លែងផ្សាយចេញជាពាក្យពេចន៍និងតួរតន្ត្រី។ វាក៏ដូចគ្នាដែរជាមួយនឹងចិត្ត។ ពេលស្លាប់ទៅកំឡាំងចិត្តហោះហើរឆ្លងកាត់ស្រទាប់បរិយាកាស គឺរសាត់ចេញនិងរសាត់ចូលដោយពងញាស់ដែលល្អ។ ទារកក្នុងស្បូនធំធាត់ឡើង វាតំកល់ខ្លួនឯងចំកណ្តាលជាខួរក្បាលជាកន្លែងដែលក្រោយមកផ្សាយចេញខ្លួនឯងក្លាយជាខ្លួនមនុស្សថ្មីឡើង។

**ប្ុ.** *តើមនុស្សម្នាក់ៗសុទ្ធតែកើតកំណើតជាមនុស្សទាំងអស់គ្នាឬ?*

**ទិ.** ទេ, មានភពច្រើនណាស់ដែលម្នាក់ៗអាចចាប់កំណើតឡើងវិញ។ មនុស្សខ្លះកើតក្នុងឋានសួគ៌ា អ្នកខ្លះកើតក្នុងឋាននរក អ្នកខ្លះកើតជាប្រេតនិងផ្សេងៗទៀត។ ឋានសួគ៌ាមិនមែនជាទីកន្លែងទេ តែជាអង្គប្រជុំសភាវៈដែលម្នាក់ៗមានរូបកាយល្អិតនិងជាកន្លែងដែលចិត្ត

សោយសុខដ៏ប្រពៃរ៍។ សាសនាខ្លះព្យាយាមយ៉ាងខ្លាំងដើម្បីកើតក្នុងភពសួគ៌ាដែលជឿយ៉ាងខុសៗថាជាប្រជុំជីវិតអចិន្ត្រៃយ៍។

តែវាមិនដូច្នោះទេ។ ដូចគ្នានឹងលក្ខណភពដទៃឋានសួគ៌ាគឺជាអនិច្ចំហើយពេលជីវិតមនុស្សម្នាក់ នៅឋាននេះបានបញ្ចប់ អ្នកនោះអាចកើតឡើងវិញម្តងទៀតជាមនុស្ស។ ដូចគ្នាដែរនរកក៏មិនមែនជាទីកន្លែង តែជាឋានមានពិតមួយដែលសត្វមានរូបកាយល្អិតហើយជាឋានដែលចិត្តជួបប្រទះតែភាពអន្ទះសារនិងសេចក្តីទុក្ខភ័យ។ ដូចគ្នា កើតជាប្រេតអត់ឃ្លានជាឋានពិតមួយដែលមានខ្លួនល្អិតហើយជាកន្លែងដែលចិត្តទ្រាំទុក្ខយូរអង្វែងដោយការញាំញីនៃការស្រេកឃ្លានហើយយូរអង្វែងណាស់។

ដូច្នេះសត្វកើតក្នុងសួគ៌ាសោយសុខ កើតជាសត្វនរកឬប្រេតសោយនូវទុក្ខ និងកើតជាមនុស្សសោយទុក្ខផងសុខផងផ្សំគ្នារហូត។ ដូច្នេះភាពខុសគ្នាសំខាន់រវាងឋានមនុស្សនិងឋានផ្សេងទៀតមានចំពោះលក្ខណៈរាងកាយនិងការសោយសុខឬការសោយទុក្ខ។

ព្រះពុទ្ធសាសនាផ្តល់អោយការពន្យល់ដ៏គួរអោយពេញចិត្តបំផុតចំពោះមនុស្សកើតមកពីទីណា?ហើយស្លាប់ទៅ ទៅកើតទីណា?។ ពេលយើងស្លាប់ចិត្តវិញ្ញាណព្រមជាមួយចុតិចិត្តវិបាកកម្ម បុណ្យកុសល និងលក្ខណៈវិស័យដែលបានអភិវឌ្ឍន៍និងកំណត់លក្ខណ្ឌជីវិត កសាងខ្លួនឯងឡើងវិញក្នុងកំណើតស៊ុតដែលមានលក្ខណៈគ្រប់បរិបូរ។ ដូច្នេះ ការចំលូតលាស់របស់មនុស្សម្នាក់ៗ គឺកើតរលត់ហើយអភិវឌ្ឍន៍លក្ខណ្ឌខ្លួនឯងព្រមទាំងលក្ខណៈផ្លូវចិត្តដែលត្រូវបានវិវត្តបន្តរហូត។ ហើយអាស្រ័យបរិដ្ឋានថ្មី រូបកាយម្នាក់ៗនឹងផ្លាស់ប្តូរដោយកំណត់ទៅតាមការព្យាយាមរបស់វិញ្ញាណ និងកំណត់កត្តាសំខាន់ទាំងឡាយដូចជាការសិក្សា តំណរពូជពីឪពុកម្តាយនិងសង្គម ហើយស្លាប់ម្តងទៀត រួចទៅចាប់កំណើតនៅក្នុងស៊ុតដែលមានលក្ខណៈគ្រប់បរិបូរម្តងទៀត។ ការវិលវល់ស្លាប់និងកើតនេះនឹងបន្តរហូតលក្ខណ្ឌដែលបណ្តាលអោយ

ស្លាប់និងកើត គឺតណ្ហានិងអវិជ្ជាត្រូវបានបំផ្លាញ (បោសសំអាត)។ ពេលពួកគេមិនបន្តវិបរូត ដល់មិនកើតមកវិញម្តងទៀតព្រោះចិត្តសំរេចបាននូវធម៌ជាន់ខ្ពស់ហៅថា ព្រះនិព្វានហើយជា ទិសដៅខ្ពស់បំផុតរបស់ព្រះពុទ្ធសាសនា និងជាគោលបំណងរបស់ជីវិត។

**បុ.** *តើអ្វីដែលកំណត់នូវទីកន្លែងដែលយើងទៅកើត?*

**វិ.** កត្តាសំខាន់បំផុត តែមិនមែនមានតែមួយទេ ដែលជះឥទ្ធិពលអោយយើងកើតម្តង ទៀតហើយជីវិតប្រភេទណាដែលយើងត្រូវកើតគឺអាស្រ័យទៅលើកម្មរបស់យើង។ ពាក្យថា កម្មមានន័យថាអំពើហើយសំដៅទៅលើចេតនាកម្មរបស់យើង។ ន័យផ្សេងទៀតសំដៅទៅ លើការកំណត់អំពើទាំងឡាយដែលយើងបានគិតនិងបានប្រព្រឹត្តក្នុងអតីតកាលកន្លងមក។ ដូចគ្នា ដែរអ្វីដែលយើងគិតនិងប្រព្រឹត្តក្នុងបច្ចុប្បន្ននេះនឹងមានឥទ្ធិពលក្នុងកំណើតនាពេលអនាគតខាង មុខទៀត។

មនុស្សដែលមានមេត្តាករុណានិងភាពសុចរិតទៀងត្រង់នឹងទៅកើតក្នុងឋានសួគ៌ាឬ មកកើតជាមនុស្សដែលបរិបូរទៅដោយភោគសម្បត្តិនិងសេចក្តីសុខ។ មនុស្សដែលកាចឃោរ ឃៅ ធ្វើអំពើបាបឬទុក្ខក្រវល់ក្រវាយនឹងទៅកើតក្នុងឋាននរកឬកើតជាមនុស្សដែលពោរពេញ ទៅដោយសេចក្តីទុក្ខវេទនា។ មនុស្សដែលបង្កើនចំណង់តណ្ហាមិនចេះចប់ បង្កើនចំណង់ តណ្ហាខ្លាំងឡើងៗបន្តទៀត និងមហិច្ឆតាដែលពុះកញ្ជ្រោលខ្លាំង មិនចេះស្កប់ស្កល់ធ្វើអោយ កើតម្តងហើយម្តងទៀតដូចជាប្រេតឬមនុស្សដែលជួបនូវសេចក្តីទុក្ខដោយការវិលវល់យូរអង្វែង ប្រកបដោយតណ្ហាខ្លាំង។ យ៉ាងណាក៏ដោយទំលាប់ផ្លូវចិត្តគឺអភិវឌ្ឍន៍យ៉ាងខ្លាំងនូវជីវិតជាតិនេះ ហើយនឹងបន្តទៀតរហូតដល់ជាតិខាងមុខ។ ទោះបីយ៉ាងណាមនុស្សភាគច្រើនកើតជាមនុស្ស ម្តងទៀត។

*ម.  ដូច្នេះបើជីវិតរបស់យើងត្រូវកំណត់ដោយកម្មរបស់យើង តើអាចប្តូរវាបានទេ?*

**ឆ.** តាមពិតយើងអាចប្តូរបាន។ នោះគឺសាហេតុដែលជាជំហានមួយក្នុងចំណោមជំហានទាំងប្រាំបីឬអរិយមគ្គប្រកបដោយអង្គ៨គឺសម្មាវាយាមៈ។ វាអាស្រ័យលើការជឿជាក់របស់យើងប្រើកំឡាំងព្យាយាមច្រើនប៉ុណ្ណានិងការតស៊ូក្រាញនឿលយ៉ាងណា។ តែវាជាសេចក្តីពិតដែលមនុស្សខ្លះពឹងផ្អែកទៅលើបុណ្យដែលគេមានពីអតីតកាលតែម្យ៉ាង ដោយមិនព្យាយាមក្រាញនឿលផ្លាស់ប្តូរវាព្រមទាំងធ្លាក់ខ្លួនជាជនរងគ្រោះនូវវិបាកកម្មដ៏អាក្រក់នេះ។ មនុស្សបែបនោះនឹងទទួលរងទុក្ខបន្តទៀតបើគេមិនប្តូរទំលាប់អវិជ្ជមានរបស់គេ។ ទំលាប់អាក្រក់កាន់តែមានអាយុយូរអង្វែង សេចក្តីលំបាកកាន់តែពិបាកនឹងផ្លាស់ប្តូរ។ ពុទ្ធសាសនិកជនយល់ដូច្នេះ ហើយម្នាក់ៗអភិវឌ្ឍន៍ខ្លួនឯងព្រមទាំងគ្រប់ឱកាសទាំងអស់ដើម្បីកាត់បំបាក់សន្តានផ្លូវចិត្តដែលមានវិបាកកម្មជាទុក្ខ និងអភិវឌ្ឍន៍ផ្លូវចិត្តដែលមានវិបាកជាសុខនិងជាមង្គល។ សមាធិគឺជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយទាំងឡាយបដិបត្តិដើម្បីសង្កត់ទំលាប់ផ្លូវចិត្តក្នុងខណៈកំពុងនិយាយ ឬវៀរចាកការនិយាយក្នុងរឿងណាមួយតែម្យ៉ាង និងកំពុងប្រព្រឹត្តឬវៀរចាកការប្រព្រឹត្តវិធីណាមួយតែម្យ៉ាង។ក្នុងមួយជីវិតរបស់ពុទ្ធសាសនិកជនគឺជាការព្យាយាមសំអាតនិងជំរះផ្លូវចិត្ត។ ជាឧទាហរណ៍ បើមានការអត់ធន់និងករុណាធម៌គឺជាផ្នែកត្រឹមត្រូវនៃចរិកលក្ខណៈជីវិតជាតិមុនរបស់អ្នក ដូចជាឧប្បនិស្ស័យនឹងកើតឡើងម្តងទៀតក្នុងជីវិតបច្ចុប្បន្ន។ បើឧប្បនិស្ស័យនេះត្រូវបានពង្រឹងនិងអភិវឌ្ឍន៍ក្នុងជាតិនេះ នឹងមានម្តងទៀតកាន់តែខ្លាំងឡើងនិងសមរម្យថែមទៀតក្នុងជាតិខាងមុខ។ នេះស្ថិតលើកត្តាដែលអាចសង្កេតបានហើយសាមញ្ញបំផុត ដែលបានបង្កើតទំលាប់ពីយូរយារណាស់មកហើយ ដែលពិបាកកែប្រែបាន។

ឥឡូវនេះ ពេលអ្នកមានការអត់ធន់និងករុណាធម៌ វានឹងកើតឡើងចំពោះអ្នក ហើយអ្នកដទៃពិបាកនឹងបង្កបញ្ហាដល់អ្នក ហើយអ្នកជាមនុស្សមិនមានការចងកំហឹង មនុស្ស

ទាំងឡាយនឹងចូលចិត្តអ្នក ហើយជីវិតការរស់នៅរបស់អ្នកកាន់តែសុខឡើងៗ។

ឥឡូវយើងនឹងពិសោធន៍មើលឧទាហរណ៍មួយទៀត។ យើងគួរនិយាយថាអ្នកកើតមកជាតិនេះជាមួយនឹងឧប្បនិស្ស័យអត់ធន់និងមានករុណាធម៌អាស្រ័យដោយអ្នកមានឧប្បនិស្ស័យខាងផ្លូវចិត្តរបស់អ្នកកាលពីជាតិមុន។ តែនៅជាតិនេះអ្នកលះបង់ការពង្រឹងនិងអភិវឌ្ឍន៍ឧប្បនិស្ស័យទាំងនេះ។ ឧប្បនិស្ស័យទាំងនេះនឹងខ្សោយចុះជាបន្តបន្ទាប់ហើយរលប់រលាយបាត់ទៅព្រមទាំងអាចបាត់បង់ទៅទាំងអស់ក្នុងជាតិខាងមុខ។ខន្តីធម៌និងករុណាធម៌អាចចុះខ្សោយក្នុងករណីនេះ អាចប្រព្រឹត្តទៅបានទាំងជាតិនេះឬជាតិក្រោយ ការឡើងទោសះ សេចក្តីក្រោធនិងចិត្តយង់ឃ្នងអាចលាស់ធំឡើងនិងអភិវឌ្ឍន៍ទៀត ផ្តល់អោយពួកគេនូវជីវិតដែលគ្មានសេចក្តីសុខព្រោះតែវិបាកដែលគេបង្កើតដូចនោះ។ យើងនឹងពិសោធន៍ឧទាហរណ៍ចុងក្រោយថែមមួយទៀត។ យើងគួរនិយាយថាអាស្រ័យដោយឧប្បនិស្ស័យជាតិមុនរបស់អ្នក ពេលអ្នកមកកើតក្នុងជាតិនេះមានឧប្បនិស្ស័យជាមនុស្សមានទោសះចរិកក្រោធខឹងងាយ ហើយអ្នកដឹងថាឧប្បនិស្ស័យបែបនេះបណ្តាលអោយអ្នកមានសេចក្តីទុក្ខតែម្យ៉ាង ដូច្នេះអ្នកគួរតែព្យាយាមផ្លាស់ប្តូរវាចេញ។ អ្នកផ្លាស់ប្តូរវាដោយអារម្មណ៍ដែលវិជ្ជមាន។ បើអ្នកអាចកំចាត់វាចេញបានទាំងស្រុង ដែលអាចកំចាត់បានទាល់តែអ្នកព្យាយាម អ្នកនឹងបានជ្រះស្រឡះពីសេចក្តីទុក្ខដែលបណ្តាលមកពីទោសះចរិកនិងសេចក្តីក្រេវក្រោធ។ បើអ្នកអាចបន្ថយឧប្បនិស្ស័យដូច្នេះបានតែបន្តិច វាអាចនឹងមានម្តងទៀតក្នុងជាតិក្រោយជាមួយនឹងសេចក្តីព្យាយាមច្រើនឡើងបន្តិច ហើយវាអាចត្រូវបានកំចាត់ចោលទាំងស្រុង អ្នកនឹងអាចរួចរំដោះពីសេចក្តីទុក្ខទាំងពួង

**ម.** *អ្នកបានពន្យល់ច្រើនអំពីការកើតម្តងទៀត តែតើមានភស្តុតាងណាមួយទេដែល បញ្ជាក់ថាយើងកើតម្តងទៀតក្រោយពីស្លាប់?*

៩. មិនមែនមានតែភស្តុតាងខាងវិទ្យាសាស្ត្រទេដែលគាំទ្រដល់ជំនឿការកើតថ្មីរបស់ពុទ្ធសាសនិកជនវាគឺពិតជាទ្រឹស្តីជីវិតក្រោយពីការស្លាប់ដែលមានភស្តុតាងឯទៀតគាំទ្រវា។មិនមានចំណិតភស្តុតាងណាបញ្ជាក់នូវភាពមានពិតនៃឋានសួគ៌ហើយនឹងភស្តុតាងសូន្យសុងក្រោយពេលយើងស្លាប់ដែរ។ ប៉ុន្តែ៣០ឆ្នាំចុងក្រោយនេះអ្នកស្រាវជ្រាវខាងចិត្តវិញ្ញាណកំពុងសិក្សាស្រាវជ្រាវពត៌មានដែលថាមនុស្សខ្លះចាំជាតិកំណើតខ្លួនឯងបាន។ឧទាហរណ៍ ក្នុងប្រទេសអង់គ្លេសក្មេងស្រីអាយុ៥ឆ្នាំបាននិយាយថានាងអាចចងចាំម្តាយនិងឪពុកម្នាក់ទៀតរបស់នាងហើយនាងនិយាយយ៉ាងជាក់ស្តែងអំពីអ្វីដែលហាក់ដូចជាហេតុការណ៍នៃជីវិតមនុស្សម្នាក់ផ្សេងទៀត។អ្នកសិក្សាស្រាវជ្រាវខាងចិត្តវិញ្ញាណបាននាំនាងចូលមកហើយសួរសំណួរជាច្រើនចំពោះអ្វីដែលនាងបានឆ្លើយ។ នាងនិយាយអំពីការរស់នៅក្នុងភូមិមួយច្បាស់លាស់ ដែលរឿងនោះកើតឡើងក្នុងប្រទេសអេស្ប៉ាញ៉ុល។ នាងបានប្រាប់ឈ្មោះភូមិ ឈ្មោះផ្លូវដែលនាងរស់នៅ ឈ្មោះញាតិជិតខាងរបស់នាង និងជីវិតរស់នៅប្រចាំថ្ងៃទីនោះដោយលំអិត។ នាងក៏បាននិយាយទាំងទឹកភ្នែកនូវសាហេតុដែលនាងឡានជល់របួសហើយស្លាប់ពីរថ្ងៃក្រោយមក។ នៅពេលភាពលំអិតនេះត្រូវបានត្រួតពិនិត្យ ពួកគេទទួលបានចំឡើយថាអ្វីដែលនាងនិយាយគឺជាសេចក្តីពិត។ មានភូមិនោះនៅក្នុងប្រទេសអេស្ប៉ាញ ព្រមទាំងឈ្មោះភូមិដែលនាងបានប្រាប់។ មានផ្ទះមួយមានទំរង់ដូចដែលនាងបានអធិប្បាយនៅជាប់លេខផ្លូវដែលនាងបានប្រាប់ឈ្មោះ។ ភស្តុតាងច្រើនជាងនេះទៀត គឺមានស្ត្រីអាយុ២៣ឆ្នាំដែលរស់នៅក្នុងផ្ទះនេះបានត្រូវស្លាប់ដោយឧបទ្ទវហេតុដោយរថយន្តជល់កាលពី៥ឆ្នាំមុន។

ឥឡូវនេះ តើវាអាចពិតបានទេដែលក្មេងស្រីអាយុ៥ឆ្នាំក្នុងប្រទេសអង់គ្លេសដែលមិនដែលធ្លាប់ទៅប្រទេសអេស្ប៉ាញសោះដឹងអ្វីគ្រប់យ៉ាងអំពីទីនោះ? ហើយតាមពិតនេះគឺមិនមែន

ជាករណីតែមួយចំពោះរឿងនេះទេ។ លោកសាស្ត្រាចារ្យអៀនស្តីវិនសាន់នៃសកលវិទ្យាល័យ វឺជិនញៀ មហាវិទ្យាល័យចិត្តសាស្ត្របានអធិប្បាយរាប់រយរងអំពីករណីមនុស្សដឹងជាតិនេះនៅក្នុងសៀវភៅរបស់គាត់។ គាត់ជាអ្នកវិទ្យាសាស្ត្រដែលគេទទួលស្គាល់ច្រើនដែលការសិក្សា២៥ឆ្នាំអំពីមនុស្សចាំជាតិរបស់គាត់គឺមានភស្តុតាងដ៏ច្បាស់លាស់សំរាប់ទ្រឹស្តីចាប់កំណើតថ្មីរបស់ព្រះពុទ្ធសាសនា។

**ប.** *អ្នកនិយាយថា ការនិយាយអំពីបិសាចគឺជារឿងអរូបិយ៍។ តើការនិយាយអំពីការកើតម្តងទៀតមិនមែនជារឿងអរូបិយជំនឿនោះដែរឬទេ?*

**ទ.** វចនានុក្រមកំណត់និយមន័យអរូបិយជំនឿថាជាជំនឿមួយដែលមិនស្ថិតលើហេតុផលឬព្រឹត្តិការណ៍តែមានទំនាក់ទំនងនឹងការគិតដូចជានៅក្នុងមន្តអាគម។ បើអ្នកអាចបង្ហាញខ្ញុំការសិក្សានូវការមានបិសាចពិតប្រាកដដែលសរសេរដោយអ្នកវិទ្យាសាស្ត្រម្នាក់ ខ្ញុំនឹងទទួលយកជំនឿលើបិសាចថាមិនមែនជាអរូបិយជំនឿ។ តែខ្ញុំមិនដែលឮអំពីការសិក្សាស្រាវជ្រាវរឿងបិសាចណាមួយទេ អ្នកវិទ្យាសាស្ត្រដូចជាប្រក្រតីដែលមិនអើពើនឹងការសិក្សារឿងនេះ ដូច្នេះខ្ញុំអាចនិយាយថាគ្មានភស្តុតាងណាបញ្ជាក់ថាមានបិសាចនោះឡើយ។តែដូចដែលយើងទើបតែឃើញគឺមានភស្តុតាងពិតដែលបញ្ជាក់នូវចំងល់រឿងការកើតម្តងទៀតយ៉ាងពិតប្រាកដ។ ដូច្នេះបើជឿលើការកើតថ្មីទៀត យ៉ាងហោចណាស់សំអាងលើព្រឹត្តិការណ៍ជាក់ស្តែងខ្លះ វាមិនមែនជារឿងអរូបិយជំនឿឡើយ។

**ប.** *មែនហើយ តើមានអ្នកវិទ្យាសាស្ត្រណាមួយដែលជឿទៅលើការកើតថ្មីម្តងទៀត?*

**ទ.** ចំពឹនពរ មាន។ ថូមម៉ាសហាក់ស្លេដែលជាអ្នកនាំយករបកគំហើញវិទ្យាសាស្ត្រទៅដាក់

ក្នុងប្រព័ន្ធសិក្សាចក្រភពអង់គ្លេសសតវត្សន៍ទី១៩ហើយជាអ្នកវិទ្យាសាស្ត្រទី១ដែលការពារទ្រឹស្តីរបស់ដាវិន ដែលជឿថាការអវតារគឺជាគំនិតដែលអាចទទួលយកបាន។ នៅក្នុងសៀវភៅដ៏ល្បីល្បាញរបស់លោក *វិវឌ្ឍនាការនិងបញ្ហាចរិយសាស្ត្រនិងអត្ថបទដទៃទៀត* គាត់និយាយថា

*ក្នុងទ្រឹស្តីការប្តូរពីមួយទៅមួយ ទោះជាយ៉ាងណាក៏ប្រភពរបស់វា ការគាត់ស្ពានរបស់ព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនាត្រូវបានគេរកឃើញយកមកពិនិត្យរួចហើយ ឧបករណ៍ការកកើតនោះជាការបញ្ជាក់នូវវិធីការប្តូរពីចក្រវាឡមកមនុស្សដែលអាចយកជាការបាន សំណើរអោយមានការចង្អុលបញ្ជាក់មានប្រសិទ្ធិភាពមិនតិចជាងទ្រឹស្តីដទៃទៀតទេ ហើយគ្មាននរណាបដិសេធ លើកលែងតែអ្នកគិតដ៏ក្រខ្វក់នឹងបដិសេធវាដោយសារតែភាពមិនទំនងជាប់មកជាមួយ។ ដូចគ្នានឹងទ្រឹស្តីវិវឌ្ឍនាការនោះឯង ដែលការប្តូរតំណែងពីមួយទៅមួយ របស់វាមានឫសគល់ស្ថិតក្នុងលោកនៃសេចក្តីពិត ហើយវាអាចជាការបញ្ជាក់ការគាំទ្រដូច្នេះ ជាមូលដ្ឋានគ្រឹះដ៏អស្ចារ្យពីការផ្ទួនផ្ទងគ្នាដែលអាចយកជាការបាន* ។

ដូចគ្នាដែរ *សាស្ត្រាចារ្យហ្គុស ស្ត្រាមប៊ើច* ជាអ្នកតារាវិទ្យាដ៏ល្បីល្បាញ ជាអ្នករូបវិទ្យា និងជាមិត្តភក្តិជាមួយលោកអៃស្តាញជនជាតិស្វីស បានរកឃើញនូវទ្រឹស្តីការកើតថ្មីដូចដែលអធិប្បាយថា *យោបល់គឺខុសគ្នាពីអ្វីដែលវិញ្ញាណមនុស្សអាចអវតារម្តងទៀតនៅលើផែនដីឬទេ។ ក្នុងឆ្នាំ១៩៣៦ ករណីដ៏សំខាន់មួយត្រូវបានគេសិក្សាយ៉ាងល្អិតហើយរាយការណ៍ដោយអាជ្ញាធររដ្ឋាភិបាលឥណ្ឌា។ ក្មេងស្រីម្នាក់ (នាងសន្តិ ទេវី ពីដេលី) អាចអធិប្បាយដូចឃើញនឹងភ្នែកនូវជីវិតពីអតីតកាលរបស់នាង (នៅឯមុត្រា ចំងាយរាប់រយម៉ៃល៍ពីក្រុងដេលី) ដែលទើបតែចប់ទៅត្រឹមតែមួយឆ្នាំមុនពេលការកើតជាលើកទីពីររបស់នាង។ នាងបានប្រាប់ស្វាមីនិងកូនរបស់នាងនិងរៀបរាប់ពីផ្ទះព្រមទាំងប្រវត្តិជីវិត។ ក្រុមអ្នកសិក្សាស៊ើបអង្កេតបាននាំនាងទៅរកញាតិមិត្តដើមរបស់នាង ដែលបានបញ្ជាក់យ៉ាង*

ច្បាស់រាល់ការអះអាងរបស់នាង។ ក្នុងចំណោមការគ្រឡប់ជាតិមកកើត ឥណ្ឌាត្រូវបានគេមើលឃើញថាជាកន្លែងសាមញ្ញធម្មតាវត្ថុដែលគួរអោយភ្ញាក់ផ្អើលសំរាប់ពួកគេក្នុងករណីនេះគឺព្រឹត្តិការណ៍ពិតជាច្រើនដែលក្មេងស្រីនេះបានចងចាំ។ ករណីនេះនិងការស្រដៀងគ្នាផ្សេងទៀតអាចត្រូវបានគេរាប់បញ្ចូលជាភស្តុតាងបន្ថែមទៀតសំរាប់ទ្រឹស្តីការចាំជាតិកំណើតដែលមិនត្រូវបានធ្វើអោយបាត់បង់ទៅនោះ ។

សាស្ត្រាចារ្យជូលៀន ហាក់ស្លេ អ្នកវិទ្យាសាស្ត្រជនជាតិអង់គ្លេសដ៏មានកិត្តិនាមដែលជាអគ្គនាយកនៃអង្គការយូណេស្កូជឿថាការកើតថ្មីពិតជាសមស្របទៅនឹងគំនិតខាងវិទ្យាសាស្ត្រ គ្មានអ្វីប្រឆាំងនឹងជីវិតខាងចិត្តវិញ្ញាណនៃបច្ចេកបុគ្គលដែលមានជីវិតជាអចិន្ត្រៃយ៍ក្នុងករណីខ្លះបន្ទាប់ពីការស្លាប់ ដូចគ្នានឹងសារដែលពិតជាគ្មានខ្សែភ្លើង ត្រូវបានផ្ញើរចេញដោយការធ្វើការយ៉ាងពិតប្រាកដក្នុងករណីជាក់ច្បាស់មួយ។តែវាគួរអោយចងចាំថាសារឥតខ្សែភ្លើងទាំងនេះ ពិតជាអាចក្លាយជាសារម្តងទៀតពេលវាមកតភ្ជាប់នឹងគ្រឿងទទួលដែលមានគ្រោងសាងជាវត្ថុនិងថ្មី។ដូច្នេះជាមួយនឹងការភាយចេញដែលអាចប្រព្រឹត្តទៅបានរបស់វិញ្ញាណវាមិនដែលគិតឬទទួលអារម្មណ៍រហូតដល់វាករជារូបរាងម្តងទៀតក្នុងលក្ខណះផ្សេងទៀត។ បុគ្គលិកលក្ខណះរបស់យើងគឺពឹងផ្អែកទៅលើខ្លួនយើងដែលពិតជាមិនអាចគិតដល់ការមានជីវិតដែលអាចស្ថិតក្នុងលក្ខណះរូបារម្មណ៍ពិតណាមួយដោយគ្មានប្រភេទនៃខ្លួនប្រាណ។ ខ្ញុំអាចគិតដល់វត្ថុខ្លះដែលត្រូវបានបញ្ជូនចេញដោយអាចទ្រទ្រង់សម្ព័ន្ធភាពដូចគ្នារវាងបុរសនិងស្ត្រីដូចគ្នានឹងសារគ្មានខ្សែភ្លើងដែរ បញ្ជូនទៅកាន់វត្ថុបន្ទាស់សំរាប់ចិត្តវិញ្ញាណ ។

ទោះបីមនុស្សដែលស្គាត់ជំនាញខ្លាំងហើយចុះមកកាន់ផែនដីដូចជាអ្នកឧស្សាហកម្ម ហិនរី ហ្វ៊ត ជនជាតិអាមេរិកាំង បានរកឃើញគំនិតការទទួលយករឿងការចាប់កំណើតថ្មី

ហ្វ៊តបានចាប់អារម្មណ៍ទៅនឹងគំនិតជឿរឿងការកើតថ្មីពីព្រោះការកើតថ្មីផ្តល់ឱកាសជាលើកទី២
ដើម្បីអភិវឌ្ឍន៍ខ្លួនឯង ដែលខុសពីគំនិតទេវនិយមឬគំនិតវត្ថុនិយម។ ហិនរី ហ្វ៊តនិយាយថា

*ខ្ញុំសំរេចយកទ្រឹស្តីការត្រឡប់ជាតិពេលខ្ញុំអាយុ២៦ឆ្នាំ។ សាសនាមិនបានផ្តល់អ្វីឡើយ
ចំពោះរឿងនេះ។ សូម្បីការងារក៏មិនអាចផ្តល់នូវភាពផ្អែតផ្អល់ដល់ខ្ញុំទាំងអស់ទេ។ ការងារគឺ
មានជីជាតិមិនគ្រប់គ្រាន់បើយើងមិនអាចប្រើប្រាស់បទពិសោធន៍ដែលយើងប្រមូលទុកក្នុងជីវិត
មួយនាពេលអនាគត។ ពេលខ្ញុំរកឃើញការអវតារជីវិតវាហាក់ដូចជាខ្ញុំបានរកឃើញគំរោងចក្រ
វាឡដែលខ្ញុំជឿច្បាស់ថា មានឱកាសមួយដើម្បីបំពេញគំនិតរបស់ខ្ញុំ។ ពេលវេលានឹងមិនមាន
កំណត់ព្រំដែនទៀតទេ។ ខ្ញុំនឹងមិនជាទាសករចំពោះទ្រនិចនាឡិការទៀតទេ។ ភាពវាងវៃគឺ
បទពិសោធន៍។ អ្នកខ្លះគិតថាវាគឺជារង្វាន់ឬទេព្យកោសល្យ តែវាជាផល(វិបាក)នៃបទពិ
សោធន៍ដ៏យូរអង្វែងក្នុងជាតិជាច្រើន។ អ្នកខ្លះគឺមានវិញ្ញាណចាស់ជាងអ្នកដទៃ ហើយ
ដូច្នោះគេដឹងច្រើនជាង។ ការរកឃើញនូវការអវតារធ្វើអោយចិត្តខ្ញុំស្ងប់។ បើអ្នកទទួលយក
ការថតការសន្ទនានេះ ចូរកំណត់ចំណាំវា ដូច្នេះអាចធ្វើអោយចិត្តរបស់មនុស្សបានស្ងប់។
ខ្ញុំគប្បីនឹងធ្វើទំនាក់ទំនងជាមួយអ្នកដទៃនូវភាពស្ងប់ស្ងាត់ ដែលទស្សនៈរឿងជីវិតដ៏យូរអង្វែង
ផ្តល់អោយយើង ។*

ដូច្នេះការប្រៀនប្រដៅរឿងការចាប់កំណើតក្នុងព្រះពុទ្ធសាសនាពិតជាមានភស្តុតាង
ខាងវិទ្យាសាស្រ្តខ្លះដែលគាំទ្រវា។ វាមានភារៈពិតប្រាកដតាមហេតុបច្ច័យ ហើយវាធ្វើដំណើរ
នៅលើកំណាត់ផ្លូវវែងឆ្ងាយ ដើម្បីឆ្លើយនូវសំណួរទាំងឡាយដែលទ្រឹស្តីវត្ថុនិយមនិងទេវនិយម
មិនអាចឆ្លើយតបបាន។

វាក៏ជាការសុខស្រួលខ្លាំងណាស់ផងដែរ។ អ្វីដែលអាក្រក់ជាងទ្រឹស្តីជីវិតដែលមិនផ្តល់អោយអ្នកនូវឱកាសទីពីរ គ្មានភ័ព្វសំណាងដើម្បីកែប្រែនូវកំហុសឆ្គងដែលអ្នកបានធ្វើក្នុងជាតិនេះ ហើយគ្មានពេលអភិវឌ្ឍន៍បន្ថែមនូវភាពជំនាញនិងលទ្ធភាពដែលអ្នកបានបីបាច់រក្សាក្នុងជីវិតនេះ។ តែតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ បើអ្នកមិនបានសំរេចព្រះនិព្វានក្នុងជីវិតនេះទេ អ្នកនឹងមានឱកាសព្យាយាមម្តងទៀតក្នុងជាតិខាងមុខ។ បើអ្នកបានសាងកំហុសឆ្គងក្នុងជាតិនេះ អ្នកនឹងអាចធ្វើអោយត្រឹមត្រូវដោយខ្លួនឯងក្នុងជាតិខាងមុខ។ អ្នកនឹងអាចបានសិក្សាយ៉ាងពិតប្រាកដពីកំហុសឆ្គងរបស់អ្នក។ រឿងរ៉ាវទាំងឡាយដែលអ្នកមិនអាចធ្វើឬសំរេចបានក្នុងជីវិតនេះ អាចនឹងប្រែទៅជាល្អក្នុងជាតិខាងមុខ។ *តើពាក្យប្រៀនប្រដៅអ្វីក៏អស្ចារ្យម្លេះ!*

# ភាគ ៦

# សមាធិ

**ប្ញ.** *តើអ្វីគឺសមាធិ?*

**ឆ.** សមាធិគឺជាការព្យាយាមខាងផ្លូវសតិមួយដើម្បីផ្លាស់ប្តូរនូវវិធីការធ្វើការរបស់ចិត្ត។ ពាក្យបាលីសមាធិគឺ ភាវនា ដែលមានន័យថា *ធ្វើអោយលូតលាស់ ឬ អភិវឌ្ឍន៍* ។

**ប្ញ.** *តើសមាធិមានសារៈប្រយោជន៍ទេ?*

**ឆ.** ចំពោះ មានសារៈប្រយោជន៍ណាស់។ មិនមានបញ្ហាថាយើងត្រូវការសេចក្តីល្អចំនួនប៉ុន្មានទេ បើយើងមិនអាចផ្លាស់ប្តូរសេចក្តីប្រាថ្នាដែលធ្វើអោយយើងប្រព្រឹត្តតាមតែចិត្តដែលមិនងាយកែប្រែបាន។ ឧទាហរណ៍ មនុស្សម្នាក់អាចនឹងដឹងខ្លួនថាគាត់គឺមិនមានសេចក្តីអត់ធន់ចំពោះភរិយារបស់គាត់ហើយគាត់អាចនឹងសន្យាខ្លួនឯងថា *ចាប់ពីពេលនេះតទៅខ្ញុំនឹងមិនជាមនុស្សទោសៈរហ័សទៀតទេ។* ប៉ុន្តែមួយម៉ោងក្រោយមកគាត់អាចនឹងស្រែកគំហកដាក់ភរិយាគាត់យ៉ាងងាយបំផុត ពីព្រោះគាត់គ្មានសតិដឹងដោយខ្លួនឯង ទោសៈកើតឡើងដោយគាត់មិនដឹងវាទាល់តែសោះ។ សមាធិជួយអោយអភិវឌ្ឍន៍សតិនិងថាមពលដែលត្រូវការដើម្បីកែប្រែទំរង់ទំលាប់ផ្លូវចិត្តដែលជ្រាបចូលមក ។

**ប្ញ.** *ខ្ញុំបានឮថាសមាធិអាចគ្រោះថ្នាក់។ តើនេះជារឿងពិតមែនឬ?*

**ឆ.** ដើម្បីមានជីវិតយើងត្រូវការរសជាតិប្រៃ។ តែបើបរិភោគអំបិលមួយគីឡូក្រាម វាអាច

នឹងសំលាប់អ្នក។ ដើម្បីរស់នៅក្នុងលោកទំនើបថ្មីអ្នកត្រូវការរថយន្តតែបើអ្នកបើកមិនគោរពច្បាប់ចរាចរឬបើអ្នកបើកបរក្នុងពេលស្រវឹង រថយន្តនឹងក្លាយជាគ្រឿងយន្តគ្រោះថ្នាក់។ សមាធិគឺដូចនេះឯង វាសំខាន់ណាស់សំរាប់សុខភាពផ្លូវចិត្តរបស់យើងនិងជីវិតផាសុខប៉ុន្តែបើយើងបដិបត្តិក្នុងផ្លូវលើលានឹងបង្កបញ្ហាជាច្រើន។ មនុស្សខ្លះមានបញ្ហាដូចជាការធុញថប់ជីវិត សេចក្តីភិតភ័យឥតហេតុផលឬរោគព្រួយចិត្ត គេថាសមាធិជាឱសថព្យាបាលរោគនេះបានឆាប់រហ័ស។ ពួកគេចាប់ផ្តើមធ្វើសមាធិហើយជួនកាលបញ្ហារបស់ពួកគេកាន់តែអាក្រក់ឡើង។ បើអ្នកមានបញ្ហាដូច្នេះមែន អ្នកគួរតែស្វែងរកគ្រូដែលជំនាញៗហើយពេលក្រោយបើអ្នកបានធូរស្បើយឡើងក៏គួរនឹងបដិបត្តិអោយជាប់ជានិច្ច។ អ្នកដទៃទៀតខ្លះធ្វើបានសម្រេចដោយខ្លួនគេផ្ទាល់ ពួកគេបដិបត្តិសមាធិហើយមិនតែបដិបត្តិជាបន្តបន្ទាប់មួយជំហានម្តងមួយជំហានម្តងនោះទេ ពួកគេធ្វើសមាធិដោយប្រឹងយ៉ាងខ្លាំងអស់រយៈពេលដ៏យូររហូតដល់អស់កំឡាំងល្អិតល្ហៃមួយរំពេច។ តែប្រហែលជាបញ្ហាភាគច្រើនក្នុងការធ្វើសមាធិបណ្តាលមកពីធ្វើសមាធិបែបសត្វកាំងហ្គារូ។

អ្នកខ្លះទៅរកគ្រូម្នាក់ហើយបដិបត្តិសមាធិតាមវិធីរបស់គាត់អស់មួយរយៈ បន្ទាប់មកពួកគេបានអានសៀវភៅខ្លះរួចសម្រេចចិត្តព្យាយាមធ្វើតាមវិធីនោះ តែមួយសប្តាហ៍ក្រោយមកគ្រូបង្រៀនសមាធិម្នាក់ដែលល្បីឈ្មោះមកលេងក្នុងក្រុងហើយពួកគេប្រាថ្នាចង់អោយគាត់ចូលរំលែកយោបល់ទស្សនៈខ្លះក្នុងការបដិបត្តិរបស់ពួកគេ ហើយបន្ទាប់ក្រោយមកបន្តិចពួកយោគាវចរកើតភាន់ច្រឡំរហូតដល់អស់សង្ឃឹម។លោតដូចជាសត្វកាំងហ្គារូពីវិធីបដិបត្តិសមាធិមួយទៅរកមួយទៀតគឺជាកំហុសឆ្គងដ៏ធំមួយ។ តែបើអ្នកមិនមានបញ្ហាឈឺចាប់ខាងផ្លូវចិត្តទេហើយអ្នកមកបដិបត្តិសមាធិ រួចបដិបត្តិយ៉ាងយកចិត្តទុកដាក់ វាគឺជាវិធីដ៏ល្អបំផុតមួយដែលអ្នកអាចធ្វើដោយខ្លួនអ្នកផ្ទាល់។

**បុ.** *តើមានវិធីបដិបត្តិសមាធិប៉ុន្មានយ៉ាង?*

**ទំ.** ព្រះពុទ្ធជាម្ចាស់បង្រៀនវិធីបដិបត្តិសមាធិច្រើនយ៉ាង វិធីនិមួយៗរចនាឡើងដើម្បីជំនះលើបញ្ហាដែលមានពិតប្រាកដឬដើម្បីអភិវឌ្ឍន៍អង្គផ្លូវចិត្តដ៏ពិតប្រាកដ។ ប៉ុន្តែប្រភេទការបដិបត្តិសមាធិពីរយ៉ាងដ៏សាមញ្ញនិងមានប្រយោជន៍បំផុតគឺការកំណត់សតិដោយដង្ហើមខ្យល់ចេញចូល (អានាបានស្សតិ) និងចំរើនមេត្តាធម៌ (មេត្តាភាវនា) ។

**បុ.** *តើអ្នកបដិបត្តិការចំរើនសតិដោយដង្ហើមខ្យល់ចេញចូលដោយវិធីណា?*

**ទំ.** អ្នកអាចបដិបត្តិតាមវិធីដ៏ងាយៗនេះ គឺ៤ភី ដូចជា:ទីកន្លែង ឥរិយាបថ ការបដិបត្តិនិងបញ្ហា។ ទីមួយចូរស្វែងរកទីកន្លែងដែលសមរម្យ អាចជាបន្ទប់ដែលមិនមានសំលេងអ៊ូរអរហើយទំនងជាមិនមានការរំខាន។ ទីពីរ ចូរអង្គុយក្នុងឥរិយាបថដែលងាយស្រួល។ ឥរិយាបថអង្គុយដែលល្អគឺអង្គុយពេនភ្នែន ខ្នើយមួយកល់ពីក្រោមគូថ តំរង់ឆ្អឹងខ្នងអោយត្រង់ ដៃទាំងពីរដាក់ពីលើភ្លៅហើយបិទភ្នែកទាំងពីរ។ វិធីផ្សេងទៀត អ្នកអាចអង្គុយលើកៅអីយូរបានទៅតាមដែលអ្នកអាចកំណត់ខ្នងអោយត្រង់។ បន្ទាប់មកទៀតចាប់ផ្តើមបដិបត្តិពិតដោយខ្លួនឯង។ ក្នុងខណៈដែលអ្នកអង្គុយយ៉ាងស្ងៀមស្ងាត់ដោយបិទភ្នែកទាំងគូរ អ្នកត្រូវតាំងចិត្តពិចារណាចំពោះដង្ហើមខ្យល់ចូលនិងដង្ហើមខ្យល់ចេញ។ វិធីនេះអាចធ្វើបានដោយការរាប់ដង្ហើមខ្យល់ឬរំពៃរ៍សំឡឹងមើលការចោងឬផតចុះរបស់ផ្ទៃពោះ។ ពេលបានធ្វើដូច្នេះបញ្ហាធំៗនិងសេចក្តីលំបាកទាំងឡាយនឹងផុសចេញឡើង។អ្នកអាចជួបប្រទះការរមាស់ដែលរោលក្រហាយនៅលើរាងកាយឬការចុករោលក្បាលជង្គង់។ បើហេតុការណ៍នេះកើតឡើង ចូរព្យាយាមរក្សារាងកាយនៅស្ងៀមដោយមិនកំរើក ហើយគិតតែខំប្រឹងពិចារណាទៅលើខ្យល់ដង្ហើម។ អ្នកប្រហែលជាមានគំនិតរំខានច្រើនជ្រៀតចូលមកក្នុងចិត្តរបស់អ្នកហើយ

ទាញការតាំងចិត្តពីការពិចារណាខ្យល់ដង្ហើម។ វិធីតែម្យ៉ាងដែលអ្នកអាចដោះស្រាយជាមួយបញ្ហានេះគឺរក្សាអត់ទ្រាំរំលឹកនូវការពិចារណារបស់អ្នកទៅរកខ្យល់ដង្ហើមវិញ។ បើអ្នកអត់ធន់ធ្វើដូច្នេះ ចិត្តរបើរវាយនិងខ្សោយចុះ ការខំរំពៃចិត្តរបស់អ្នកនឹងមានកំឡាំងខ្លាំងហើយអ្នកបានសេចក្តីស្ងប់ក្នុងចិត្តយ៉ាងជ្រៅជាខណៈៗ ព្រមទាំងសេចក្តីស្ងប់នៅខាងក្នុង ។

ឞុ. *តើខ្ញុំអាចធ្វើសមាធិយូរយ៉ាងណា?*

ភិ. វាជាការប្រសើរណាស់បើបដិបត្តិសមាធិបាន១៥នាទីជារៀងរាល់ថ្ងៃក្នុងមួយសប្តាហ៍ ហើយក្រោយមកបន្ថែម៥នាទីជារៀងរាល់សប្តាហ៍ រហូតដល់អ្នកអាចធ្វើសមាធិបាន៤៥នាទី។ បន្ទាប់ពីការធ្វើសមាធិជារៀងរាល់ថ្ងៃជាប្រចាំពីរបីសប្តាហ៍កន្លងមក អ្នកអាចចាប់ផ្តើមសំគាល់ថាការរំងាប់ចិត្តអោយស្ងប់របស់អ្នកមានការប្រសើរឡើង មានចិត្តរបើរវាយតិច ហើយអ្នកអាច មានសេចក្តីសុខពិតប្រាកដគ្រប់ខណៈទាំងអស់ ព្រមទាំងស្ងប់ជារៀងរហូត។

ឞុ. *ចុះអំពីការចំរើនមេត្តាសមាធិជាអ្វី? តើសមាធិនេះគេបដិបត្តិដូចម្តេច?*

ភិ. អ្នកធ្លាប់ស្គាល់ខ្លះម្តងហើយអំពីការបដិបត្តិអានាបានស្សតិសមាធិហើយកំពុងបដិបត្តិយ៉ាងជាប់លាប់ អ្នកអាចចាប់ផ្តើមបដិបត្តិចំរើនមេត្តាសមាធិ។ អ្នកគួរគប្បីធ្វើ២ឬ៣ដងរៀងរាល់សប្តាហ៍ក្រោយពីអ្នកបានបដិបត្តិចំរើនមេត្តាសមាធិ។ ដំបូង អ្នកសំឡឹងមករកខ្លួនអ្នក ហើយនិយាយមកកាន់ខ្លួនឯងថា *សូមអោយខ្ញុំនៅជាសុខនិងប្រាសចាកទុក្ខ។ សូមឱ្យខ្ញុំមានសេចក្តីសុខនិងសេចក្តីស្ងប់។ សូមអោយខ្ញុំរួចចាកផុតពីគ្រោះភ័យទាំងពួង។ សូមអោយចិត្តរបស់ខ្ញុំរួចចាកផុតពីការបៀតបៀន។ សូមអោយបេះដូងរបស់ខ្ញុំពេញប្រៀបទៅដោយមេត្តាធម៌។ សូមអោយខ្ញុំនៅជាសុខនិងប្រាសចាកទុក្ខ។* បន្ទាប់មកបន្តិចម្តងៗអ្នកផ្សាយមេត្តា

ដល់មនុស្សដែលអ្នកស្រលាញ់ មនុស្សឧបេក្ខានោះគឺមនុស្សដែលអ្នកមិនស្អប់មិនស្រលាញ់ ហើយចុងក្រោយគេគឺមនុស្សដែលអ្នកមិនស្រលាញ់ ប្រាថ្នាអោយគេគ្រប់គ្នានោះបានសេចក្ដីសុខ

ម. *តើការបដិបត្តិសមាធិបែបនេះបានប្រយោជន៍យ៉ាងណា?*

ទ. បើអ្នកបដិបត្តិមេត្តាសមាធិបានយ៉ាងជាប់លាប់ ជាមួយនឹងការបដិបត្តិដែលត្រឹមត្រូវ អ្នកអាចជួបប្រទះការផ្លាស់ប្ដូរជាវិជ្ជមាននឹងកើតមាននៅក្នុងខ្លួនអ្នក។ អ្នកនឹងរកឃើញនូវការទទួលស្គាល់ខ្លួនឯងកាន់តែខ្លាំងឡើង និងការអត់អោនទោសកំហុសដល់ខ្លួនឯង។ អ្នកនឹងរកឃើញថាអារម្មណ៍របស់អ្នកចំពោះមនុស្សដ៏ជាទីស្រលាញ់របស់អ្នកនឹងមានខ្លាំងឡើង។ អ្នកនឹងរកឃើញខ្លួនឯងក្នុងការសេពគប់មិត្តភក្ដិជាមួយមនុស្សដែលធ្លាប់តែមិនខ្វល់ពីគ្នាឬធ្លាប់តែមិនរវល់នឹងគ្នា ហើយធ្វើឱ្យអ្នកមានបដិឃៈឬការតូចចិត្តដែលអ្នកមានចំពោះអ្នកដទៃ មានការថយចុះបន្តិចហើយអាចរលាយបាត់នៅទីបំផុត។ជួនកាលបើអ្នកស្គាល់នរណាម្នាក់មានជំងឺ ទុក្ខព្រួយក្រំ ឬប្រឈមមុខនឹងសេចក្ដីលំបាក អ្នកអាចនឹកយកមកជាអារម្មណ៍កម្មដ្ឋានរបស់អ្នក ហើយអ្នកនឹងរកឃើញផ្លូវធ្វើឱ្យស្ថានការណ៍របស់ពួកគេប្រសើរឡើង ជាបន្តបន្ទាប់ ។

ម. *តើសមាធិអាចនឹងបានផលយ៉ាងណា?*

ទ. ចិត្ត នៅពេលដែលបានអភិវឌ្ឍន៍ល្អហើយ គឺជាឧបករណ៍ដ៏មានឥទ្ធិពលខ្លាំងក្លាមួយ បើយើងអាចសិក្សាការសង្កេតមើលថាមពលចិត្តរបស់យើង ហើយកំណត់វាទៅរកអ្នកដទៃ វាអាចមានមហិទ្ធិឫទ្ធិចំពោះជនទាំងនោះ។ អ្នកគង់នឹងមានបទពិសោធន៍ល្អដូចនេះ។ប្រហែលជាអ្នកស្ថិតក្នុងបន្ទប់មនុស្សអ៊ូអរហើយមានអារម្មណ៍ថាមានមនុស្សខ្លះកំពុងសំឡឹងអ្នក។ អ្នកងាកមើលជុំវិញដើម្បីធ្វើឱ្យប្រាកដច្បាស់ថាមានអ្នកខ្លះកំពុងសំឡឹងអ្នក។ អ្វីដែលបានកើតឡើង

គឺថាអ្នកត្រូវបានមនុស្សដទៃពញ្ញាក់ឱ្យសង្ស័យដោយថាមពលចិត្តរបស់គេ។ មេត្តាសមាធិគឺដូចនេះឯង។ យើងដាក់ថាមពលចិត្តវិជ្ជមានសញ្ជើងឆ្ពោះទៅ ហើយវាក៏បានប្តូរអារម្មណ៍អ្នកដទៃជាបន្តបន្ទាប់។

**ប្ុ.** *តើខ្ញុំចាំបាច់ត្រូវមានគ្រូបង្រៀនសមាធិខ្ញុំទេ?*

**ទិ.** ការមានគ្រូមិនមែនជាភាពចាំបាច់ខានមិនបាននោះទេ តែការនាំបដិបត្តិផ្ទាល់ពីអ្នកណាម្នាក់ដែលថ្នឹកនឹងសមាធិស្រេចគឺជាជំនួយដ៏ចាំបាច់មួយ។ ជាភ័ព្វអាក្រក់ដែលព្រះសង្ឃនិងឧបាសកខ្លះតាំងខ្លួនឯងថាជាគ្រូបង្រៀនសមាធិ ពេលដែលគេមិនដឹងអ្វីដែលគេនឹងត្រូវបដិបត្តិបន្តិចសោះ។ ព្យាយាមស្វែងរកគ្រូដែលមានឈ្មោះសំឡេងល្អ មានតុល្យភាពខាងបុគ្គលិកលក្ខណៈ និងអ្នកដែលជឿយ៉ាងជាប់លាប់ចំពោះពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់។

**ប្ុ.** *ខ្ញុំបានដឹងថាសមាធិកម្មដ្ឋានត្រូវបានគេប្រើយ៉ាងទូលំទូលាយដោយពួកអ្នកចិត្តវិទ្យានិងប្រាសាទវិទ្យា។ តើនេះជារឿងពិតឬទេ?*

**ទិ.** ចំរើនពរ, វាពិតដូច្នោះមែន។ សមាធិឥឡូវនេះត្រូវបានគេទទួលស្គាល់ថាជាថ្នាំព្យាបាលដ៏មានគុណភាព មានឥទ្ធិពលចំពោះចិត្ត ហើយត្រូវបានប្រើប្រាស់ដោយអ្នកធ្វើការសុខភាពផ្លូវចិត្តជំនាញៗជាច្រើន ដើម្បីជួយបង្កើនការធូរស្រាល យកជំនះលើភាពតានតឹង និងនាំមកនូវសតិជាប់ជាមួយនឹងខ្លួនជានិច្ច។ ការត្រាស់ដឹងឃើញច្បាស់របស់ព្រះពុទ្ធជាម្ចាស់ទៅក្នុងចិត្តមនុស្ស ជួយមនុស្សបានច្រើនសម្បើមណាស់សព្វថ្ងៃនេះ ដូចគ្នាដែលគេបានធ្វើកាលពីសម័យបុរាណកាល ដូច្នេះឯង។

# ភាគ ៧
# បញ្ញា និង មេត្តាធម៌

**សុ.** *តើពាក្យថាបញ្ញា និងមេត្តា មានអត្ថន័យដូចម្តេចក្នុងព្រះពុទ្ធសាសនា?*

**វិ.** សាសនាខ្លះជឿថាមេត្តាធម៌ ឬសេចក្តីស្រលាញ់ (ពាក្យទាំងពីរគឺមានន័យស្រដៀងគ្នាណាស់) ជាគុណភាពខាងផ្លូវចិត្តដ៏សំខាន់បំផុតមួយ តែពួកគេមិនបានយកចិត្តទុកដាក់អភិវឌ្ឍន៍បញ្ញាឡើយ។ ជាលទ្ធផលគឺអ្នកចប់ជាចុងក្រោយដោយក្លាយជាមនុស្សចិត្តល្អល្ងីល្ងើ ជាមនុស្សមានសន្តានចិត្តល្អណាស់ តែមានសេចក្តីយល់ដឹងតិចតួចឬគ្មានសោះឡើយក៏មាន។ ដូចគ្នានឹងវិទ្យាសាស្ត្រដែរ ប្រព័ន្ធនៃទ្រឹស្តីមួយទៀតដែលគេជឿថាបញ្ញាអាចអភិវឌ្ឍន៍ដល់កំពូលបានពេលដែលមនោសញ្ចេតនាទាំងអស់រួមទាំងមេត្តាធម៌ ត្រូវបានទុកដោយឡែកពីគ្នា។ ការអធិប្បាយរឿងនេះគឺថាស្សង់មានទិសដៅក្លាយជាអ្នកគ្រប់គ្រងមុនគេនូវលទ្ធផលហើយបំភ្លេចរឿងនោះចោល ស្សង់គឺជាអ្នកបំរើមនុស្សមិនមែនជាអ្នកគ្រប់គ្រងឬជិះជាន់មនុស្សទេ។ យ៉ាងណាក៏ដោយ អ្នកវិទ្យាសាស្ត្រឱ្យគេខ្ចីនូវចំណេះដឹងជំនាញរបស់ខ្លួនទៅឱ្យអ្នកដទៃអភិវឌ្ឍន៍គ្រាប់បែកបរមាណូ មេរោគសង្គ្រាមនិងផ្សេងៗទៀត។ ជានិច្ចជាកាលសាសនាឃើញហេតុផលនិងបញ្ញាជាសត្រូវនៃមនោសញ្ចេតនាទាំងឡាយដូចជាសេចក្តីស្រឡាញ់និងជំនឿ។ ស្សង់ជានិច្ចជាកាលមើលឃើញ មនោសញ្ចេតនាដូចជាការស្រឡាញ់និងជំនឿថាជាសត្រូវនៃហេតុផលនិងគោលការណ៍។ ហើយតាមពិតទៅពេលដែលស្សង់មានការរីកចំរើនសាសនាក៏ដួលរលំ។ ម្យ៉ាងវិញទៀតព្រះពុទ្ធសាសនា បង្រៀនឱ្យមានការធ្វើឱ្យបច្ចេកបុគ្គលម្នាក់ៗបានសម្រេចជោគជ័យ និងមានតុល្យភាពយ៉ាងពិតប្រាកដ ដែលមនុស្សត្រូវតែអភិវឌ្ឍន៍ទាំងបញ្ញានិងមេត្តាធម៌។ ហើយព្រោះតែវាមិនមែនលទ្ធិប្រកាន់ជ្រុល

តែអាស្រ័យទៅលើការពិសោធន៍ធ្វើឱ្យព្រះពុទ្ធសាសនាគ្មានអ្វីគួរឱ្យភ័យខ្លាច ចំពោះវិទ្យាសាស្ត្រទាល់តែសោះ ។

**ម.** *ដូច្នេះ អាស្រ័យតាមព្រះពុទ្ធសាសនា តើអ្វីគឺជាបញ្ញា?*

**ឆ.** បញ្ញាដ៏ខ្ពង់ខ្ពស់បំផុតគឺមើលឃើញវត្ថុគ្រប់យ៉ាងតាមសេចក្តីពិតដែលកើតឡើងដូចជាឃើញថាជាទុក្ខំ អនិច្ចំ និងអនត្តា។ ការយល់ដូចនេះគឺជាសេរីភាពទាំងស្រុងហើយនាំទៅរកសុវត្ថិភាពនិងសុភមង្គលដ៏អស្ចារ្យមួយដែលគេហៅថាព្រះនិព្វាន។ ទោះជាយ៉ាងណាក៏ដោយព្រះពុទ្ធបរមគ្រូមិនត្រាស់ច្រើនទេអំពីបញ្ញាកំរិតនេះ។ វាមិនមែនជាបញ្ញាបើយើងជឿយ៉ាងងាយនូវអ្វីដែលគេប្រាប់យើង។ បញ្ញាពិតប្រាកដគឺឃើញនិងយល់ដោយត្រង់ដោយខ្លួនឯង។ បញ្ញាកំរិតនេះ ពេលនោះជាបញ្ញាដែលធ្វើចិត្តឱ្យទូលាយជាងចិត្តចង្អៀតចង្អល់មានការចេះស្តាប់ទស្សនៈរបស់អ្នកដទៃជាជាងការស្រឹងរឹងនឹងខ្លួនឯង ពិនិត្យពិចារណានូវហេតុការណ៍យ៉ាងយកចិត្តទុកដាក់នូវអ្វីដែលផ្ទុយពីជំនឿរបស់ខ្លួនឯងជាជាងការបង្កប់ក្បាលខ្លួនឯងទៅក្នុងដីខ្សាច់ ធ្វើខ្លួនឯងជាមនុស្សចូលសង្គមគេបានជាជាងការប្រកាន់ខ្លួននិងការប្រកាន់បក្សពួក ប្រើពេលវេលាក្នុងការបញ្ចេញមតិរបស់យើងនិងជំនឿជាជាងគ្រាន់តែទទួលយល់ព្រមនូវរឿងដែលរំភើបខ្លាំងឬរឿងដំបូងដែលគេប្រាប់យើង ហើយជានិច្ចជាកាលគឺត្រៀមខ្លួនជាស្រេចដើម្បីកែប្រែជំនឿរបស់យើង នៅពេលដែលរឿងរ៉ាវគេផ្តល់ឱ្យយើងផ្ទុយស្រឡះពីយើង ។ មនុស្សដែលធ្វើដូចនេះ គឺជាមនុស្សឆ្លាតដ៏ពិតប្រាកដហើយនៅទីបំផុតពិតជាទទួលបាននូវការយល់ដឹងដែលពិតប្រាកដ។ មគ្គាដែលគ្រាន់តែការជឿនូវអ្វីដែលគេប្រាប់អ្នកគឺងាយណាស់ ។ វិធីព្រះពុទ្ធសាសនាទាមទារឱ្យយើងក្លាហាន អត់ធន់ រស់រវើក និងឆ្លាតវាងវៃ ។

**ឬ.** *តើគោលនៃព្រះពុទ្ធសាសនាគឺអ្វីបើមានតែពីរបីនាក់ប៉ុណ្ណោះអាចបដិបត្តិបាន?*

**ទ.** វាជាសេចក្តីពិតដែលអ្នករាល់គ្នាមិនទាន់ត្រៀមខ្លួនជាស្រេចចូលកាន់ព្រះពុទ្ធសាសនានៅឡើយ។តែទោះបីនិយាយដូច្នោះក៏ដោយ យើងក៏អាចបង្រៀនសាសនាបែបក្លែងក្លាយ តែធ្វើឱ្យអ្នកទាំងអស់គ្នាយល់បានយ៉ាងងាយ អាចបដិបត្តិបានដែលមិនគួរឱ្យជឿ។ ព្រះពុទ្ធសាសនាតាំងគោលដៅទៅរកសច្ចភាព បើអ្នកទាំងអស់គ្នាមិនមានសមត្ថភាពយល់ដឹងវាទេ ពួកគេគង់នឹងត្រៀមខ្លួនជាស្រេចដើម្បីវានៅជាតិខាងមុខរបស់ពួកគេ។ទោះជាយ៉ាងណាក៏ដោយមានមនុស្សជាច្រើនដែលគ្រាន់តែមានពាក្យត្រឹមត្រូវឬការលើកទឹកចិត្តអាចនឹងលើកកំពស់សេចក្តីយល់ដឹងរបស់ពួកគេ។ ហើយសំរាប់ហេតុផលនេះដែលពុទ្ធសាសនិកជនព្យាយាមយ៉ាងស្វាត់ៗនិងទន់ភ្លន់ដើម្បីចូលរួមធ្វើឱ្យយល់ច្បាស់នូវព្រះពុទ្ធសាសនាជាមួយអ្នកដទៃ។ព្រះពុទ្ធបរមគ្រូបានបង្រៀនយើងឱ្យផ្សាយមេត្តាធម៌ ហើយយើងបង្រៀនអ្នកដទៃឱ្យផ្សាយមេត្តាធម៌ផងដែរ ។

**ឬ.** *អាស្រ័យតាមព្រះពុទ្ធសាសនា តើអ្វីគឺជាមេត្តាធម៌?*

**ទ.** បញ្ញាគ្រាន់តែគ្របដណ្តប់ទៅលើផ្នែកយល់ដឹងឬបញ្ញានៃធម្មជាតិរបស់យើង។ ដូចគ្នានឹងបញ្ញា មេត្តាធម៌គឺជាគុណភាពពិសេសមួយរបស់មនុស្ស។មេត្តាធម៌បង្កើតឡើងដោយពាក្យពីរម៉ាត់។ *កូ* មានន័យថារួមគ្នា និង *ផាស់សិន* មានន័យថាអារម្មណ៍ដ៏ជ្រាលជ្រៅ។ហើយនេះគឺជាអត្ថន័យរបស់ពាក្យមេត្តាធម៌។ ពេលយើងឃើញនរណាម្នាក់ទុក្ខព្រួយហើយយើងមានអារម្មណ៍ថាសេចក្តីទុកចាប់របស់ពួកគេ ហាក់ដូចជារបស់យើងផ្ទាល់ ហើយព្យាយាមព្យាបាលលុបបំបាត់ឬធ្វើឱ្យថយចុះនូវសេចក្តីទុកចាប់របស់ពួកគេ ហើយនេះគឺជាមេត្តាធម៌។ ដូច្នេះភាពល្អបំផុតសំរាប់មនុស្សលោកយើង ភាពជាព្រះពោធិសត្វទាំងឡាយចូលចិត្តចែករំលែក ត្រៀម

ជាស្រេចនឹងឱ្យគេបានសុខ ករុណាធម៌ យកចិត្តទុកដាក់និងគាំពារ-ទាំងអស់នេះគឺបញ្ជាក់នូវមេត្តាធម៌។

អ្នកនឹងសង្កេតផងដែរនូវអ្វីមានក្នុងមនុស្សប្រកបដោយមេត្តាធម៌គាំពារនិងស្រឡាញ់ចំពោះអ្នកដទៃមានប្រភពរបស់វាមកពីការគាំពារនិងស្រឡាញ់ខ្លួនឯង។យើងអាចយល់អ្នកដទៃយ៉ាងច្បាស់ពេលដែលយើងយល់ខ្លួនយើងបានច្បាស់។យើងនឹងដឹងអ្វីដែលជាចំណុចខ្លាំងរបស់អ្នកដទៃពេល យើងដឹងនូវចំណុចខ្លាំងរបស់ខ្លួនយើង។ ដូច្នេះក្នុងព្រះពុទ្ធសាសនាមនុស្សម្នាក់ៗជាកម្មសិទ្ធក្នុងការអភិវឌ្ឍន៍ផ្លូវសតិស្មារតីឱ្យរីកស្គុះស្គាយតាមធម្មជាតិពិតប្រាកដចូលទៅក្នុងសុខមាលភាពរបស់អ្នកដទៃ។ ជីវិតរបស់ព្រះពុទ្ធបរមគ្រូលាតត្រដាងបង្ហាញនូវរឿងនេះបានយ៉ាងច្បាស់។ ព្រះអង្គចំណាយពេល៦ឆ្នាំប្រយុទ្ធប្រឆាំងនូវសុខមាលភាពខ្លួនឯងបន្ទាប់ពីពេលដែលព្រះអង្គអាចក្លាយជាអ្នកធ្វើប្រយោជន៍ដល់មនុស្សលោកទាំងមូល។

**ស**. *តើវាមិនមែនជាបុគ្គលនិយមឬទេ ដែលនិយាយថាយើងគឺចំណុចខ្លាំងបំផុតដែលអាចជួយអ្នកដទៃបន្ទាប់ពីយើងបានជួយខ្លួនយើង ។*

**ឆ**. ជាធម្មតាយើងមើលឃើញបរត្ថភាព ឱ្យការយកចិត្តទុកដាក់ទៅលើអ្នកដទៃមុនខ្លួនយើងជាភាពផ្ទុយគ្នាស្រឡះពីអត្តទត្ថបុគ្គលដែលមើលឃើញផលប្រយោជន៍ផ្ទាល់ខ្លួនមុនអ្នកដទៃ។ ព្រះពុទ្ធសាសនាមិនមើលឃើញមួយណាសំខាន់ជាងមួយណាទេ តែមើលឃើញជាទំរង់ច្របាច់ចូលគ្នាទាំងពីរ។ ការយកចិត្តទុកដាក់តែលើខ្លួនឯងពិតប្រាកដនឹងក្លាយខ្លួនជាបន្តបន្ទាប់ចំពោះការយកចិត្តទុកដាក់ដល់អ្នកដទៃដូចដែលមនុស្សម្នាក់នោះឃើញថាប្រយោជន៍អ្នកដទៃពិតជាដូចគ្នានឹងប្រយោជន៍ផ្ទាល់ខ្លួន។ នេះគឺជាមេត្តាធម៌ដ៏ពិតប្រាកដ។ មេត្តាធម៌គឺជាគ្រាប់ពេជ្រមានរូបឆោមល្អស្រស់បំផុតក្នុងមកុដរបស់ពាក្យប្រៀនប្រដៅព្រះពុទ្ធបរមគ្រូនៃយើង។

# ភាគ ៨
## មំសវិរត្តិ ឬ ការហូបបន្លែបបួស

**ប.** *ពុទ្ធសាសនិកជនគួរតែមិនបរិភោគសាច់ មែនទេ?*

**វិ.** មិនចាំបាច់ទេ។ ព្រះពុទ្ធបរមគ្រូមិនមែនជាអ្នកមិនបរិភោគសាច់ទេ។ ព្រះអង្គមិនបានបង្រៀនសាវ័កទាំងឡាយរបស់ព្រះអង្គជាមំសវិរត្តិឡើយ ហើយទោះបីសព្វថ្ងៃនេះមានពុទ្ធសាសនិកជនដ៏ល្អជាច្រើនដែលមិនមែនជាមំសវិរត្តិ ។

**ប.** *បើអ្នកបរិភោគសាច់ គឺអ្នកត្រូវទទួលខុសត្រូវដោយត្រង់នូវការសំឡាប់សត្វទាំងឡាយ។ តើនោះមិនមែនជាការប្រព្រឹត្តខុសសីលទីមួយឬ?*

**វិ.** វាជារឿងពិតនៅពេលដែលអ្នកបរិភោគសាច់ អ្នកគឺទទួលខុសត្រូវក្នុងការសំឡាប់សត្វមួយផ្នែកនិងដោយប្រយោល តែក៏ដូចគ្នាដែរនៅពេលអ្នកបរិភោគបន្លែ។ អ្នកចំការត្រូវតែបាញ់ថ្នាំពួជផលរបស់គាត់ដោយថ្នាំបំផ្លាញសត្វល្អិតនិងថ្នាំពិស ដូច្នេះធ្វើឱ្យបន្លែមកដល់ចានម្ហូបល្ងាចរបស់អ្នកដោយគ្មានស្លឹកប្រហែងប្រហោង។ ហើយជាថ្មីម្តងទៀត សត្វពាហនៈត្រូវបានគេប្រើដើម្បីយកស្បែកធ្វើខ្សែក្រវាត់ឬកាបូបយួររបស់អ្នក ខ្លាញ់យកធ្វើសាប៊ូឱ្យអ្នកប្រើ និងទំនិញរាប់ពាន់ប្រភេទផងដែរ។ ម្យ៉ាងវិញទៀត វាពិតជាពិបាកនឹងរស់នៅដោយគ្មានទំនួលខុសត្រូវសំឡាប់ជីវិតសត្វដទៃខ្លះដោយប្រយោលនោះទេ។នេះគ្រាន់តែជាឧទាហរណ៍មួយទៀតនៃអរិយសច្ចទីមួយ សភាវៈសាមញ្ញធម្មតាគឺសេចក្តីទុក្ខនិងភាពមិនពេញចិត្ត។ នៅពេលដែលអ្នកសមាទានសីលដំបូង អ្នកព្យាយាមជៀសវាងទទួលខុសត្រូវការសំឡាប់ជីវិតគេដោយត្រង់។

ម. *ពុទ្ធសាសនិកជននិកាយមហាយានមិនបរិភោគសាច់ទេ?*

ទ.នោះគឺមិនត្រឹមត្រូវទេ។ ព្រះពុទ្ធសាសនានិកាយមហាយានក្នុងប្រទេសចិនតឹងតែងណាស់ ក្នុងការបដិបត្តិជាមំសវិរត្តិ តែព្រះសង្ឃ ឧបាសក ឧបាសិកា និកាយមហាយានទាំងនៅក្នុងប្រទេសជប៉ុននិងទីបេ ជាធម្មតាគឺបរិភោគសាច់។

ម. *តែខ្ញុំនៅតែគិតថាពុទ្ធសាសនិកជនគួរតែជាអ្នកមំសវិរត្តិ ។*

ទ. បើមានមនុស្សម្នាក់ដែលជាអ្នកតឹងតែងក្នុងការមិនបរិភោគសាច់តែជាអ្នកអាត្មានិយម ខិលខូចនិងកាចសាហាវ ហើយមនុស្សម្នាក់ទៀតដែលមិនមែនជាអ្នកមំសវិរត្តិ តែជាអ្នកដែលមានសុភវិនិច្ឆ័យចំពោះអ្នកដទៃ ស្មោះត្រង់ ចិត្តទូលាយនិងចិត្តល្អ តើមនុស្សទាំងពីរប្រភេទនេះ ម្នាក់ណាដែលជាពុទ្ធសាសនិកជនល្អជាងគេ?

ម. *មនុស្សដែលជាអ្នកមានសេចក្ដីស្មោះត្រង់និងសន្ដានចិត្តល្អ ។*

ទ. ព្រោះហេតុអ្វី?

ម. *ពីព្រោះមនុស្សប្រភេទនោះមានសន្ដានចិត្តល្អជាក់ស្ដែង ។*

ទ. ពិតប្រាកដហើយ។ មនុស្សដែលបរិភោគសាច់អាចមានសន្ដានចិត្តបរិសុទ្ធ ដូចគ្នានឹងមនុស្សម្នាក់ដែលមិនបរិភោគសាច់អាចមានសន្ដានចិត្តមិនបរិសុទ្ធ។ ក្នុងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គ វត្ថុដែលសំខាន់គឺបេះដូងរបស់អ្នក មិនមែនជាបញ្ជីរតមអាហាររបស់អ្នកទេ។ ពុទ្ធសាសនិកជនជាច្រើនយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការមិនហូបសាច់ តែពួកគេមិន

ចាប់អារម្មណ៍អំពីភាពជាអាត្មានិយម មិនស្មោះត្រង់ កាចសាហាវនិងចិត្តឫស្យា។ ពួកគេប្តូរការតមអាហាររបស់គេដែលងាយនឹងធ្វើ ក្នុងខណៈដែលព្រងើយកន្តើយរឿងការផ្លាស់ប្តូរបេះដូងរបស់គេ ដែលជារឿងលំបាកនឹងផ្លាស់ប្តូរ។ ដូច្នេះទោះបីអ្នកជាមំសវិរត្តិឬទេនោះ ចូរចងចាំទុកថាភាពបរិសុទ្ធិនៃចិត្តគឺជាវត្ថុសំខាន់បំផុតក្នុងព្រះពុទ្ធសាសនា ។

## ភាគ ៩

## សំណាងល្អ និង សំណាងអាក្រក់

**ចុ.** *តើព្រះពុទ្ធជាម្ចាស់បង្រៀនអ្វីខ្លះ អំពីមហិទ្ធិឫទ្ធិនិងការទាយ?*

**ឆ.** ព្រះពុទ្ធបរមគ្រូពិចារណាការបដិបត្តិដូច្នោះថាជាការទោះទាយ ពាក់គាថាការពារ ទាយប្លង់ដី មើលហោរាសាស្ត្រនិងកាត់គ្រោះហ៍ គឺជាជំនឿអរូបីយ៍ឥតប្រយោជន៍ ហើយព្រះអង្គ ហាមប្រាមសាវ័កទាំងឡាយរបស់ព្រះអង្គមិនឱ្យបដិបត្តិវត្ថុដូចនេះ។ ព្រះពុទ្ធអង្គហៅវិជ្ជាទាំងអស់នេះថា *ជាសិល្បៈវិទ្យាថ្នាក់ទាប* ។ *មានអ្នកសាសនាខ្លះក្នុងខណៈដែលមានជីវិតរស់នៅដោយអាស្រ័យបាយទឹកនំចំណីរបស់អ្នកម្ចាស់ទាន ដែលបានមកពីការប្រើសិល្បៈវិទ្យាថ្នាក់ទាបដូចនេះ មុខរបរដែលខុសដូចនោះមានដូចជាទាយបាតដៃ ស័កចារ ទាយសុបិន្តនិមិត្ត ស្រោចទឹកកាត់គ្រោះហ៍ ទាយប្លង់ដី សមណគោត្តម វៀរចាកពីការប្រើសិល្បៈវិទ្យាថ្នាក់ទាបយ៉ាងនេះ វៀរចាកពីការចិញ្ចឹមជីវិត ដោយវិធីខុសយ៉ាងនេះ* ។

**ចុ.** *បើដូច្នោះ ហេតុអ្វីពេលខ្លះមនុស្សបដិបត្តិដូចនោះ ហើយជឿនូវវិជ្ជាសិល្បៈទាំងនេះ*

**ឆ.** ពីព្រោះតែសេចក្ដីលោភលន់ សេចក្ដីភ័យខ្លាចនិងអវិជ្ជា។ ពេលមនុស្សយល់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គកាន់តែរហ័ស ពួកគេនឹងភ្ញាក់ខ្លួនថាបេះដូងពិតប្រាកដអាចការពារពួកគេ បានច្រើនជាងផែនក្រដាស ផែនមេដែក និងពាក្យសូត្រអាគមន៍គាថាមួយម៉ាត់ពីរម៉ាត់ ហើយពួកគេនឹងមិនពឹងពាក់ទៅលើវត្ថុទាំងនោះបន្តទៀតឡើយ ។ នៅក្នុងពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គ វាគឺសេចក្ដីស្មោះត្រង់ សុន្ទានចិត្តល្អ ការយល់

ដឹង អត់ធន់ អភ័យទោស ចិត្តសប្បុរសធម៌ ភក្តីភាព និងសភាពល្អៗ ផ្សេងទៀតដែលអាចការពារអ្នកបានពិតប្រាកដ និងផ្តល់ឱ្យអ្នកនូវភិយ្យាភាពយ៉ាងពិតប្រាកដ។

**បុ.** *តែវេទមន្តភ័ព្វសំណាងខ្លះជួយបានពិតប្រាកដ មែនទេ?*

**ទិ.** ខ្ញុំស្គាល់មនុស្សម្នាក់ដែលចិញ្ចឹមជីវិតដោយការលក់វេទមន្តភ័ព្វសំណាង។ គាត់អះអាងថា វេទមន្តរបស់គាត់អាចធ្វើឱ្យសំណាងល្អ រីកចំរើន ហើយគាត់ធានាថាអ្នកនឹងអាចត្រូវឆ្នោតរង្វាន់លេខបី។ តែបើអ្វីដែលគាត់និយាយជារឿងពិត ចុះហេតុអ្វីបានជាខ្លួនគាត់ផ្ទាល់មិនក្លាយជាមហាសេដ្ឋីទៅ?។ បើវេទមន្តភ័ព្វសំណាងរបស់គាត់ពិតជាជួយពិតប្រាកដមែន ចុះហេតុអ្វីក៏គាត់មិនឈ្នះឆ្នោតរាល់សប្តាហ៍ទៅ?។ ភ័ព្វសំណាងតែមួយយ៉ាងដែលគាត់មានគឺមានមនុស្សឆ្កួតសន្ធាស ចំនួនច្រើនគ្រប់គ្រាន់ល្មម បានទិញវេទមន្តសក្តិសិទ្ធិរបស់គាត់។

**បុ.** *ដូច្នោះ តើមានវត្ថុដូចនេះអាចជាភព្វ័សំណាងទេ?*

**ទិ.** វចនានុក្រមអោយនិយមន័យពាក្យឡាក់ថា “ជំនឿដែលអ្វីក៏ដោយនឹងកើតឡើងទាំងល្អ និងអាក្រក់ ចំពោះមនុស្សដែលស្ថិតនៅក្នុងហេតុការណ៍ទាំងឡាយអាស្រ័យទៅលើកាលៈទេសៈ ជោគវាសនាឬភព្វ័សំណាង”។ព្រះពុទ្ធបរមគ្រូបដិសេធន៍ជំនឿបែបនេះទាំងស្រុង។ អ្វីគ្រប់យ៉ាងដែលកើតឡើង មានមូលហេតុឬសាហេតុទាំងឡាយពិតប្រាកដ ហើយត្រូវតែមានការទំនាក់ទំនងខ្លះរវាងហេតុនិងផល។ សំរាប់ជាឧទាហរណ៍ ពេលយើងធ្លាក់ខ្លួនឈឺមានមូលហេតុពិតប្រាកដរបស់វា។ មនុស្សដែលឈឺពិតជាបានឆ្លងមេរោគ ហើយរាងកាយអ្នកជំងឺពិតជាទន់ខ្សោយអាចធ្វើឱ្យមេរោគកកំណើតខ្លួនវាបាន។មានទំនាក់ទំនងច្បាស់លាស់រវាងហេតុ (មេរោគ និង រាងកាយដែលទន់ខ្សោយ) និងផល (ការឈឺ) ពីព្រោះយើងដឹងថា

មេរោគចូលទៅលុកលុយអវយវៈទាំងឡាយ ហើយធ្វើឱ្យធ្លាក់ខ្លួនឈឺ។ តែគ្មានទំនាក់ទំនងណាអាចត្រូវគេរកឃើញរវាងការពាក់ផែនក្រដាសជាមួយពាក្យដែលចារទុកលើនោះក្លាយជាអ្នកមានឬប្រឡងជាប់ឡើយ។ ព្រះពុទ្ធសាសនាបង្រៀនថាអ្វីក៏ដោយនឹងកើតឡើង កើតឡើងដូច្នេះពីព្រោះហេតុណាមួយឬ ហេតុទាំងឡាយ ហើយមិនអាស្រ័យទៅលើភ័ព្វសំណាងកាលៈទេសៈឬជោគវាសនាឡើយ។ មនុស្សដែលចាប់អារម្មណ៍ទៅលើភ័ព្វសំណាងជានិច្ចជាកាលគឺស្វះស្វែងរកវត្ថុមួយចំនួនដូចជាជាធម្មតាត្រូវការលុយកាក់ឬក៏ទ្រព្យសម្បត្តិច្រើនថែមទៀត ។ ព្រះពុទ្ធបរមគ្រូបង្រៀនយើងថាវាកាន់តែឆ្ងាយពីសារៈសំខាន់ក្នុងការអភិវឌ្ឍន៍បេះដូង និងចិត្តគំនិតទាំងឡាយរបស់យើង ។

ព្រះអង្គត្រាស់ថា :

*ជាអ្នកសិក្សារៀនសូត្រច្រើន និងមានឯកទេសជំនាញ, ជាអ្នកបានហ្វឹកហាត់លត់ដំល្អ*
*និយាយតែពាក្យដែលជាសុភាសិត, នេះគឺជាភ័ព្វសំណាងល្អបំផុត ។*
*ចិញ្ចឹមបីបាច់មាតានិងបិតា, មើលថែទាំភរិយានិងបុត្រីបុត្រា និង*
*មានជីវិតរស់នៅយ៉ាងសាមញ្ញ, នេះគឺជាភ័ព្វសំណាងល្អបំផុត ។*
*ជាអ្នកមានសន្តានចិត្តល្អ មិនលំអៀង, ជួយឃើញ្ញាលញាតិសន្តានរបស់មិត្ត និង*
*ជាអ្នកមិនចេះស្តីបន្ទោសជនដទៃ, នេះគឺជាភ័ព្វសំណាងល្អបំផុត ។*
*វៀរចាកពីអំពើអាក្រក់និងផឹកទឹកស្រវឹង, និងជានិច្ចជាកាលតាំងខ្លួននៅក្នុងគុណធម៌*
*នេះគឺជាភ័ព្វសំណាងល្អបំផុត ។*
*អោនលំទោន មានករុណាធម៌ សេចក្តីរីករាយចិត្ត, ដឹងបុណ្យគុណនិងស្តាប់ធម៌ជាប្រចាំ*
*នេះគឺជាភ័ព្វសំណាងល្អបំផុត ។*

**សំយុត្តនិកាយ ២៦១-២៦៥**

# ភាគ ១០

# ការក្លាយជាពុទ្ធសាសនិកជន

**សួ.** *អ្វីដែលបាននិយាយមកទាំងអស់ល្មមហើយ ធ្វើឱ្យខ្ញុំចាប់អារម្មណ៍ណាស់។ តើខ្ញុំអាចក្លាយជាពុទ្ធសាសនិកជនបានយ៉ាងណា?*

**ទ.** ពេលមួយមានបុរសម្នាក់ឈ្មោះឧបាលី។ គាត់ជាសាវ័ករបស់សាសនាមួយទៀត ហើយគាត់បានចូលទៅរកព្រះពុទ្ធបរមគ្រូក្នុងគោលបំណងដើម្បីជជែកវែកញែកជាមួយព្រះអង្គនិងព្យាយាមទាញព្រះអង្គឱ្យចូលសាសនាគេ។ តែបន្ទាប់ពីនិយាយទៅកាន់ព្រះពុទ្ធបរមគ្រូ ធ្វើឱ្យឧបាលីចាប់អារម្មណ៍យ៉ាងខ្លាំងរហូតគាត់បានសំរេចចិត្តក្លាយខ្លួនជាសាវ័ករបស់ព្រះពុទ្ធអង្គ។ តែព្រះពុទ្ធបរមគ្រូទ្រង់ត្រាស់ថា *ចូរធ្វើការពិនិត្យឱ្យល្អិតជាដំបូងសិន។ ការគិតពិនិត្យឱ្យល្អិតគឺជាការល្អសំរាប់មនុស្សដែលល្បីឈ្មោះដូចជាអ្នក។ ឥឡូវនេះខ្ញុំកាន់តែរីករាយនិងពេញចិត្តពេលដែលព្រះអង្គត្រាស់មកខ្ញុំថា ចូរធ្វើការពិនិត្យឱ្យល្អិតជាដំបូងសិន។ ប្រសិនបើសមាជិកមកពីសាសនាដទៃអាចមកទាក់ទាញខ្ញុំជាសាវ័កម្នាក់ពួកគេអាចនឹងដើរប្រកាសដោយពិងពារដើរជុំវិញទីក្រុងហើយស្រែកថា ឧបាលីបានចុះចូលជាមួយសាសនារបស់យើង។* តែព្រះអង្គត្រាស់មកកាន់ខ្ញុំថា: *ចូរធ្វើការពិនិត្យឱ្យល្អិតជាដំបូងសិន។ ការគិតត្រិះរិះឱ្យល្អិតគឺជាការល្អសំរាប់មនុស្សមានឈ្មោះល្បីដូចជាអ្នក។*

ក្នុងព្រះពុទ្ធសាសនា ការយល់ដឹងគឺជាវត្ថុសំខាន់បំផុត ហើយការយល់ដឹងត្រូវប្រើពេលវេលា។ ដូច្នេះ ចូរកុំប្រញាប់ប្រញាល់ធ្វើតាមតែចិត្តចូលមកកាន់ព្រះពុទ្ធសាសនា។ ចូរប្រើពេលវេលា ចូរចោទសួរ ចូរពិចារណាយ៉ាងល្អិត និងបន្ទាប់មកចូរធ្វើការសម្រេចចិត្តរបស់អ្នក។ ព្រះពុទ្ធអង្គបរមគ្រូមិនបានឱ្យនរណាចាប់អារម្មណ៍ទៅលើការមានចំនួនសាវ័ក

ច្រើននោះទេ។ ព្រះអង្គធ្វើឱ្យគេចាប់អារម្មណ៍ចំពោះមនុស្សដែលអាចបដិបត្តិតាមពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ដែលជាលទ្ធផលនៃការគិតត្រិះរិះឱ្យល្អិត និងគិតពិចារណានូវហេតុការណ៍ទាំងនោះ។

**ម.** *បើខ្ញុំបានធ្វើបូជាហើយអាចយល់ដឹងនូវពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គដែលអាចទទួលយកបាន បន្ទាប់មកតើខ្ញុំគួរធ្វើដូចម្តេចបើខ្ញុំចង់ក្លាយជាពុទ្ធសាសនិកជន?*

**ទ.** បើដូច្នោះមែនវិធីល្អបំផុតនឹងចូលរួមក្នុងវត្តដែលល្អឬក្រុមពុទ្ធសាសនិកជន ចូរជួយឧបត្ថម្ភពួកគេ ឱ្យពួកគេជួយឧបត្ថម្ភយើងហើយបន្តសិក្សារៀនសូត្របន្ថែមទៀតអំពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធបរមគ្រូ។ បន្ទាប់មក ពេលអ្នករៀបចំខ្លួនរួចហើយ អ្នកអាចក្លាយជាពុទ្ធសាសនិកជនជាផ្លូវការដោយយកព្រះរតនត្រ័យជាទីពឹងទីរលឹក ។

**ម.** *តើអ្វីគឺជាការយកព្រះរតនត្រ័យជាទីពឹងទីរលឹក?*

**ទ.** ការយកជាទីពឹងគឺជាកន្លែងមួយដែលមនុស្សដើរទៅរកពេលពួកគេកង្វល់ទុក្ខព្រួយឬពេលពួកគេត្រូវការភាពជាសុខនិងប្រាសចាកការភិតភ័យ។ មានការយកជាទីពឹងទីរលឹកច្រើនយ៉ាងណាស់។ ពេលមនុស្សមិនសប្បាយចិត្ត ពួកគេយកមិត្តភក្តិជាទីពឹងទីរលឹក ពេលពួកគេព្រួយកង្វល់និងភ័យខ្លាច ពួកគេអាចនឹងយកទីពឹងទីរលឹកក្នុងក្តីសង្ឃឹមនិងជំនឿមិនពិត ។ ពេលគេចូលដល់ទីអវសាន្ត ពួកគេអាចនឹងយកជំនឿនៅក្នុងឋានសួគ៌អមតៈជាទីពឹងទីរលឹក។ តែ តាមដែលព្រះពុទ្ធអង្គបរមគ្រូបានត្រាស់ វត្ថុទាំងអស់នោះមិនមែនជាទីពឹងទីរលឹកពិតប្រាកដឡើយពីព្រោះពួកគេមិនបានផ្តល់ឱ្យនូវភាពសុខស្រួល និងទីជ្រកភ័យដែលអាស្រ័យលើសភាវះពិត ។

*ដោយពិតទាំងអស់នេះមិនមែនជាទីពឹងទីរលឹកដ៏ប្រសើរឡើយ,*

*មិនមែនជាទីពឹងដ៏ឧត្តុង្គឧត្តម*

*ជាទីពឹងទីរលឹកដែលគ្មាននរណាម្នាក់*

*អាចចេញចាកផុតពីសេចក្ដីទុក្ខបាន*

*តែយកទីពឹងទីរលឹកក្នុង, ព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ*

*ហើយចាក់ធ្លុះនូវធម៌ពិតប្រាកដ,*

*នូវអរិយសច្ច៤*

*នូវទុក្ខ, នូវហេតុនៃទុក្ខ, នូវការរលត់ទុក្ខ និងអរិយមគ្គប្រកបដោយអង្គ៨*

*ដែលនាំទៅរកការរលត់នូវទុក្ខ*

*នេះគឺពិតជាទីពឹងដ៏ប្រពៃបំផុត*

*វាជាទីពឹងដ៏ឧត្តុង្គឧត្តម*

*វាជាទីពឹងដែលមនុស្សម្នាក់,*

*អាចចេញចាកទុក្ខបាន ។*

*ទីឃនិកាយ ១៨៩-១៩២*

ការយកព្រះពុទ្ធជាទីពឹងគឺជាការទទួលយកដោយជឿទុកចិត្តនូវហេតុការណ៍ដែលមនុស្សម្នាក់អាចក្លាយជាអ្នកត្រាស់ដឹងនិងសុក្រឹតភាពយ៉ាងពេញលេញបានដូចគ្នាដែលព្រះពុទ្ធបរមគ្រូធ្លាប់បានទទួល។ ការយកព្រះធម៌ជាទីពឹងទីរលឹកមានន័យថាយល់នូវអរិយសច្ច៤ ហើយអាស្រ័យលើជីវិតមនុស្សម្នាក់ដែលស្ថិតលើអរិយមគ្គប្រកបដោយអង្គ៨។ ការយកព្រះសង្ឃជាទីពឹងទីរលឹកមានន័យថាសំឡឹងមើលការជួយណែនាំ ការទាក់ទាញនិងការដឹកនាំរបស់ព្រះសង្ឃទាំងឡាយ ដែលបដិបត្តិទៅតាមមាគ៌ាអរិយមគ្គប្រកបដោយអង្គ៨ ។

ការធ្វើដូច្នេះមនុស្សម្នាក់ៗអាចក្លាយជាពុទ្ធសាសនិកជន ហើយបដិបត្តិតាមជំហានដំបូងនៅលើមាគ៌ាឈានទៅរកព្រះនិព្វាន ។

**ឬ.** *តើមានអ្វីផ្លាស់ប្តូរកើតឡើងក្នុងជីវិតរបស់អ្នកចាប់តាំងពីពេលអ្នកយកព្រះរតនត្រ័យជាទីពឹងទីរលឹកជាលើកដំបូង?*

**ឆ.** ដូចគ្នានឹងមនុស្សដែលមិនអាចរាប់បានរាប់លាននាក់កាលពី២៥០០ឆ្នាំមុនអាត្មាបានយល់ច្បាស់ថាពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធបរមគ្រូបានធ្វើឱ្យមានន័យដល់ពិភពលោកដ៏លំបាកនេះ ព្រះធម៌ទាំងនោះបានផ្តល់អត្ថន័យទៅលើអ្វីដែលជាជីវិតឥតខ្លឹមសារ . ព្រះធម៌នោះបានផ្តល់ឱ្យអាត្មានូវចរិយធម៌នៃចិត្តប្រោសប្រណីនិងករុណាធម៌ជាមួយនឹងអ្វីដែលនាំជីវិតអាត្មា ហើយព្រះធម៌នោះបានបង្ហាញអាត្មានូវវិធីដែលអាត្មាអាចសម្រេចនូវភាពបរិសុទ្ធិនិងសុក្រឹតភាពក្នុងជាតិខាងមុខ។ អ្នកកវីឥណ្ឌាសម័យបុរាណបានសរសេរអំពីព្រះពុទ្ធបរមគ្រូថា: *ចូលទៅរកព្រះអង្គដើម្បីយកជាទីពឹង ស្ញូត្របទសរសើរដល់ព្រះអង្គ ធ្វើការគោរពព្រះអង្គ និងជ្រោកក្រោមម្លប់នៃព្រះធម៌របស់ព្រះអង្គដោយការបដិបត្តិដោយភាពយល់ដឹង។* អាត្មាយល់ព្រមទាំងស្រុងនូវពាក្យពេជ្រទាំងឡាយនេះ។

**ឬ.** *ខ្ញុំមានមិត្តម្នាក់ដែលជាញឹកញយព្យាយាមទាក់ទាញខ្ញុំឱ្យចូលសាសនារបស់គេ។ ខ្ញុំពិតជាមិនបានចាប់អារម្មណ៍ទៅលើសាសនារបស់គាត់ ហើយខ្ញុំក៏បានប្រាប់ទៅគាត់ដូច្នេះ តែគាត់នៅតែមិនចាកចេញពីខ្ញុំ។ តើខ្ញុំអាចធ្វើយ៉ាងណា?*

ឆ. រឿងដំបូងដែលអ្នកត្រូវតែយល់គឺថាមនុស្សម្នាក់នេះមិនមែនជាមិត្តពិតរបស់អ្នកទេ។មិត្តពិតទទួលស្គាល់អ្នកនូវអ្វីដែលអ្នកមាន ហើយគោរពបំណងប្រាថ្នារបស់អ្នក។ អាត្មាសង្ស័យថាមនុស្សម្នាក់នេះក្លែងខ្លួនឯងធ្វើជាមិត្តរបស់អ្នក ដូច្នេះគេអាចទាក់ទាញអ្នកឱ្យចូលសាសនាគេ។ ពេលមនុស្សទាំងឡាយកំពុងព្យាយាមបង្ខំនឹងបំណងរបស់អ្នក ពួកគេគឺពិតជាមិនមែនជាមិត្តរបស់អ្នក។

ស. *តែគាត់និយាយថាគាត់ចូលរួមរំលែកសាសនារបស់គេជាមួយខ្ញុំ។*

ឆ.ការចូលរួមរំលែកសាសនារបស់អ្នកជាមួយអ្នកដទៃគឺជារឿងល្អមួយ។តែអាត្មាសំណូមពរថាមិត្តរបស់អ្នកមិនដឹងពីភាពខុសគ្នារវាងការរួមរំលែកនិងការបង្ខំ។ បើអាត្មាមានផ្លែប៉ោមមួយ អាត្មាឱ្យអ្នកឯងពាក់កណ្តាល ហើយអ្នកក៏ទទួលពីអាត្មា ពេលនោះអាត្មាបានបែងរំលែកជាមួយអ្នក។ តែបើអ្នកនិយាយមកកាន់អាត្មាថា *អរគុណ ព្រោះខ្ញុំព្រះករុណាបានហូបរួចហើយ* ហើយអាត្មានៅតែបង្ខំអោយអ្នកត្រូវតែយកផ្លែប៉ោមមួយចំហៀងរហូតដល់អ្នកទទួលដោយចិត្តបង្ខំពីអាត្មា នេះគេមិនអាចហៅថាការរួមរំលែកគ្នាទេ។ មនុស្សដូចជាមិត្តរបស់អ្នកព្យាយាមក្លែងបញ្ចេញការប្រព្រឹត្តអាក្រក់របស់គេដោយនិយាយថា *រួមរំលែក ស្រលាញ់ ឬ មិត្តសប្បុរស* តែដោយឈ្មោះដូចម្តេចក៏ដោយដែលគេហៅវា តែការប្រព្រឹត្តរបស់គេនៅតែគំរោះគំរើយ ឫកពាររអាក្រក់និងអាត្មានិយម ។

ស. *ដូច្នេះតើខ្ញុំអាចបញ្ឈប់គេបានយ៉ាងណា?*

ឆ. វាសាមញ្ញណាស់។ ជាដំបូង ធ្វើចិត្តអ្នកឱ្យច្បាស់លាស់នូវអ្វីដែលអ្នកត្រូវការ។ ទីពីរប្រាប់ទៅគេដូច្នោះឱ្យខ្លីនិងច្បាស់។ ទីបី ពេលគាត់សួរសំណួរអ្នកដូចជា *តើអ្នកមានជំ*

*នឿយ៉ាងម៉េចអំពីបញ្ហានេះ? ឬ ហេតុអ្វីអ្នកមិនប្រាថ្នាមកចូលរួមប្រជុំជាមួយខ្ញុំ*
ចូរបញ្ជាក់សំណួរដំបូងរបស់អ្នកម្តងទៀតដោយភាពម៉ឺងម៉ាត់ សុភាពរាបសារនិងច្បាស់លាស់។
*អរគុណសំរាប់ការកោះអញ្ជើញរបស់អ្នក តែខ្ញុំមិនអាចមកបានទេ។* ហេតុអ្វី មកមិនបាន។
*នោះពិតជារឿងរបស់ខ្ញុំ។ ខ្ញុំមិនអាចមកចូលរួមបានទេ។*

តែមានមនុស្សគួរឱ្យចាប់អារម្មណ៍ច្រើនណាស់នៅទីនោះ។
ខ្ញុំជឿជាក់ថាពិតជាមាន តែខ្ញុំមិនអាចមកចូលរួមបានទេ។
ខ្ញុំកំពុងបបួលអ្នកព្រោះខ្ញុំស្រលាញ់អាណិតអ្នក។
ខ្ញុំសប្បាយចិត្តណាស់ដែលអ្នកស្រលាញ់អាណិតខ្ញុំ តែខ្ញុំក៏មិនអាចមកចូលរួមបានដែរ។
បើអ្នកនិយាយបញ្ជាក់សំដែងភាពម៉ឺងម៉ាត់ អត់ធន់ និងច្បាស់លាស់ ហើយបដិសេធន៏មិនឱ្យគេជាប់សម្ព័ន្ធជាមួយនៅក្នុងការជជែកចោទឆ្លើយនេះ ជាចុងក្រោយគេនឹងបោះបង់ចោល។ វាជាការខ្មាស់អៀនណាស់ដែលអ្នកធ្វើដូច្នេះ តែវាសំខាន់ណាស់សំរាប់មនុស្សដើម្បីរៀនសូត្រដែលពួកគេមិនអាចបង្ខំសទ្ធារបស់ពួកអ្នក ឬប្រាថ្នាអ្វីទៅលើអ្នកដទៃ។

**សុ.** *តើពុទ្ធសាសនិកជនអាចព្យាយាមរួមរំលែកធម៌ជាមួយអ្នកដទៃបានទេ?*

**ទិ.** ចំរើនពរយើងអាចធ្វើបាន។ហើយអាត្មាគិតថាពុទ្ធសាសនិកជនភាគច្រើនយល់ចំពោះភាពខុសផ្សេងពីគ្នារវាងការបង្ខំនិងការរួមរំលែក។ បើមានគេសួរអ្នកអំពីព្រះពុទ្ធសាសនាចូរប្រាប់ពួកគេ។ អ្នកក៏អាចប្រាប់គេអំពីពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់ដោយគ្មានការសាកសួររបស់គេ។ តែបើទាំងដោយកាយឬវាចាដែលគេសំដែងចេញឱ្យអ្នកយល់ថាគេមិនចាប់អារម្មណ៍សោះឡើយ ចូរសំរបតាមហេតុការណ៍នោះហើយគោរពបំណងប្រាថ្នារបស់គេ។ វាគឺ

សំខាន់ផងដែរដោយចងចាំថាអ្នកធ្វើឱ្យមនុស្សទាំងឡាយដឹងអំពីព្រះធម៌កាន់តែមានប្រសិទ្ធិភាពខ្លាំងឡើង តាមរយៈទង្វើរបស់អ្នកជាជាងតាមរយៈការទេសនាប្រដៅពួកគេ។ ចូរបង្ហាញមនុស្សទាំងឡាយឱ្យស្គាល់ធម៌ដោយជានិច្ចជាកាលមានការពិចារណាសន្ដានចិត្តល្អ អត់ធន់ ទៀងទាត់និងស្មោះស្ម័គ្រ។

ចូរជួយឱ្យព្រះធម៌ចែងចាំងរស្មីតាមរយៈពាក្យពេជ្រនិងទង្វើរបស់អ្នក។ បើយើងម្នាក់ៗអ្នកឬក៏អាត្មាចេះនូវធម៌យ៉ាងពិតប្រាកដ អនុវត្តយ៉ាងពេញលេញនិងរួមរំលែកវាប្រកបដោយសន្ដានចិត្តទូលាយជាមួយអ្នកដទៃយើងអាចជាប្រយោជន៍ដ៏ធំធេងចំពោះខ្លួនយើងនិងអ្នកដទៃផងដែរ។

~ ចប់ ~

+ knowlege :
+ behavior :
+ attitude :
+ tolerance :
+ obedient child

